00885396

E1/168.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Feb-2013, 14:05
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ២៧នាទី**

**សវនាការលើកទី១៥៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយធ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*
លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់
លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*
លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន
លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:២៧:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់ការបង្ហាញឯកសារគន្លឹះពាក់ព័ន្ធទៅនឹងអង្គហេតុ តួនាទីរបស់ជនជាប់ចោទ ដោយតំណាងសហព្រះរាជអាជ្ញា។

មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយ-ការណ៍អំពីស្ថានភាព វត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅ ក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីឲ្យលោក អៀង សារី អវត្តមាន ដោយមូលហេតុសុខភាព។ លោក ពេជ អង្គ មេធាវីនាំជាតិ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី អវត្តមាន ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។

ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ រីឯជនជាប់ចោទ ខៀវ សំផន មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ ចំណែកឯកជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព និង កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខ្មែរ-សូវៀត។ សូមអរគុណ។

[០៩:២៩:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះ អង្គជំនុំជម្រះសម្រេចលើកសេចក្តីជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ដែលបានធ្វើកាលពីសប្តាហ៍ម្សិលមិញ ទៅនឹងឯកសារមួយចំនួនដែលតំណាងសហព្រះរាជ អាជ្ញានឹងដាក់បង្ហាញចំពោះមុខ អង្គជំនុំជម្រះពាក់ព័ន្ធនឹងអង្គហេតុ តួនាទីរបស់ជនជាប់ចោទ ដូចខាង

ក្រោមនេះ៖

អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នូវការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន លើឯកសារមួយចំនួនដែលបានកំណត់ដោយសហព្រះរាជអាជ្ញា ដោយមិនត្រូវបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការកំណត់ -- ស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមិនមកបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្ម ដែលបានចេញកាលពីពេលមុន ឯកសារ E96/7 អង្គជំនុំជម្រះបានដាក់នូវក្របខ័ណ្ឌច្បាប់ សម្រាប់ការពិចារណាលើកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅក្នុងឯកសារ E96/7 ហើយអង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើឯកសារបែបនេះផ្អែកតាមការពិចារណាតាមផ្លូវច្បាប់។ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារទាំងអស់ដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធទៅនឹងបុគ្គលដែលបានទទួលមរណភាព ហើយអង្គជំនុំជម្រះយល់ឃើញថាឯកសារទាំងនោះមានភាពពាក់ព័ន្ធនឹងអាចទុកចិត្តបាន ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ តម្លៃនៃភស្តុតាងរបស់ឯកសារទាំងនោះនឹងត្រូវទទួលការវាយតម្លៃដោយផ្អែកលើកាលៈទេសៈ និងបទដ្ឋានផ្លូវច្បាប់ទាំងអស់ដូចមានរៀបរាប់ក្នុងឯកសារ E96/7 ប៉ុន្តែឯកសារ E190.1.72 គឺជាបទសម្ភាសន៍ជាមួយបុគ្គលម្នាក់ដែលអង្គជំនុំជម្រះនឹងកោះអញ្ជើញគាត់ឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលខាងមុខឆាប់ៗនេះ។

[០៩:៣២:០២]

ហេតុដូច្នេះ សហព្រះរាជអាជ្ញា នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារទាំងនេះនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មបុគ្គលនោះ។ ការជំទាស់នានាលើឯកសារដទៃទៀត សហព្រះរាជអាជ្ញាអាចបង្ហាញនាពេលនៃការដាក់បង្ហាញឯកសារនៅក្នុងសវនាការនេះបាន។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារ។

បាទ សូមផ្អាកសិនលោកតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញលោក សុន អរុណ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន!

ដោយយោងទៅតាមរបាយការណ៍របស់វេជ្ជបណ្ឌិតប្រចាំមន្ទីរពេទ្យសូវៀត ស្តីអំពីស្ថានភាពលោក នួន ជា ដែលជាអ្នកជំងឺ ក្នុងឋានៈខ្ញុំៗជាក្រុមមេធាវីការពារលោក នួន ជា សូមជូនយោបល់ទៅ

តុលាការនៅថ្ងៃនេះដូចតទៅ បើលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[០៩:៣៣:២៨]

**លោក សុន អរុណ៖**

ទី១ យោងតាមរបាយការណ៍របស់វេជ្ជបណ្ឌិត អ្នកពិនិត្យជំងឺលោក -- លើរូបលោក នួន ជា ចាប់ពីថ្ងៃទី២៨ ខែ០១ ឆ្នាំ២០១៣ របាយការណ៍លេខ៩៣ ចុះហត្ថលេខាដោយគ្រូពេទ្យបីនាក់ ជាពិសេសលោកវេជ្ជបណ្ឌិត ងី ម៉េង "ថាស្ថានភាពរបស់លោក នួន ជា បានកាន់តែប្រសើរល្អហើយ"។ ទី២ លុះដល់ថ្ងៃទី២៩ ខែ០១ ឆ្នាំ២០១៣ ក្រុមមេធាវីលោក នួន ជា បានទៅសួរសុខទុក្ខលោក នួន ជា តែក្រុមមេធាវីពេលនោះបានទទួលព័ត៌មានពីគ្រួសារលោក នួន ជា ថា "លោក នួន ជា បានប្រាប់គ្រួសារគាត់ឲ្យអញ្ជើញបងប្អូនរបស់គាត់ដែលនៅមានសល់ទាំងប៉ុន្មាននៅ -- ឲ្យមកជួបជុំចំពោះមុខរបស់គាត់នៅពេល -- បើ -- នៅពេល បើមាន (សូមទោស) បើមានគ្រួសារគាត់ប្រាប់ថា លោក នួន ជា ចុះខ្សោយខ្លាំង អ្វីៗធ្វើឲ្យគាត់អស់សង្ឃឹមដោយខ្លួនឯង ខ្លួនគាត់"។ នេះជាការមួយដែលខ្ញុំសូមជូនដំណឹងដល់អង្គជំនុំជម្រះ របាយការណ៍របស់ពេទ្យ អំពីរបាយការណ៍របស់ពេទ្យមានការផ្ទុយគ្នា។

[០៩:៣៥:០៩]

៣) នៅថ្ងៃទី២៩ ខែ០១ ឆ្នាំ២០១២ (ស៊ីក) របាយការណ៍លេខ៩៤ របាយការណ៍របស់មន្ទីរបានរាយការណ៍ថា ស្ថានភាពរបស់លោក នួន ជា កាន់តែប្រសើរ ហើយមាន -- ហើយបានអង្គុយបានខ្លះៗ តែរបាយការណ៍នេះបានបន្ថែមថា ប៉ុន្តែស្ថានភាពចាស់ជរា និងជំងឺរ៉ាំរ៉ៃ តម្រូវឲ្យមានអ្នកថែរក្សាជាប្រចាំ។ របាយការណ៍ទាំងបីថ្ងៃនេះ ដែលបានជម្រាប អ៊ូ! សូមទោស! របាយការណ៍មួយទៀតនៅថ្ងៃទី៣០ ខែ០១ ឆ្នាំ២០១៣ លេខ១០០ បានជម្រាបមកតុលាការថាលោក នួន ជា ពុំមានលទ្ធភាពសុខភាពមានលំនឹងបើប្រៀបធៀបពីម្សិលមិញ។ មានន័យថារបាយការណ៍ទាំងបីនេះ តាំងពីថ្ងៃ២៨មកថាលោក នួន ជា មានជំងឺធូរស្រាល។ ជាការពិតណាស់ ក្រុមមេធាវីការពារលោក នួន ជា មិនមែនជាអ្នកជំនាញខាងពេទ្យមែន តែក្រុមយើងខ្ញុំបានតាមដានសុខភាពរបស់គាត់ រួមទាំងគ្រួសារដែលជាអ្នកថែទាំគាត់ផ្ទាល់នោះ ឃើញផ្ទាល់នឹងភ្នែក ថាស្ថានភាពសុខភាពរបស់លោក នួន ជា ដូចដែលមានរបាយការណ៍របស់លោកគ្រូ ដែលខ្ញុំបានជម្រាបអង្គសវនាការពេលនេះ មានការខុសគ្នាច្រើន។

បើតុលាការអនុញ្ញាតឲ្យខ្ញុំជម្រាបតុលាការ ក៏ដូចជម្រាបសាធារណជនបាននៅពេលនេះ ខ្ញុំនឹងជម្រាប។

[០៩:៣៧:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកជម្រាបរាយការណ៍អ្វីផ្សេងទៀតទេ អនុញ្ញាតឲ្យត្រឹមប៉ុណ្ណេះ ពីព្រោះលោកមិនមែនមានវិជ្ជាជីវៈខាងវេជ្ជសាស្ត្រទេ។ អង្គជំនុំជម្រះជឿជាក់ផ្អែកលើមូលដ្ឋាននៃការពិនិត្យតាមក្បួនវេជ្ជសាស្ត្រ ដែលជាអ្នកមានមុខងារជាក់ច្បាស់ ដែលមានការកិច្ចសន្យាទទួលខុសត្រូវក្នុងការពិនិត្យថែទាំសុខភាពជនជាប់ចោទជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬអ្នកវេជ្ជសាស្ត្រដទៃទៀត អ្នកជំនាញដទៃទៀត ដែលអង្គជំនុំជម្រះចាត់តាំង។ អង្គជំនុំជម្រះមិនស្តាប់បុគ្គលណាដែលមិនមានភាពជំនាញពាក់ព័ន្ធទៅនឹងសុខភាពរបស់បុគ្គលជនជាប់ចោទទេ។

**លោក សុន អរុណ៖**

សូមអរគុណនូវការណែនាំរបស់លោកប្រធាន។ ខ្ញុំចាប់អារម្មណ៍រឿងមួយទៀត--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ! រឿងអ្វីពាក់ព័ន្ធជាមួយនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ គឺទុកលទ្ធភាព និងសមត្ថភាព សមត្ថកិច្ចជូនទៅក្រុមវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលបច្ចុប្បន្នហ្នឹងបាននិងកំពុងទទួលខុសត្រូវបំពេញមុខងារតាមកិច្ចសន្យារវាងមន្ទីរពេទ្យជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើបញ្ហានេះ។ លើកលែងតែលោកមានបញ្ហាផ្សេង បញ្ហាពាក់ព័ន្ធសុខភាពនេះ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

[០៩:៣៩:០២]

**លោក សុន អរុណ៖**

ខ្ញុំសូមលើករឿងមួយដែលមិនមែនជារឿងសុខភាព។ រឿងដែលមានលិខិតមួយដែលពាក់ព័ន្ធទៅនឹងលោក ប៊ូរ៉ាត ក្លូត ដែលផ្ញើជូនមកលោក វ៉ិចទ័រ កូប៉េ និង ផល្លា ព្រំ។ ផល្លា ព្រំ ជាអ្នករៀបចំឯកសារថា នឹងយកលោក នួន ជា មកចេញពីពេទ្យថ្ងៃនេះវេលាម៉ោងពីរ។ អាហ្នឹងធ្វើឲ្យការ ខ្ញុំក្រុមមេធាវីការពារលោក នួន ជា មានការភ្ញាក់ផ្អើលខ្លាំងណាស់។ ហើយ--

**ប្រធានអង្គជំនុំ៖**

អានេះរឿងដដែលរបស់ -- អាហ្នឹងពាក់ព័ន្ធជាមួយកិច្ចការរបស់វេជ្ជបណ្ឌិតទេ បើសិនខាងមន្ទីរពេទ្យបញ្ជូនមកថ្ងៃនេះ ខាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការទទួលយកថែទាំធម្មតា។ ក្នុងករណីចាំបាច់មានបញ្ហាសុខភាពធ្ងន់ធ្ងរដែលត្រូវទៅបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ គឺយើងធ្វើដូចអ្វីដែលយើងបានធ្វើកន្លងមក។ ទីនេះគឺខាងកិច្ចការគ្រូពេទ្យប្រចាំការនៅទីនេះ គេបានយល់ច្បាស់ពីបញ្ហានេះហើយ ហើយគេបានធ្វើការជាប្រចាំ។ យើងបានជម្រាបលោកហើយ ពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់លោក នួន ជា នេះគឺយើងមិនអនុញ្ញាតឱ្យលោកនិយាយទេ លើកលែងតែលោកមានបញ្ហាផ្សេង។ បញ្ហានេះយើងបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីម្សិលមិញ តាមខ្លឹមសារលិខិតនេះ។

**លោក សុន អរុណ៖**

ជាសំណើរបស់ក្រុមមេធាវីការពារលោក នួន ជា សូមស្នើថា មុននឹងយក នួន ជា មក ត្រឡប់មកតុលាការវិញ សូមស្នើថា សូមអញ្ជើញលោកវេជ្ជបណ្ឌិតទទួលខុសត្រូវមកចំពោះមុខតុលាការ ដើម្បីឱ្យបាន ភាគីបានសួរដេញដោលលម្អិតទៅលើជំងឺរបស់លោក នួន ជា សិនមុននឹងយកលោក នួន ជា ត្រឡប់មកតុលាការវិញ។ នេះសំណើ។ សូមអរគុណ។

[០៩:៤១:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបរួចហើយអំមិញណ៎ះ! បញ្ហានេះគឺមិនមែនជានីតិវិធីដែលត្រូវធ្វើដូច្នេះនោះទេ។ វាមិនមានភាពចាំបាច់អ្វីដែលធ្វើដូច្នេះឡើយ។ ដូច្នេះសំណើនេះគឺមិនត្រឹមត្រូវទេ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រីចៅក្រម ភាគី សាធារណជនទាំងអស់គ្នា។

យើងបន្តនៅព្រឹកនេះការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន។ ដើម្បីជាការសរុបដោយសង្ខេបឡើងវិញ កាលពីម្សិលមិញពេលរសៀលយើងបានពិនិត្យមើលកិច្ចសម្ភាសន៍រវាង ខៀវ សំផន និងសហចៅក្រមស៊ើបអង្កេត ការស្តាប់ចម្លើយរវាង ខៀវ សំផន និងសហចៅក្រមស៊ើបអង្កេត។ បន្ទាប់មកគឺយើងបានបន្តពិនិត្យមើលអំពីវត្តមានរបស់លោក ខៀវ សំផន នៅក្នុង

កិច្ចប្រជុំថ្នាក់ដឹកនាំនានា គឺថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចដែលបានលើកឡើងនៅក្នុងភស្តុតាងដែលនៅសល់។ ហើយបន្ទាប់មកទៀតនោះ គឺថាយើងបន្តបង្ហាញនូវឯកសារទាំងឡាយពាក់ព័ន្ធទៅនឹងការបង្កើតកម្ពុជាប្រជាធិបតេយ្យ និងការលាលែងពីមុខតំណែងរបស់សម្តេច នរោត្តម សីហនុ និងការតែងតាំង ខៀវ សំផន ជាគណៈប្រធានរដ្ឋនៅក្នុងរដ្ឋថ្មីនាសម័យនោះ។

[០៩:៤២:៥៥]

យើងបានមើលខ្សែវីដេអូខ្លីមួយ តែជាសំខាន់នោះ ខ្សែវីដេអូនោះរួមមានរូបថតនៃការវិលត្រឡប់មកវិញរបស់សម្តេច នរោត្តម សីហនុ នៅក្នុងឆ្នាំ១៩៧៥ បន្ទាប់មកគឺថា យើងបានចូលទៅដល់ឯកសារលើកឡើងឯកសារមួយទៀតនៅក្នុងប្រធានបទដដែលនោះ។ ឯកសារនេះគឺចុះថ្ងៃ -- ចុះខែមករា ឆ្នាំ៧៦ វាជារបាយការណ៍នៃសុន្ទរកថាថ្លែងឡើងដោយ ខៀវ សំផន។ សុន្ទរកថានេះខ្លួនឯង គឺបានធ្វើឡើង -- បានថ្លែងឡើងថ្ងៃ១៤ ធ្នូ ឆ្នាំ៧៥។ ឯកសារនេះមានលេខ E3/273 ជាព័ត៌មានហ្វីប៊ីស មានចំណងជើងថា "អត្ថបទរបស់ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ពាក់ព័ន្ធទៅនឹងរបាយការណ៍ សេចក្តីព្រាងរដ្ឋធម្មនុញ្ញ ចុះថ្ងៃ១៤ ខែធ្នូ ឆ្នាំ៧៥ សន្និបាតទី៣ នៅក្នុងទីក្រុងភ្នំពេញ"។

ប្រសិនបើយើងមើលឯកសារនេះ លោក លោកស្រីចៅក្រមជាទីគោរព! គឺថា យើងនឹងព្យាយាមបង្ហាញនៅលើអេក្រង់ផងដែរ ដើម្បីឱ្យសាធារណជនបានជ្រាប និងឱ្យអ្នកភាសាខ្មែរ អានភាសាខ្មែរនោះបានយល់ផង។ អ្វីដែលពាក់ព័ន្ធនៅក្នុងឯកសារនេះគឺជាសំខាន់បង្ហាញអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងការបង្កើតរដ្ឋធម្មនុញ្ញ និងបង្កើតរដ្ឋថ្មីនេះ។ ហើយវាក៏បានបង្ហាញអំពីគោលការណ៍មួយចំនួនដែលបានគូសបញ្ជាក់អំពី -- គូសបញ្ជាក់នៅក្នុងរដ្ឋនេះផងដែរ។

[០៩:៤៥:00]

ខ្មែរ ERN 0065748 (ស៊ីក), បារាំង 00745796, អង់គ្លេស 00167811។ យើងឃើញអត្ថបទដែលវាសំខាន់នៅក្នុងនេះ បានសរសេរឡើងពាក់ព័ន្ធទៅនឹងសន្និបាតនាពេលមុន គឺសន្និបាតលើកទី២ ដែលយើងបានស្តាប់ភស្តុតាងរួចមកហើយ គឺសន្និបាតរៀបចំនៅខែកុម្ភៈ ឆ្នាំ៧៥ យោងតាមឯកសារដែលយើងបានឃើញ ដែលនៅក្នុងពេលនោះ គឺថាថ្កោលទោស និងដាក់ទោសជនមហាក្បត់ទាំងប្រាំពីរ។ របាយការណ៍នៅក្នុងនេះ គឺបានលើកឡើងដូចតទៅ "ដោយយោងទៅលើសន្និបាតនាពេលមុន"។ បន្ទាប់មក សមាជលើកទី២ ត្រូវបានប្រារព្ធនៅខែមករា ហើយបានសង្កត់ធ្ងន់នៅ នយោបាយក្នុងស្រុក និងនយោបាយការបរទេសរបស់យើង ដែលរួមមាន៖ ១) វាយប្រហារ និងបណ្តេញពីណ្ឋាន

ចក្រពត្តិអាមេរិក, ២) ថ្កោលទោស និងដាក់ទោសជនមហារក្បត់ទាំងប្រាំពីរ ដែលក្នុងមាន លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វៃណង់ដែស ដែលជាមេប្រឆាំងជាតិ មេហ្វាស៊ីស និងមេក្បត់ពុករលួយ។ និង៣) លើកកម្ពស់គោលជំហរមហាសាមគ្គីភាពជាតិ។

[០៩:៤៦:៣៦]

កថាខណ្ឌបន្ទាប់ពីកថាខណ្ឌពីរខាងក្រោមនេះ គឺបាន ឯកសារនេះបានបង្ហាញអំពីជ័យជម្នះថ្ងៃ ១៧ ខែមេសា ឆ្នាំ៧៥ ហើយបានលើកឡើងដូចតទៅ សូមដកស្រង់សម្តី "នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍យើង ប្រជាជន កម្មករ កសិករ និងប្រជាជាតិយើងទាំងមូលបានសម្រេចជោគជ័យទាំងស្រុង។ នៅពេលនោះយើងបានប្រឈមមុខនឹងភារកិច្ចថ្មីៗជាច្រើនទៀត ក្នុងការការពារ និងរក្សាជ័យជម្នះដែលយើងទទួលបានភារកិច្ចក្នុងការកម្ទេចផែនការរបស់ពួកចក្រពត្តិអាមេរិកទាំងអស់ដែលពួកគេបានរៀបចំឡើងប្រឆាំងនឹងយើងទាំងអស់គ្នា បន្ទាប់ពួកគេបានចាញ់សង្គ្រាម និងភារកិច្ចដោះស្រាយជីវភាពរស់នៅរបស់ប្រជាជន"។

[០៩:៤៧:២៧]

ខ្ញុំសូមរំលងកថាខណ្ឌមួយចំនួន ហើយយើងមើលអត្ថបទខ្លីៗផ្សេងទៀត ដែលលើកឡើងអំពីគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋមធ្មនុញ្ញ។ គោលការណ៍ដែលបានរៀបរាប់លើកឡើងដោយ ខៀវ សំផន នាពេលនោះ។ ចំណុចទី១ គោលការណ៍ទី១ ដែលគាត់បានលើកឡើងនោះ ក្នុងខ្មែរ ERN 00657443, បារាំងមានលេខ 00725798, អង់គ្លេស 00167813។ ពាក់ព័ន្ធទៅនឹងបញ្ហាវប្បធម៌ ខ្ញុំសូមដកស្រង់សម្តី "វប្បធម៌របស់យើងនោះ គឺថាវាមានតម្លៃរបស់វា។ យើងក៏បានជំទាស់ទៅនឹងការពុករលួយ ឬក៏បញ្ហាវប្បធម៌ប្រតិកិរិយា ហើយជាពិសេសវប្បធម៌របស់ចក្រពត្តិនិយម និងពួកមូលធននិយមនៅក្នុងប្រទេសកម្ពុជា។ ខ្សែវីដេអូ ទស្សនាវីដ្តដែលបង្ហាញអំពីបញ្ហាពុករលួយនោះ គឺថាមិនមានទៀតទេ យើងត្រូវបានលុបចោលទាំងស្រុងក្នុងប្រទេសកម្ពុជា រួមជាមួយនឹងបញ្ហាចក្រពត្តិនិយមនៅក្នុងប្រទេសកម្ពុជាផងដែរ"។

[០៩:៤៨:៥០]

កថាខណ្ឌបន្ទាប់ទៀត ដែលនិយាយអំពីបញ្ហាវប្បធម៌ដដែល នៅក្នុងរបបនោះគឺបានលើកឡើងដូចតទៅៈ

"មើល៍ពួកក្បត់ លន់ នល់ ធ្វើចំពោះអ្នកដែលជាប្រជាជនរបស់ខ្លួនយ៉ាងម៉េច។ អ្វីដែល ទាំងផ្ទះ

ទាំងឡាយនៅក្នុងទីក្រុងភ្នំពេញ ពោរពេញទៅដោយរឿងរ៉ាវដែលមិននឹកស្មានដល់ ខ្ញុំមិនដឹងរៀបរាប់យ៉ាងដូចម្ដេចទេ ផ្ទះទាំងនេះគ្មានលក្ខណៈជាតិអ្វីទាំងអស់។ ហេតុដូច្នេះហើយ ទើបយើងប្រឆាំងដាដាច់ខាតនឹងវប្បធម៍បែបនេះ ពីព្រោះប្រសិនបើយើងអនុញ្ញាតឲ្យវប្បធម៍ពុករលួយប្រភេទនេះ បំផ្លិចបំផ្លាញប្រទេសយើង វាប្រាកដជាធ្វើឲ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់យើងក្នុងការការពារប្រទេសការការពារឯករាជ្យ និងអធិបតេយ្យភាពយើងជាមិនដាច់ខាត”។

កថាខណ្ឌបន្ទាប់ ខៀវ សំផន បានបន្តនិយាយអំពីបញ្ហាសមូហភាពនៅក្នុងប្រទេស។ គាត់បានលើកឡើងដូចតទៅ “ទាក់ទងទៅនឹងជំពូកទី៤ យើងអនុវត្តបញ្ហាសមូហភាពនៅក្នុងការងារ។ ប្រព័ន្ធនេះគឺមានប្រសិទ្ធភាពជាយូរមកហើយ។ យើងអនុវត្តប្រព័ន្ធនេះនៅគ្រប់ទីកន្លែង យើងធ្វើតាំងពីមុនរំដោះហើយយើងបន្តរហូតមកដល់ពេលបច្ចុប្បន្ននៅទូទាំងប្រទេស នៅក្នុងរោងចក្រទាំងឡាយរួមទាំងផលិតកម្ម រួមទាំងយើងបានអនុវត្តនៅតាមផលិតកម្ម រោងចក្រផលិតកម្មនានាផងដែរ”។

បន្ទាប់មកគាត់បាននិយាយអំពីបញ្ហារដ្ឋធម្មនុញ្ញថ្មី រួមទាំងសភាផងដែរ ដែលគាត់នៅពេលនោះនិយាយសថា “សភាមានអំណាចក្នុងការបង្កើតមាគ៌ានយោបាយ”។ ក៏ប៉ុន្តែដោយសារតែពេលវេលាខ្ញុំមើលដោយសង្ខេប ហើយលឿនបំផុតពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ ត្រង់ខ្មែរ ERN 00657445, បារាំងមានលេខ 00725799, អង់គ្លេសមានលេខ 00167814។

គាត់បានលើកឡើងដូចតទៅ “ដូចដែលលោកបានឃើញហើយ ក្រោមជំពូក៧ ស្ដីអំពីយុត្តិធម៍តុលាការគឺជារបស់ប្រជាជនធ្វើការដើម្បីការពារសេរីភាព និងយុត្តិធម៍របស់ប្រជាជន និងដាក់ទោសរាល់សកម្មភាពទាំងឡាយណាដែលប្រឆាំងនឹងរដ្ឋ និងប្រជាជន។ តុលាការនេះត្រូវបានបោះឆ្នោតជ្រើសតាំងដោយសភាតំណាងប្រជាជន”។

[០៩:៥១:២៧]

ហើយខ្ញុំរំលងប្រយោគមួយចំនួន។ បន្ទាប់មកនៅខាងក្រោម គាត់និយាយអំពីបញ្ហាបទល្មើសដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ពាក់ព័ន្ធទៅនឹងបញ្ហាការការពារប្រទេសជាតិ “យើងឃើញថាបញ្ហានេះគឺបែងចែកជាពីរប្រភេទ ពោលគឺសកម្មភាពដែលមានចរិតលក្ខណៈជាប្រព័ន្ធ និងគ្រោះថ្នាក់ នឹងត្រូវទទួលទោសក្នុងកម្រិតធ្ងន់បំផុត ហើយនិងសកម្មភាពកំហុសស្រាលនឹងត្រូវដោះស្រាយតាមរយៈការអប់រំ កសាងខ្លួនឡើងវិញនៅក្នុងក្របខ័ណ្ឌអង្គការរដ្ឋ និងនៅក្នុងក្របខ័ណ្ឌអង្គការប្រជាជន ដែលបញ្ហានេះពាក់ព័ន្ធនឹងបញ្ហាបទល្មើស”។

អត្ថបទចុងក្រោយដែលខ្ញុំចង់អាននៅក្នុងឯកសារនេះគឺខ្មែរ ERN 00657450, បារាំងមានលេខ 00725802, អង់គ្លេសមានលេខ 00167116។ អត្ថបទនេះគឺពាក់ព័ន្ធនឹងបញ្ហាសាសនានៅក្នុងរដ្ឋថ្មីនាសម័យនោះ។ ជំពូក១៥ មាត្រា២០ ចែងថា "ប្រជាជនយើងមានសិទ្ធិប្រកាន់ជំនឿសាសនាអ្វីក៏បានឲ្យខ្លួនពេញចិត្តនិងមានសិទ្ធិប្រកាន់ជំនឿសាសនាអ្វីក៏បាន។ នេះគឺជាសេរីភាពថ្មីនៃប្រជាជនយើង"។ ហើយវាក៏បានចែងផងដែរនៅក្នុងរដ្ឋធម្មនុញ្ញយើង "ជំហររបស់យើងមិនត្រូវអនុញ្ញាតឲ្យពួកចក្រពត្តិនិយមបរទេសណាមួយប្រើប្រាស់សាសនា ដើម្បីធ្វើវិទ្ធង្សនាមកលើយើងទេ យើងប្តេជ្ញាវាយប្រយុទ្ធពួកគេទោះបីពួកគេប្រើរូបភាពលាក់កំបាំងអ្វីក៏ដោយ។ ពួកចក្រពត្តិនិយមបន្តស្វែងរកមធ្យោបាយវាយប្រហារយើង ក្នុងចំណោមមធ្យោបាយទាំងនេះពួកគេប្រើសាសនាជារូបភាពលាក់បាំងមួយដើម្បីជ្រៀតខ្លួនចូលក្នុងប្រទេសយើង ដូច្នេះយើងគួរតែប្រឆាំងនឹងពួកគេ ទោះបីជាក្នុងកាលៈទេសៈណាក្តី"។

លោក លោកស្រីចៅក្រមជាទីគោរព! រដ្ឋធម្មនុញ្ញនេះគឺមាននៅក្នុងសំណុំរឿងឯកសារ E3/259 ដែលជារដ្ឋធម្មនុញ្ញយើងយកមកពិចារណារួមជាមួយនឹងរបាយការណ៍មួយនេះបាន។

[០៩:៥៣:៥២]

ឯកសារបន្ទាប់ដែលខ្ញុំសូមបង្ហាញនោះគឺថា ឯកសារនេះគឺត្រូវបានយកមកពិភាក្សាពីមុនរួចមកហើយ ដូច្នេះយើងខ្ញុំនឹងលើកឡើងដោយសង្ខេប ជាពិសេសអត្ថបទត្រង់ចំណុចដែលពាក់ព័ន្ធតួនាទីរបស់ ខៀវ សំផន។ អត្ថបទនេះគឺវាកំណត់ហេតុកិច្ចប្រជុំនៅតាមការងារមូលដ្ឋាន។ វាមិនបានបង្ហាញនៅក្នុងកំណត់ហេតុគណៈអចិន្ត្រៃយ៍នោះទេ ក៏ប៉ុន្តែនៅក្នុងពេលនោះគឺកិច្ចប្រជុំមានការចូលរួមដោយ ប៉ុល ពត, នួន ជា រួមទាំង ខៀវ សំផន និងកម្មាភិបាលផ្សេងទៀត។ ឯកសារនេះគឺ E3/232 ចុះថ្ងៃ០៨ ខែមីនា ឆ្នាំ៧៦។ មេដឹកនាំបានជួបពីរដងនាពេលនោះ ១) និយាយអំពីការផ្សាយអំពីការបោះឆ្នោត ហើយ ខៀវ សំផន បានចូលរួមកិច្ចប្រជុំនោះផងដែរ។ បន្ទាប់មកកិច្ចប្រជុំមួយទៀត ឯកសារមួយទៀតដែលយើងមើលនៅពេលនេះគឺការពិភាក្សានៅក្នុងឯកសារនោះ គឺផ្តោតសំខាន់លើការបោះឆ្នោតតែម្តង ហើយនិងបញ្ហាផ្សេងទៀតដែលយើងនឹងលើកឡើងដោយសង្ខេប ប្រសិនបើយើងខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះលើអេក្រង់ ទំព័រទី១ យើងឃើញមានវត្តមានអ្នកចូលរួម។ បុគ្គលដែលចូលរួមនៅក្នុងពេលនោះគឺថាលេខា ប៉ុល ពត, អនុលេខា នួន ជា និងសមមិត្ត ហែម ឬក៏ ខៀវ សំផន។ ជួរខាងក្រោមគឺសមមិត្ត ឌឿន ដែលនៅក្នុងភស្តុតាងហៅថាជា អតីតប្រធានមន្ទីរ៨៧០។

[០៩:៥៥:៣៥]

ប្រសិនបើយើងមើលទំព័រដំបូង លោក លោកស្រីចៅក្រមជាទីគោរព! កិច្ចប្រជុំទាំងអស់គឺចាប់ផ្តើមចេញអំពីសេចក្តីរាយការណ៍របស់សមមិត្ត ហែម។ កិច្ចប្រជុំបានលើកឡើងដូចតទៅ សេចក្តីរាយការណ៍របស់សមមិត្ត ហែម "ទី១ សមមិត្ត ហែម រាយការណ៍ជូនមូលដ្ឋានអំពីគោលការណ៍បោះឆ្នោតថ្ងៃទី២០ ខែមីនា ឆ្នាំ៧៦។ សំណួមពរនៃការបោះឆ្នោត វិធីបោះឆ្នោត លក្ខណៈផ្សេងៗដើម្បីឈរឈ្មោះជាតំណាង វិធីអប់រំឃោសនា។ល។" កំណត់ហេតុនេះក៏ក្នុងនោះរួមមានមតិយោបល់បញ្ជាក់បន្ថែមរបស់អង្គការផងដែរ។ ពាក់ព័ន្ធទៅនឹងគោលបំណងនៃឯកសារនេះ គឺថាក្រោយពីអនុម័តរដ្ឋធម្មនុញ្ញ និងនៅពេលដែលយើងមើលរបាយការណ៍របស់ ខៀវ សំផន ដែលយើងបានមើលអម្បាញ់មិញនោះ គឺបានបង្ហាញថា សភាមានអំណាចក្នុងការបង្កើតមាគ៌ានយោបាយ។

[០៩:៥៦:៤០]

អត្ថបទខាងក្រោមនេះ ត្រង់ខ្មែរ ERN 00017118, បារាំងមានលេខ 00233923, អង់គ្លេស 00182630 ដែលក្នុងនោះពាក់ព័ន្ធទៅនឹងបញ្ហាឃោសនា និងអប់រំដែលមានការលើកឡើងដូចខាងក្រោម។ សូមដកស្រង់ "បើមានគេសួរ យើងត្រូវពន្យល់ កុំច្រងេងច្រងាង កុំឲ្យឃើញថាយើងចង់បង្ក្រាប។ ទន្ទឹមនឹងនេះក៏កុំនិយាយលេងពីសភានៅមុខប្រជាជន ថាយើងបន្ទឹមបន្តំ ហើយសភាយើងគ្មានតម្លៃអី។ ការពិតនៅតែជាភារកិច្ចរបស់បក្សដដែល។

ឯកសារនេះផងដែរក៏វាពាក់ព័ន្ធ បង្ហាញពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន ដោយសារបញ្ហាផ្សេងទៀតគឺបានលើកឡើងនៅក្នុងកិច្ចប្រជុំនេះ ដែលក្នុងពេលនោះ ខៀវ សំផន បានចូលរួម។ បញ្ហាផ្សេងៗនោះ គឺបានរាយការណ៍ដោយអតីតលេខាតំបន់ចំនួនបីគឺ ៣០៣, ១០៦ និងតំបន់១០៣។ តំបន់ទាំងបីនេះគឺបានបង្កើតជាផ្នែកមួយនៃភូមិភាគឧត្តរ ដែលភូមិភាគឧត្តរនេះដឹកនាំដោយ កុយ ធួន ជាសមាជិករបស់គណៈមជ្ឈិម។

[០៩:៥៨:១៨]

យើងខ្ញុំនឹងលើកឡើងដោយសង្ខេបទៅលើបញ្ហានេះ ក៏ប៉ុន្តែដើម្បីឲ្យយើងដឹងខ្លះអំពីការរាយការណ៍នៅពេលនេះ គឺសូមមើលខ្មែរ ERN 00182630 វា-- សូមអធ្យាស្រ័យ គឺជាលេខ ERN ជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ គឺអង់គ្លេសមានលេខ 00017118, បារាំងមានលេខ 00233933 ពាក់ព័ន្ធទៅនឹងស្ថានភាពនៅមូលដ្ឋាន។ សភាពការណ៍នៅ៣០៣ សូមដកស្រង់សម្តី "សមមិត្ត ស្រេង រាយការណ៍ជូនអង្គការពីសកម្មភាពរបស់ពួក អាឿន និងគ្នាវា៣៤នាក់ ដែលកងទ័ពភាគចាប់ខ្លួនបានអស់

ហើយ”។ ចំណុចមួយទៀត “ពួក អាអ៊ុក អឿន ហៅ អ៊ុក ហុង ដែលប៉ុនប៉ងរត់ទៅវៀតណាមខាងត្បូង និងគ្នាវាបួនប្រាំនាក់ទៀត ហើយស្នើមតិណែនាំរបស់អង្គការ”។

សេចក្ដីសភាពការណ៍មួយទៀត ដែលនៅខាងក្រោមនេះគឺវាទាក់ទងសភាពការណ៍១០៦ ក៏បានលើកឡើងអំពីស្ថានភាពខ្មាំងក្រោមចំណុច ខ ផងដែរ។ ហើយនៅក្នុងទីនោះ នៅក្នុងនោះរបាយការណ៍បានលើកឡើងថា មិនមានខ្សែណាមួយត្រូវបានរកឃើញនៅថ្ងៃទី២៤ ខែកុម្ភៈ នោះទេ។ ដូច្នេះចំណុចទាំងអស់នេះគឺវាបានបង្ហាញថាជាការយោងអំពីការបោកគ្រាប់បែក ដែលបានកើតឡើងនៅខេត្តសៀមរាប។ ចំណុចនេះក៏បានលើកឡើងនៅក្នុងឯកសារ E3/1173។ ឯកសារនោះគឺជាការណែនាំរបស់មន្ទីរ៨៧០ ហើយខ្ញុំសូមកត់សម្គាល់នៅក្នុងនេះថា ឯកសារទាំងអស់នោះវាពាក់ព័ន្ធទៅនឹងមតិរបស់គណៈកម្មាធិការដែលថាការបោកគ្រាប់បែកទំនងរៀបចំដោយពួកចក្រពត្តិអាមេរិក។ នៅក្នុងកំណត់ហេតុគណៈអចិន្ត្រៃយ៍នេះ គឺថាយើងមើលឃើញថា មានការស៊ើបអង្កេតទៅលើបញ្ហាបោកគ្រាប់បែកនៅពេលនោះ។

[១០:០០:៤១]

សភាពការណ៍មួយទៀតគឺមកពីសភាពការណ៍១០៣ នៅ១០៣ ហើយសមមិត្ត ហង់ បានរាយ-ការណ៍ថា នៅចុងក្រោយដូចតទៅ “ចំណែកនៅផ្នែកខាងក្រោយនោះគឺថា គ្រាប់ផ្សេងៗគឺវាដូចនៅតំបន់៣០៣ នៅកំពង់ឆ្នាំង។ នៅក្នុងខែមករា ប្រហែលជិត១០០នាក់ត្រូវបានចាប់ខ្លួន។ អង្គការ បន្ទាប់មកបានផ្ដល់ការណែនាំបន្ថែម”។ ដោយសារតែពេលវេលារបស់យើង ខ្ញុំសូមរំលង ជាពិសេសឯកសារទាំងអស់នេះបានបង្ហាញនៅចំពោះមុខ ដេវីដ ឆេនដ័ល័រ រួចមកហើយ។

ឯកសារមួយទៀតនោះគឺថា ទាក់ទងទៅនឹងទិដ្ឋភាពមួយនៃឯកសារនេះ គឺវាមានភាពពាក់ព័ន្ធ។ ឯកសារនេះគឺវាបានបង្ហាញអំពីវត្តមានចូលរួម ហើយនិងជោគវាសនារបស់អ្នកដែលចូលរួម។ យើងបានឃើញរួចមកហើយថាកិច្ចប្រជុំនេះ ចូលរួមដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន។ អ្នកដែលចូលរួមផ្សេងទៀតនោះមានសមមិត្ត ឌឿន ជាការពិតហៅមានឈ្មោះថា ស៊ឿ វ៉ាស៊ី ជាប្រធានខាងផ្នែកនយោបាយនៅមន្ទីរ៨៧០។ ឌឿន ត្រូវបានបោសសម្អាត។ ហើយចម្លើយសារភាពគឺ ចម្លើយសារភាពនោះលេខ E3/1625 ចុះថ្ងៃ១៩ ខែកុម្ភៈ ៧៧ ប្រហែលជិត១ឆ្នាំក្រោយពេលប្រជុំនោះ។

សមមិត្តចូលរួមមួយទៀតនោះគឺថា សមមិត្ត ស្រេង ជាអនុលេខា ដូចដែលបានឃើញនៅក្នុងរបាយការណ៍មុន។ គាត់ក៏ត្រូវបានបោសសម្អាតផងដែរ។ ចម្លើយសារភាពនោះគឺថាឃើញមាន E3/2795 ហើយនិង E3/135 ឈ្មោះរបស់គាត់គឺ ឆាង ហៅ ស្រេង -- ឈូក ឆាង ហៅ ស្រេង។ អ្នក

ចូលរួមមួយទៀតគឺសមមិត្ត ហង់ ដែលយើងឃើញពីមុនថារាយការណ៍អំពីតំបន់១០៣។ បុគ្គលរូបនេះក៏ត្រូវបានសម្លាប់ចោលផងដែរ។ នៅក្នុងចម្លើយសារភាពមាននៅក្នុង E3/2470 ឈ្មោះពេញគឺ ប៊ូ ផាត់ ហៅ ហង់។ ចម្លើយសារភាពចុះថ្ងៃទី១៦ ខែ១, ៧៨។ ហើយសមមិត្តចូលរួមចុងក្រោយនោះគឺសមមិត្ត សុត។ យើងឃើញក្នុងចម្លើយសារភាពផងដែរ ដែលជាអ្នកធ្វើកំណត់ហេតុ។ គាត់ក៏ត្រូវបានសម្លាប់ចោលផងដែរ។ នៅចម្លើយសារភាពឃើញនៅក្នុងឯកសារ E3/3702 ឈ្មោះ ពេញ គឺ អោគ ឆាយ ហៅ ទូច។ ឯកសារចុះថ្ងៃទី៣០ -- ចម្លើយសារភាពចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧។

[១០:០៣:៥៧]

ខ្ញុំពិនិត្យមើលឃើញថា ខ្ញុំបានទុកបុគ្គលម្នាក់មុនសមមិត្ត ទូច។ សមមិត្ត សុត ក៏ជាអ្នករាយ-ការណ៍នោះផងដែរ។ ជាថ្មីម្តងទៀត គាត់ក៏ត្រូវបានគេបោសសម្អាត។ ចម្លើយសារភាពនៅ ស-២១ គឺ E3/1754។ គាត់ឈ្មោះ ប៉ា ផល ហៅ សុត គឺចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ៧៧ និងកាលបរិច្ឆេទ។ គឺឯកសារពាក់ព័ន្ធទៀត គឺថាលោក លោកស្រីចៅក្រមតាមពិតនោះគឺ ដែលទាក់ទងទៅនឹងបុគ្គលនេះ គឺម្នាក់ៗដែលចូលរួមក្នុងកិច្ចប្រជុំនោះ ជា -- ដូចដែលកំណត់ហេតុបញ្ជាក់ជាមន្ត្រីជាន់ខ្ពស់ លើកលែងតែ ប៉ុល ពត, នួន ជា និង ខៀវ សំផន ក្រៅពីហ្នឹងត្រូវបានគេយកទៅសម្លាប់នៅ ស-២១ ទាំងអស់។

ដូចដែលយើងចូលទៅឯកសារមួយទៀត គឺជាឯកសារ E3/197។ យើងបន្តពិនិត្យមើលតួនាទីដែលគាត់បានធ្វើ ហើយនិងឯកសារអ្វីដែលនិយាយអំពីតួនាទីរបស់លោក ខៀវ សំផន នៅពេលនោះ។ នៅក្នុងពេលសម្តេច នរោត្តម សីហនុ បានលាលែងពីតំណែងទៅនោះ។ ឯកសារនេះ គឺជាកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ មានកិច្ចប្រជុំទាក់ទងអំពីរណសិរ្ស។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ យើងបាននៅក្នុងនេះ គឺរួចហើយ ហើយយើងនឹងទៅមុខឲ្យបានលឿន។ ទំព័រទី១ នៃឯកសារនេះ គឺប្រធានបទតែមួយ គឺនិយាយអំពី "សីហនុ លាលែងពីតំណែង" គឺនៅក្នុងចំណុចទី១ គឺរបាយការណ៍របស់សមមិត្ត ហែម ទៅគណៈ អចិន្ត្រៃយ៍អំពីការលាលែងពីតំណែងនេះ។

មានមតិមួយចំនួនដែលបានសម្តែងនៅទីនេះ ទាក់ទងទៅនឹងអំពីគោលបំណង ហើយនិងការលាលែងរបស់សម្តេច នរោត្តម សីហនុ នៅកាលនោះ ហើយខ្ញុំនឹងដកស្រង់ដោយសង្ខេបទេ។ ហើយផ្នែកទី២ គឺមតិរបស់អង្គការ។

[១០:០៦:២០]

"ចំណុចទី១(ក) គឺពិនិត្យមើលមូលហេតុនៃការលាលែង គឺថាមតិ វណ្ណៈជាកំពូលហ្នឹងគឺមាន

ទំនាស់រវាងៗរវាងគាត់និងក្រុមគ្រួសារគាត់ និងអង្គការ។ គាត់មិនអាចរស់នៅទេ កន្លងមកគាត់រស់ នៅបានជាយុទ្ធវិធីទេ ដោយយើងធ្វើដំណើរការជាយុទ្ធសាស្ត្រ យុទ្ធវិធីទៅ គាត់ចេះតែនៅបានជាបណ្តើរៗ សីហនុ មិនមែនជា មិនមែនលាឈប់តែម្តងនេះទេ”។ ហើយនៅកថាខណ្ឌខាងក្រោមមួយទៀត មានមតិយោបល់មួយទៀត ដែលរៀបរាប់អំពីការលាលែងនេះ។ ប៉ុន្តែខ្ញុំសូមអនុញ្ញាតទៅមុខ ដោយសារពេលវេលាខើចខ្លី គឺថានិយាយអំពីផ្នែកមួយនៃកិច្ចប្រជុំដែលពិភាក្សានៅក្នុងពេលល្ងាច នៃថ្ងៃទី១៣ ខែមីនា។ ខ្មែរ ERN 00000747, បារាំង 00334963 ហើយអង់គ្លេស ERN 00182640។ ផ្នែកទី៣ នៃរបាយការណ៍នេះនិយាយថា មតិរបស់អង្គការ អង្គប្រជុំយប់ថ្ងៃទី១៣។ សូមដកស្រង់ “សមមិត្ត ហែម រាយការណ៍ជូនគណៈអចិន្ត្រៃយ៍អំពីបញ្ហា សីហនុ គាត់សម្រេចសុំលាលែងពីតំណែងដាច់ខាត។ គាត់បញ្ជាក់ថា ឲ្យអង្គការអាណិតគាត់ ហើយគាត់អាចនឹងសម្លេង សំតះ ឲ្យតែឲ្យគាត់ឈប់”។

បន្ទាប់មក មានមតិទាក់ទងទៅនឹងមតិរបស់អង្គការ អំ! លេខា សមមិត្តលេខា។ បាទ នៅក្នុងចំណុចទី៣ នេះដែរ “បញ្ជូនព័ត៌មានឲ្យក្រុមគ្រួសារគាត់ឲ្យបានឆាប់ ដើម្បីឲ្យគាត់មកទាន់បុណ្យឯករាជ្យនៅពេលបុណ្យចូលឆ្នាំ។ យើងដោះស្រាយបញ្ហានេះឲ្យស្អាត យើងត្រូវដោះស្រាយយ៉ាងនេះ ដើម្បីចំណេញបដិវត្តន៍”។

[១០:០៨:៣៩]

ផ្នែកមួយទៀត មុននឹងយើងបញ្ចប់ឯកសារនេះ គឺនៅខ្មែរ ERN 00000748, អង់គ្លេស ERN 00182641, បារាំង ERN 003334963 (ស៊ីក)។

កំណត់ខាងក្រោមនេះ គឺទាក់ទងទៅនឹងសម្តេច សីហនុ ដដែល “យើងចាត់ទុកគាត់ជាឥស្សរជន យើងមិនសម្លាប់គាត់ទេ ប៉ុន្តែចំពោះប្រជាជាតិ និងប្រជាជន គាត់ក៏មានទោសធ្ងន់ ក្នុងឋានៈជាអ្នកកាប់សម្លាប់ប្រជាជន។ ដូច្នេះ ការសម្រេចរបស់យើងសមហេតុផលគ្រប់យ៉ាង។ យើងនៅតែរក្សាគាត់ តែបើគាត់នៅតែរើបម្រះ យើងត្រូវបញ្ចប់”។ ហើយផ្នែកបន្ទាប់ទៀត “យើងត្រូវតែបញ្ចប់សក្តិភូមិបែបនេះ។ ល្បែងអុក គឺជិតដល់ចំណុចចុងក្រោយហើយ។ របបសក្តិភូមិក៏ត្រូវបញ្ចប់ទាំងស្រុង កម្ទេច និងគាស់រំលើងជាស្ថាពរ។ សម្តេចដែលមានមក២.០០០ឆ្នាំហើយ ទីចុងបំផុត ត្រូវស្អាត។ យើងគ្មានផ្លូវអីចេញក្រៅនេះទេ”។

របាយការណ៍បន្ទាប់ទៀត ដែលយើងខ្ញុំនឹងដាក់បង្ហាញផងដែរនោះ ដាក់ដេញដោលចំពោះអង្គជំនុំជម្រះថ្ងៃនេះនោះ គឺខ្សែវីដេអូ គឺឯកសារ D232/110.1.1.42R ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៥ គឺ

បន្ទាប់ពីការលាលែងរបស់សម្តេច សីហនុ ដែរ គឺមានសេចក្ដីដកស្រង់សង្ខេបដែលសម្តេច នរោត្តម សីហនុ ព្រះអង្គឯងរៀបរាប់អំពីជំហាររបស់ព្រះអង្គទាក់ទងនឹងការដកខ្លួន ឬក៏នៅក្នុងឋានៈជាប្រមុខរដ្ឋនៃកាលនោះ។

សូមអនុញ្ញាតពីលោកប្រធាន សូមឲ្យខាងប្រព័ន្ធសោតទស្សន៍ចាក់ផ្សាយវីដេអូនេះ ជូនអង្គជំនុំជម្រះ និងសាធារណជន ភាគីបានជ្រាប។ សូមអនុញ្ញាតបាទ!

[១០:១១:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

បុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សាយវីដេអូនៅលើអេក្រង់ទូរទស្សន៍ តាមការស្នើសុំរបស់ខាងតំណាងសហព្រះរាជអាជ្ញា!

[១០:១១:៣៣]

*(ការបង្ហាញឯកសារជាសំឡេង)*

[១០:១២:២១]

**ប្រធានអង្គជំនុំ៖**

ម៉េចអត់មានសំឡេង?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនប្រាកដទេលោកប្រធាន ប្រហែលជាបញ្ហាបច្ចេកទេសទេមើលទៅ។ បាទ មានសំឡេងសម្រាប់វីដេអូនេះបាទ។ វីដេអូនេះមានសំឡេងលោកប្រធាន ដូច្នេះគឺថាយើងនឹងចាក់វីដេអូនេះបាទ។

[១០:១២:៤៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*នៅកម្ពុជាប្រមុខរដ្ឋសម្តេច សីហនុ បានសម្រេចលាលែងពីមុខតំណែង។ នរោត្តម សីហនុ ដែលបាននិរទេសព្រះកាយនៅទីក្រុងប៉េកាំងអស់រយៈពេល៥ឆ្នាំ បានក្លាយជាប្រមុខកម្ពុជាជាថ្មីម្តងទៀត។ ឥឡូវនេះព្រះអង្គបានសម្រេចព្រះទ័យចាកចេញពីអំណាច។ ហើយការសម្រេចរបស់ព្រះអង្គទំនងជាត្រូវបានទទួលយក។ អ្នកសម្លាស៖ ព្រះអង្គមានការភ័យខ្លាច ហើយព្រះអង្គមានបន្ទូលដោយផ្ទាល់ថា ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គត្រៀមព្រះកាយក្នុងការបោះបង់ចោលអំណាចដែលគ្រួសាររបស់ព្រះអង្គ*

*បានកាន់កាប់អស់រយៈពេលជាង ២.០០០ឆ្នាំមកហើយ តើពិតមែនទេ? ខ្ញុំពិតជាចង់ចាកចេញនៅពេលផលប្រយោជន៍នៃប្រទេសខ្ញុំ តម្រូវឲ្យខ្ញុំលាលែងពីមុខតំណែងជាប្រមុខរដ្ឋ ប៉ុន្តែខ្ញុំមិនចង់ឲ្យធាក់ពីក្រោយខ្ញុំ ខ្ញុំមិនចង់ឲ្យគេបណ្ដេញខ្ញុំ ខណៈដែលខ្ញុំមិនបានក្បត់ប្រទេសជាតិខ្ញុំនោះទេ។ ខ្ញុំមិនទទួលយកករណីនេះទេ ហេតុនេះហើយបានជាខ្ញុំតស៊ូ។ ខ្ញុំតស៊ូហើយខ្ញុំឈ្នះ ពីព្រោះខ្ញុំចូលចិត្តការតស៊ូ។ ខ្ញុំគឺដូចជាលោកកាស្ត្រូ ក្លេស ដែលចូលចិត្តប្រដាល់ ហើយខ្ញុំៗចូលចិត្តការតស៊ូ។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:១៤:០០]

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោក លោកស្រីចៅក្រម ការលាលែងរបស់ព្រះអង្គត្រូវបានធ្វើជាសាធារណៈ ដើម្បីសាធារណជននោះ គឺថាយើងពិនិត្យឃើញថា ការទទួលយកការលាលែងនេះគឺជាបញ្ហាដែលទាក់ទងទៅនឹងលោក ខៀវ សំផន ឯកសារ E3/275 ជាសេចក្ដីដកស្រង់ចេញមកពីព័ត៌មាន សេវាផ្សាយព័ត៌មានបរទេស ហើយយើងមានតែអត្ថបទជាភាសាអង់គ្លេសទេ សូមអនុញ្ញាតឲ្យមានការបកប្រែ។ ដើម្បីកំណត់ត្រាតុលាការ យើងបញ្ជាក់ ERN ជាភាសាអង់គ្លេសគឺ 00167605។ សូមកត់សម្គាល់ក្នុងកំណត់ត្រាតុលាការ នេះជាឯកសារជាការទទួលយកដែល ខៀវ សំផន ចេញក្នុងនាមអ្វីដែលកាលនោះ គឺជារដ្ឋាភិបាល រាជរដ្ឋាភិបាលរួបរួមជាតិនៅឡើយ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៦។

ឯកសារបន្ទាប់នោះគឺ ទាក់ទងទៅនឹងសកម្មភាពរបស់ ខៀវ សំផន ទាក់ទងទៅនឹងការបង្កើតរដ្ឋថ្មី។ គឺឯកសារ E3/165 នេះជាឯកសារមួយទៀតដែលបានពិចារណាលើកមុនហើយ ជាពិសេសនៅក្នុងការបង្ហាញអំពីរចនាសម្ព័ន្ធអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ។ នេះត្រូវបានពិភាក្សានៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ គឺឯកសារនិយាយថា "អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា នៅថ្ងៃ១១, ១៣ ខែមេសា ឆ្នាំ១៩៧៦"។ ជាឯកសារដ៏វែង ហើយយើងនឹងមើលតែផ្នែកតែមួយតែប៉ុណ្ណោះ ជម្រាបតុលាការ ដែលនិយាយអំពីសុន្ទរកថាប្រកាសដោយលោក ខៀវ សំផន។ សុន្ទរកថានៅខ្មែរ ERN ហ្នឹងគឺ 00053610, បារាំង ERN 00301338 ហើយអង់គ្លេស ERN 00184052។

[១០:១៦:២៥]

ហើយខ្ញុំនិយាយដោយសង្ខេបអំពីបញ្ហាខាងដើមនេះ លោក ខៀវ សំផន បាននិយាយដូចខាង

ក្រោមនេះ សូមដកស្រង់ "ថ្ងៃនេះជាថ្ងៃមហាជោគជ័យដោយមិត្តតំណាងបានអញ្ជើញមក គឺយើងបញ្ចប់នូវសក្តិភូមិទាំងថ្មីទាំងចាស់ គ្រប់ផ្នែកទាំងអស់ ទាំងនយោបាយ ទាំងយោធា សេដ្ឋកិច្ច វប្បធម៌ ទូទាំងកម្ពុជាទាំងមូល។ នៅក្នុងសម័យនោះយើងឲ្យមានព្រលឹងជាតិ ហើយលក្ខណៈពិតរបស់ប្រជាជនយើង ទស្សនៈ គោលជំហរ ច្បាប់ និងទំនៀមទម្លាប់សេដ្ឋកិច្ច កិច្ចការសង្គម ជីវភាពរស់នៅ ហើយអ្វីៗទាំងអស់ អ្វីដែលប្រតិកិរិយាពុករលួយរបស់ចក្រពត្តិនិយម អាណានិគមនិយម ហើយនិងសង្គមគាបសង្កត់ដែលគាបសង្កត់ជាតិយើងទាំងមូលនោះ"។

ហើយគាត់ពិភាក្សាបន្តទៅទៀតអំពីអនាគត អំពីការបង្កើតនូវសង្គមថ្មី សម្រាប់ទៅអនាគតរបស់គាត់នោះ។ សូមដកស្រង់ "យើងឃើញយ៉ាងច្បាស់អំពីការជោគជ័យរបស់ពលករ កសិករ របស់កងទ័ពបដិវត្តន៍របស់យើង នៅក្នុងក្រោមការដឹកនាំដ៏ភ្លឺស្វាងអស្ចារ្យរបស់អង្គការបដិវត្តន៍យើង។ យើងឃើញច្បាស់អំពីតម្លៃដ៏ថ្លៃថ្លាបំផុតរបស់រដ្ឋធម្មនុញ្ញ និងសភាយើង ដែលចេញពីការតស៊ូពីឈាមស្រស់របស់ប្រជាជនយើង។ ដូច្នេះសភាយើងមិនមែនកើតឡើងដោយឧបាយកលបោះឆ្នោត គឺដោយកលល្បិច កែច្បាប់ទម្លាប់ ដោយវិធីប្រជាជនជាតិផុតសន្លឹម បន្លឹមបន្លំ ឬដោយឃោសនាបោកប្រាស់នោះទេ ហើយក៏មិនមែនកើតឡើងដោយសារអង្វរចុះញ៉ម ចំពោះចក្រពត្តិនិយម អាណានិគមនិយមនោះដែរ"។

នេះគឺជាសម្តីរបស់លោក ខៀវ សំផន ដែលនិយាយនៅក្នុងការប្រជុំដ៏សំខាន់ បញ្ជាក់អំពីការបង្កើតរដ្ឋាភិបាលថ្មីនោះ។

[១០:១៨:៤៨]

នៅក្នុងឯកសារបន្ទាប់ ហើយខ្ញុំនឹងអានខ្មែរ ERN 00053614 ដល់ 5, បារាំង ERN 00301341 ដល់ 2, អង់គ្លេស ERN 00184054 ដល់ 5 ដែលលោក ខៀវ សំផន បានពិភាក្សាអំពីភាពចាំបាច់នៃការប្រុងប្រយ័ត្នបដិវត្តន៍នៅក្នុងសង្គមថ្មីរបស់គាត់។ "យើងបន្តការពង្រឹងឯកភាពឲ្យបានរឹងមាំទូទាំងប្រទេស និងប្រជាជនរបស់យើង ហើយនិងបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់គ្រប់ពេលវេលា ដើម្បីធ្វើការវាយប្រយុទ្ធគ្រប់សមរភូមិ ដើម្បីផលិត ឬក៏បង្កបង្កើនផល"។

ខ្ញុំមានពេលខ្លី ខ្ញុំសូមផ្អាកត្រឹមនេះ ប៉ុន្តែគឺមានការបញ្ជាក់ពីខ្លឹមសារជាច្រើនទាក់ទងទៅនឹងអំពីនយោបាយរបស់រដ្ឋនៃបក្សកុម្មុយនីស្តកម្ពុជា។ អ្វីដែលសំខាន់នៅទីនេះ គឺសុន្ទរកថានេះគឺជាការទទួលស្គាល់ដោយសមាជិកតំណាងរាស្ត្រជាច្រើន ជាតំណាងឧស្សាហកម្ម តំណាងមកពីពលការិនី ហើយតំណាងកសិករមកពីភូមិភាគនិរតី មកពីសៀមរាប តំបន់សៀមរាបជាដើម ហើយនៅទីបំផុតគឺតំណាង

របស់កងទ័ពបដិវត្តន៍កម្ពុជា។ តាមពិតដូចដែលខ្ញុំបានជម្រាបគឺថា សហសេវិករបស់ខ្ញុំ គឺនៅថ្ងៃទី១០ តុលា ឆ្នាំ២០១២ គឺនៅក្នុងឯកសារនេះ ឃើញអំពីការតែងតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងសភាតំណាងប្រជាជនដែលដឹកនាំដោយលោក នួន ជា នោះផងដែរ។ ហើយនិងគណៈប្រធានរដ្ឋដឹកនាំដោយលោក ខៀវ សំផន ហើយរដ្ឋទាំងមូលដឹកនាំដោយ នួន ជា ហើយក្រសួងការបរទេសដឹកនាំដោយលោក អៀង សារី។

ឯកសារនោះក៏មាននិយាយអំពីសេចក្ដីសម្រេចក្នុងការទទួលយកសំណើសុំលាលែង សុំចូលនិវត្តន៍របស់សម្ដេច នរោត្តម សីហនុ ដែរ គឺជាសំណើសុំចូលនិវត្តន៍របស់រដ្ឋាភិបាលពីមុននោះ។ សំណើទាំងអស់នោះគឺមានការផ្ដល់ការយល់ស្របនៅខ្មែរ ERN 00053633 ហើយបន្ទាប់ទៅទៀតបារាំង ERN 00301353 ហើយតទៅទៀត ហើយអង់គ្លេស ERN 00184067 ហើយនិងទំព័រតទៅទៀត។

[១០:២១:៤២]

ឯកសារបន្ទាប់នេះគឺពាក់ព័ន្ធអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងដំណើរការនេះ គឺជាក្រមជាភាសាខ្មែរហៅថាក្រមនោះ គឺនៅក្នុងឯកសារ E3/260 គឺជាក្រមនិយាយអំពីការកំណត់របៀបធ្វើការងាររបស់តំណាងប្រជាជនកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា។

ខ្ញុំនឹងពិនិត្យមើលដោយសង្ខេប ហើយខ្ញុំនឹងមើលមាត្រាមួយ គឺមាត្រា៦ និយាយដូចខាងក្រោមនេះ៖

"ប្រជាជនកម្ពុជា ហើយនិងតំណាងប្រជាជនត្រូវមានសិទ្ធិទាំងស្រុង ក្នុងការកំណត់បញ្ហាសំខាន់ៗ" នេះគឺជាក្រមដែលចេញដោយ ខៀវ សំផន គឺនៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៦ ក្នុងសមត្ថភាពជាប្រធានគណៈប្រធានរដ្ឋ។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតចូលដោយសង្ខេប ពិនិត្យមើលបញ្ហាដែលនិយាយពីដំណើររបស់ ខៀវ សំផន ទៅជនបទនានា ក្នុងតួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ដែលគាត់មានលទ្ធភាពធ្វើទស្សនកិច្ចទៅការដ្ឋានការងារ និងសហករណ៍នានា ហើយនិងទីកន្លែងមួយចំនួនទៀត។ របាយការណ៍មួយអំពីបញ្ហានេះ យើងអាចរកឃើញនៅក្នុងឯកសារ E3/273 ជាសេចក្ដីដកស្រង់អំពីប្រភពឯកសារហៅថា ហ្វីប៊ីស គឺសេវាផ្សាយព័ត៌មានអន្តរជាតិ។ ហើយយើងមិនមានឯកសារខ្មែរទេ។ បារាំង ERN 00275804 ហើយ 00167844 ជាភាសាអង់គ្លេស។ មិនសុំអនុញ្ញាតបង្ហាញឯកសារទេ ខ្ញុំជម្រាបជូនតុលាការអំពីរបៀបទស្សនកិច្ច ៣ថ្ងៃទៅភូមិភាគឧត្តរជាមួយសម្ដេច នរោត្តម សីហនុ ដែលធ្វើឡើងនៅ

ថ្ងៃ -- នៅខែមករា ឆ្នាំ១៩៧៦ បន្ទាប់មកគឺអមដំណើរដោយសមាជិកនៃរដ្ឋាភិបាល ហើយនិងលោក ខៀវ សំផន ផងដែរក្នុងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បាទដែលលោក ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រីនៅពេលនោះ។ ដូច្នេះវាមានការពាក់ព័ន្ធ ពីព្រោះថាមានកត់ត្រាអំពីដំណើរទស្សនកិច្ចរបស់ ខៀវ សំផន ទៅជនបទ។

[១០:២៤:៤៥]

លោកប្រធាន ខ្ញុំសូមអនុញ្ញាត យើងមានឯកសារពីរ -- ឯកសារវីដេអូពីរ ដែលកត់ត្រាជាសំខាន់នោះ សេចក្តីថ្លែងការណ៍របស់សម្តេច នរោត្តម សីហនុ ដែលរៀបរាប់អំពីព្រះអង្គបានយាងត្រឡប់មកកម្ពុជា ហើយព្រះរាជដំណើររបស់ព្រះអង្គទៅសហករណ៍ ហើយព្រះអង្គបានធ្វើការរៀបរាប់ពីអ្វីដែលព្រះអង្គបានទតឃើញនៅទីនោះ នាកាលនោះ។ វីដេអូទី១ គឺ D299.1.42R, ឯកសារទី២ គឺ D108/32.2R។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន លោកស្រីចៅក្រម ឲ្យខាងសោតទស្សន៍ដើម្បីចាក់ផ្សាយវីដេអូនេះ ហើយនិងមានផ្នែកពីរនៃវីដេអូនេះ គឺទី១ គឺ ហេចស៍ (H) បាទ គឺសរុបពេលទៅគឺថា ៤នាទី-- ៧៤សឹហ្កុង។ បាទ សុំការអនុញ្ញាតនៅពេលនេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អ្នកបច្ចេកទេសខាងសោតទស្សន៍ចាក់ផ្សាយវីដេអូលើអេក្រង់ទូរទស្សន៍តាមការស្នើសុំឲ្យតំណាងសហព្រះរាជអាជ្ញា។

[១០:២៦:២៩]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ប៉ុល ពត (គ្មានការបកប្រែ)... ជាដំបូងនៅឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៦ ខ្ញុំជាប្រមុខរដ្ឋ ខ្ញុំធ្វើដំណើរនៅទូទាំងប្រទេសកម្ពុជាជាមួយលោក ខៀវ សំផន។ បាទ ខ្ញុំឃើញមានជំរំឃុំខ្លួនគេធ្វើការទាំងថ្ងៃទាំងយប់នៅពេលព្រះចន្ទរះគេមិនអាចដេក គឺគេមិនអនុញ្ញាតឲ្យដេក គឺគេត្រូវធ្វើការ។ ខ្ញុំឃើញអ្វីៗដែលប្រជាជនហូប គឺមិនមានបាយគ្រប់គ្រាន់ទេ គេលាយជាមួយពោត និងអ្វីៗជាមួយសណ្តែក ហើយជាមួយស្លឹកឈើ គេអាចនឹងលាយដើមចេកផងដែរ។ របបអាហារគឺអាក្រក់ណាស់។ នៅឆ្នាំ១៩៧៦ ខៀវ សំផន ធ្វើជាប្រមុខរដ្ឋ ហើយទ្រង់ សីហនុ ត្រូវបានឃុំខ្លួន។ តើព្រះអង្គអាចរួចពីរបបនេះដូចម្តេច? សីហនុ បានប្រកាសដូចតទៅនេះ៖ ហេតុអ្វី? ពីព្រោះថាប្រធាន ម៉ៅ សេទុង ហើយ ជូ អេនឡាយ ប្រាប់ខ្មែរក្រហម មេខ្មែរក្រហម ប៉ុល ពត និង ខៀវ សំផន ថានៅខែកញ្ញា ឆ្នាំ១៩៧៥ គឺថា*

*សីហនុ និងក្រុមគ្រួសារមិនត្រូវគេសម្លាប់នោះទេ គេមិនសម្លាប់ សីហនុ ព្រះជាយានិងកូន ព្រះរាជបុត្រនោះទេ។ យើង មានតែពួកយើងប៉ុណ្ណេះដែលរួចរស់ពីរបបនោះ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:២៨:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ហើយផ្នែកទី២ ជាវីដេអូ គឺថា ប្រហែលជា២មីនុតប៉ុណ្ណោះទេលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អ្នកបច្ចេកទេសសោតទស្សន៍អនុវត្តដាក់បង្ហាញនៅលើអេក្រង់ទូរទស្សន៍។

[១០:២៩:១៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“ខ្ញុំមិនបានឃើញវាលពិឃាតទេ។ ជាការពិត ហើយខ្ញុំក៏ជាអ្នកទោសរបស់ខ្មែរក្រហមនៅក្នុងរាជវាំងដែរ។ ខ្ញុំត្រូវបានកាត់ផ្តាច់ទាំងស្រុងពីគេ។ ខ្ញុំបានឃើញបុរសតែម្នាក់គឺ ខៀវ សំផន ពីពេលមួយទៅពេលមួយ គាត់បានជួបខ្ញុំនៅរាជវាំង គ្រាន់តែនិយាយថា សួស្តី អ្នកឯងសុខសប្បាយទេ។ ហើយខ្ញុំបានព្យាយាមការអនុញ្ញាតពីគាត់ និងពី ប៉ុល ពត ដើម្បីឲ្យ ដើម្បីមានឱកាសខួបកំណើត ឬក៏ខួប ទិវាគម្រប់ខួប ដើម្បីឲ្យកូនខ្ញុំ ឬក៏ចៅខ្ញុំបានជួបជុំ។ គាត់និយាយថា ទេៗៗ ឥឡូវនេះពួកគេនៅឆ្ងាយពីភ្នំពេញណាស់ ពួកគេមានសុខភាពល្អ ប៉ុន្តែកុំៗមានជីវិតគ្រួសារតទៅទៀតអី ពីព្រោះឥឡូវនេះជាកុម្មុយនីស្តថ្មី យើងត្រូវតែគិតអំពីប្រទេស អំពីមាតុភូមិតែប៉ុណ្ណោះ មិនត្រូវគិតក្រុមគ្រួសារអីទៀតទេ។ នេះអ្វីដែលគេប្រាប់ខ្ញុំ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៣០:៣៨]

លោក លោកស្រីចៅក្រម លោកប្រធាន ប្រធានបទដែលខ្ញុំសូមអនុញ្ញាតចូលទៅដល់នោះ គឺជាសុន្ទរកថាដែល ខៀវ សំផន បានធ្វើនៅក្នុង -- ចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដោយសារខ្ញុំមើលពេលទៅគឺប្រហែលជាអាចនឹងសមស្រប លោកប្រធានអាចនឹងប្រកាសសម្រាកសម្រាប់ពេលព្រឹកនេះ ឬដូចម្តេចបាទ។

សុន្ទរកថាទី១ ដែលថ្លែងឡើងដោយ ខៀវ សំផន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ៧៥។ សុន្ទរកថា

នេះគឺថ្លែងឡើង ៤ថ្ងៃក្រោយពីបែកទីក្រុងភ្នំពេញ ដូច្នេះរយៈពេលហ្នឹងគឺថាវាពាក់ព័ន្ធនៅក្នុងពេលវេលារបស់យើង។ សុន្ទរកថានេះគឺឃើញមានដកស្រង់នៅក្នុងឯកសារ ហ្វីប៊ីស ឯកសារ E3/118, ERN ជាភាសាអង់គ្លេសគឺ 00166994 រហូតទៅដល់ 00166996 យើងខ្ញុំបានស្នើសុំឲ្យមានការបកប្រែជាភាសាខ្មែរ និងភាសាបារាំងរួចមកហើយ។ ដូច្នេះយើងខ្ញុំថាគិត -- យើងខ្ញុំយល់ថានឹងមានឯកសារជាភាសាខ្មែរ និងបារាំងក្នុងពេលឆាប់ៗនេះ។ ខ្ញុំនឹងអានដោយសង្ខេប អត្ថបទចំនួនពីរនៅក្នុងសុន្ទរកថានេះ។ មានចំណងជើងថា "សារជោគ -- សារអបអរសាទរដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងរដ្ឋាភិបាលបង្រួបបង្រួមជាតិ បានចុះផ្សាយនៅក្នុងវិទ្យុផ្សាយទីក្រុងភ្នំពេញថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥"។ នេះគឺជាអ្វីដែលសុន្ទរកថានេះបានលើកឡើង សូមដកស្រង់សម្ដី "នេះគឺជាជាតិជ័យជម្នះប្រវត្តិសាស្ត្រនៃប្រជាជន និងជាតិរបស់យើង។ ជាតិរបស់យើងទាំងមូលប្រជាជនរបស់យើង និងកងទ័ពរំដោះប្រជាជនកម្ពុជា រួមទាំងប្រជាជននៅក្នុងពិភពលោកនៅប្រទេស ដែលជាមិត្តរបស់យើងទាំងជិតទាំងឆ្ងាយ គឺស្វាគមន៍នូវជ័យជម្នះដ៏មហាអស្ចារ្យនេះ។ គេបានបើកនូវផ្លូវដែលក្លាហាន និងថ្លៃថ្លាមួយដែលអបអរប្រជាជន និងកងទ័ពរំដោះរបស់យើងក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងសត្រូវ ដោយខិតខំទៅលើបញ្ហាយោធា នយោបាយ សេដ្ឋកិច្ច ហើយយើងក៏បានទទួលជោគជ័យក្នុងការបំផ្លិចបំផ្លាញខ្មាំងរបស់យើង ហើយបានវាយខ្មាំងរបស់យើងទាំងផ្នែកយោធា នយោបាយ សេដ្ឋកិច្ច និងកម្លាំងស្បៀងអាហារ និងស្រូវរហូតទៅដល់ខ្មាំងយើងលែងតទល់បាន។ ចំណុចចុងក្រោយខ្មាំងរបស់យើងស្លាប់ទាំងអស់"។

[១០:៣៤:២១]

អត្ថបទមួយទៀតដែលខ្ញុំសូមអាន អង់គ្លេស ERN គឺ 00166995 មើលអំពីអនាគត ហើយក្នុងនេះបានរៀបរាប់ដូចខាងក្រោមនេះ "ទោះបីជាយ៉ាងនេះក្ដី យើងឃើញមានឧបសគ្គយ៉ាងច្រើនក្នុងការអនុវត្តការងារការពារប្រទេស និងការកសាងជាតិរបស់យើងដែលនៅខាងមុខយើង ដូច្នេះយើងត្រូវតែរួបរួមគ្នា ហើយយើងតស៊ូឲ្យបានខ្លាំងក្លា ជាពិសេសឲ្យមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ និងរក្សាជំហររបស់យើងក្នុងការពឹងខ្លួនឯង"។

លោក លោកស្រីចៅក្រមជាទីគោរព ឯកសារនេះគឺវាពាក់ព័ន្ធដោយសារតែវាកត់កំណត់ត្រាទុកនូវសុន្ទរកថាតែប៉ុន្មានតែប៉ុណ្ណោះ ក្រោយពេលបែកទីក្រុងភ្នំពេញ។ តាមសក្ខីកម្មរបស់សាក្សីដែលបានឆ្លើយ គឺថានៅក្នុងពេលនោះការជម្លៀសនៅតែបន្តធ្វើឡើងដដែល។ ភាពពាក់ព័ន្ធនេះគឺដោយសារតែវា

ក៏បង្ហាញ និងពាក់ព័ន្ធទៅនឹងការអះអាងរបស់ ខៀវ សំផន នៅចំពោះចៅក្រមស៊ើបអង្កេតផងដែរ។ ហើយគាត់បានក៏បាននិយាយដូច្នេះផងដែរ អំពីបញ្ហានៃការជម្លៀស។

[១០:៣៥:៣៩]

ឯកសារមួយទៀត គឺពាក់ព័ន្ធទៅនឹងហេតុការណ៍ខែមេសា ឆ្នាំ៧៥ ហើយខ្ញុំបានយកមកលើកឡើងនៅទីនេះ ដោយសារតែវាក៏វាពាក់ព័ន្ធចេញពីសុន្ទរកថានេះផងដែរ។ ឯកសារនេះគឺជាកំណត់សម្គាល់របស់សម្តេច នរោត្តម សីហនុ។ ឯកសារលេខ 10.18 គឺសរសេរ-- បានសរសេរជាភាសាបារាំង ជាចំណារដោយដៃ។ ឯកសារនេះមានតែមួយទំព័រតែប៉ុណ្ណោះ យើងស្នើសុំឲ្យមានការបកប្រែទៅជាភាសាខ្មែរ។ យើងបានទទួលឯកសារបកប្រែជាភាសាអង់គ្លេសហើយ ឯកសារដើមជាភាសាអង់គ្លេស ដូច្នេះខ្ញុំ -- ឯកសារដើមជាភាសាបារាំង។ ខ្ញុំនឹងអានឯកសារនេះដោយសង្ខេប។

ឯកសារសរសេរនៅទីក្រុងប៉េកាំង ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧ "នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ពីទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ខ្ញុំបានបញ្ជូនសារមួយទៅឯកឧត្តម ខៀវ សំផន អបអរសាទរ និងកោតសរសើរចំពោះឱកាសជ័យជម្នះមហាអស្ចារ្យ ដ៏ក្លាហានរបស់កងទ័ពរំដោះជាតិកម្ពុជាដែលហៅថាកាត់ថា អេ.អេហ្វ.អិន.អិល.ស៊ី នៅក្នុងទីក្រុងភ្នំពេញ។ ហើយខ្ញុំបង្ហាញខ្មែរក្រហមដែលកំពុងកាន់អំណាច ខ្ញុំក៏មិនបានបង្ហាញអំពីគោលបំណងរបស់ខ្ញុំក្នុងការត្រឡប់មកវិញ ដោយមិនមានពន្យារពេលមកប្រទេសរបស់យើងវិញដើម្បីរស់នៅក្នុងចំណោមប្រជាជន និងប្រជាជាតិខ្មែរ។ នៅពេលនេះគឺប្រជាជនរបស់យើងហើយដែលខ្មែរក្រហមគាត់ចង់បាន ហើយចង់យើងឲ្យខ្ញុំបែកចេញពីគ្រួសារ។ ខ្ញុំបានទទួលនូវការឆ្លើយតបផ្ទួរពីឯកឧត្តម ខៀវ សំផន ដែលក្នុងនោះនិយាយអំពីបញ្ហាខ្មែរក្រហមរំដោះប្រជាជនពីទីក្រុងទៅជនបទ ហើយស្នើសុំឲ្យខ្ញុំនេះរាយការណ៍ ក្រោយមកអំពីការត្រឡប់របស់ខ្ញុំមកប្រទេសកម្ពុជា"។

ឯកសារនេះគឺពាក់ព័ន្ធដោយសារតែវាមានកត់ត្រាទុក ដោយ -- ការកត់ត្រាទុកសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ហើយត្រូវបានរាយការណ៍ដោយសម្តេច សីហនុ ក្រោយពេលបែកទីក្រុងភ្នំពេញ។

[១០:៣៨:០៧]

នៅពេលដែលយើងមើលទៅលើសុន្ទរកថាបន្ថែមទៀត ដែលថ្លែងឡើងដោយ ខៀវ សំផន ដែលក្នុងនោះគឺមានការឯកភាពទៅលើគោលនយោបាយ និងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា។

ឯកសារដំបូងគឺ ឯកសារថ្ងៃ១៧ ខែមេសា ឆ្នាំ៧៦ គឺជាសេចក្ដីថ្លែងសុន្ទរកថា។ សេចក្ដីថ្លែងនេះធ្វើឡើងដោយ ខៀវ សំផន នៅខួបលើកទី១ នៃជ័យជម្នះទីក្រុងភ្នំពេញ។ សុន្ទរកថានេះបានលើកឡើងបញ្ហាមួយចំនួន មាននៅឯកសារលេខ E3/275 វាជាឯកសារមកពីសេវាផ្សាយព័ត៌មានអន្តរជាតិគឺហ្វីប៊ីស។ ខ្ញុំយកចំណុចចោះៗតែប៉ុណ្ណោះនៅក្នុងអត្ថបទនេះ ដោយសារពេលវេលាកំណត់របស់យើង។ យើងមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ ហើយយើងខ្ញុំបានស្នើសុំបកប្រែជាភាសាបារាំង និងខ្មែររួចមកហើយ។ ERN ជាភាសាអង់គ្លេសគឺ 00167631។

ខៀវ សំផន នៅក្នុងនេះគឺបានឯកភាព ហើយធ្វើការប្រារព្ធខួបលើកទី១ នៅថ្ងៃ១៧ ខែមេសា។ ការដកស្រង់សម្ដីនៅក្នុងនេះគឺមានដូចតទៅ ពាក់ព័ន្ធថ្ងៃ១៧ ខែមេសា។ សូមដកស្រង់សម្ដី "វាក៏ជាថ្ងៃដែលយុគសម័យខ្មៅងងឹតនៅលើប្រទេសកម្ពុជាយើងបានបញ្ចប់។ វាជាថ្ងៃមួយដែលការឈឺចាប់ ទុក្ខសោករបស់កម្មករ កសិកររបស់យើង ដែលឆ្លងកាត់ជាយូរមកហើយ ក្រោមការគាបសង្កត់របស់ពួកចក្រពត្តិ អាណានិគម និងពួកប្រតិកិរិយា ក៏បានបញ្ចប់ផងដែរ"។

[១០:៤០:២០]

អត្ថបទបន្ទាប់មួយទៀតនៅខាងក្រោមនេះបន្តិច គឺសរសេរដូចតទៅ "ប្រជាជនយើង កម្មករ កសិករ និងកងទ័ពបដិវត្តន៍របស់យើងក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃអង្គការបដិវត្តន៍របស់យើង មិនត្រឹមតែឈ្នះមហាអស្ចារ្យនិងរំដោះប្រទេសកម្ពុជារបស់យើងនោះទេ ក៏បានបញ្ចប់យុគសម័យខ្មៅងងឹត ដែលកំពុងតែយាយីពួកគេរាប់ពាន់ឆ្នាំមកហើយ ហើយក៏បានរំដោះខ្លួនឯងចេញមកពីការគាបសង្កត់របស់ពួកចក្រពត្តិ និងពួកអាណានិគម និងការគាបសង្កត់ពីវណ្ណៈប្រតិកិរិយាផ្សេងទៀត។

ឯកសារនេះគឺថា ខ្ញុំបានបញ្ចប់រួចមកហើយនូវការដកស្រង់សម្ដី។ ដូច្នេះ តើលោកប្រធានយើងអាចសម្រាកពេលនេះ ឬក៏នៅពេលបន្តិចទៀត?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅដល់រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤១ នាទី ដល់ម៉ោង ១១:០៥ នាទី)*

[១១:០៥:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាង។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងបានពិនិត្យមើលឯកសារ E3/275 ដែលមានចែងអំពីសុន្ទរ-កថាឆ្នាំ១៩៧៥ ដោយលោក ខៀវ សំផន ដែលជាប្រធាននៃគណៈប្រធានរដ្ឋ។

ហើយយើងខ្ញុំនឹងអានចេញពីកថាខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងការយល់ស្រប ការឯកភាពរបស់ ខៀវ សំផន ទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់មកទៀតគឺថា ERN 00167632 ហើយមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដូចខ្ញុំជម្រាប។ គាត់បាននិយាយដូចខាងក្រោមនេះ៖

"បច្ចុប្បន្ននេះប្រជាជនយើង កម្មករ កសិករ ហើយនិងកងទ័ពបដិវត្តន៍កម្ពុជាដោយខ្លួនឯងសម្រេចអំពីជោគវាសនារបស់ខ្លួនដោយឯករាជ្យ។ គ្មានចក្រពត្តិនិយម ហើយអាណានិគមនិយម ឬក៏វណ្ណៈប្រតិកិរិយាណាមួយអាចកំណត់អំពីជោគវាសនាប្រជាជន កម្មករ កសិករ កងទ័ពបដិវត្តន៍របស់យើងបានទេ។ ប្រជាជាតិទាំងមូលប្រើឈាមស្រស់របស់ខ្លួន ដើម្បីកសាងប្រទេសជាតិប្រវត្តិសាស្ត្ររបស់ខ្លួននៅក្នុងអនាគត គ្មានអ្វីអាចលុប ឬក៏ធ្វើឲ្យយើងបំភ្លេចបានទេ អតីតដ៏ខ្មៅងងឹតមិនអាចត្រឡប់វិញទេ"។

នៅខាងក្រោមនេះបន្តិច គាត់បាននិយាយថា "ជោគជ័យរបស់ប្រជាជនយើង កម្មករ កសិករយើងនៅក្នុងសម័យកាលនេះ បានធ្វើឲ្យយកឈ្នះលើចក្រពត្តិនិយមអាមេរិកដែលអមនុស្សធម៌ ហើយនិងឆ្លុះបញ្ចាំងអំពីប្រាសាទអង្គរដ៏ថ្លៃថ្លារុងរឿង"។

បន្ទាប់មកគាត់បានពិភាក្សាអំពីស្ថាប័នជាតិមួយចំនួនដែលបានបង្កើត ហើយខ្ញុំមិនអានទាំងអស់ទេ ពីព្រោះវាស្រដៀងទៅនឹងសុន្ទរកថាខាងដើមដែលយើងបានពិនិត្យមើល ដែលនិយាយអំពីរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យនោះ។

[១១:០៨:៥០]

អត្ថបទបន្ទាប់ទៀតដែលខ្ញុំអានគឺថា ERN 00167636 គឺនេះផ្លូវមើលទៅអនាគត ភារកិច្ចរបស់ប្រជាជន។ សូមដកស្រង់ "បន្ទាប់ពីរំដោះគឺពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់បច្ចុប្បន្នការឈានមុខរបស់យើងគឺថា ដោយល្បឿនឈានមុខយ៉ាងលឿនបំផុត។ ក្នុងរយៈពេលតែ១ឆ្នាំ យើងសម្រេចបានគ្រប់ទិដ្ឋភាព ដូចដែលគេធ្វើក្នុង ១០ឆ្នាំដូច្នោះដែរ។ ការឈានមុខរបស់យើងគឺដើរលឿនបំផុត ប៉ុន្តែយើងមានអ្វីច្រើនទៀតដែលត្រូវធ្វើ ហើយផ្លូវរបស់យើងនៅវែងនៅឡើយ។ ជាឧទាហរណ៍ យើងនៅតែមានភារកិច្ចក្នុងការអនុវត្តនូវរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឲ្យបានត្រឹមត្រូវឲ្យបានម៉ឺងម៉ាត់ ឲ្យល្អឥតខ្ចោះ ហើយនិងជានិច្ច។ ភារកិច្ចរបស់យើងគឺត្រូវរក្សាស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ដើម្បីការពាររក្សានូវប្រទេសរបស់យើងទាំងមូល"។ សុន្ទរកថានេះ គឺនៅ ថ្ងៃទី -- ខែមេសា ឆ្នាំ១៩៧៥។

ឯកសារបន្ទាប់ទៅទៀតហ្នឹងគឺ សុន្ទរកថានៅខែសីហា ឆ្នាំ១៩៧៦ នៅពេលនេះនៅក្នុងមហាសន្និបាតប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា នៅថ្ងៃទី១៦ ដល់ សីហា ឆ្នាំ១៩៧៦ ERN *អ៊ីណាំប៊ីរ* គឺ E3/549។ យើងមានអត្ថបទខ្មែរនិងអង់គ្លេសទាំងមូល ហើយមានបកប្រែជាភាសាបារាំងតែមួយផ្នែក ហើយយើងបានស្នើសុំឲ្យបកប្រែទាំងស្រុង។ នៅក្នុងវេទិកាអន្តរជាតិមួយគាត់បានអានសុន្ទរកថាបែបនេះ សុន្ទរកថានេះប្រកាសទទួលស្គាល់គោលនយោបាយរបស់ថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ។

[១១:១១:១៦]

ខ្ញុំនឹងអានខ្លឹមសារមួយចំនួន ដើម្បីបំភ្លឺជូនតុលាការអំពីបញ្ហានេះ។ នៅខ្មែរ ERN 00065900, អង់គ្លេស ERN 00644938 ដល់ 939 គាត់បាននិយាយអំពីបទពិសោធន៍របស់រដ្ឋាភិបាលថ្មីកម្ពុជា ហើយនិយាយអំពីសកម្មភាពវិទ្ធង្សនារបស់ខ្មាំងផងដែរ។ គាត់បាននិយាយដូចខាងក្រោមនេះ សូមដកស្រង់ "ក្រៅពីការប៉ុនប៉ងរបស់ខ្មាំង ក្នុងការតាមបំផ្លាញលទ្ធផលនៃជ័យជម្នះរបស់ប្រជាជនយើងទៀត ដូចជាយើងកប៉ាល់ ការទម្លាក់គ្រាប់បែកនៅសៀមរាបនៅឆ្នាំ១៩៧៦។ ទោះជាយ៉ាងនេះក្តីយើងបានពុះពារឧបសគ្គគ្រប់បែបយ៉ាងបង្កើត -- បង្កបង្កើនសស្រាក់សស្រាំ ដោយឈរលើជំហរខ្លួនទីពឹងខ្លួនជាសំខាន់ហើយយើងដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជន ហើយជាពិសេសយើងបានដោះស្រាយបញ្ហាស្បៀងអាហារ"។

ហើយចុងបញ្ចប់នៅកន្លែងនេះក្នុងកថាខណ្ឌ គាត់បាននិយាយថា "ទោះជាយ៉ាងនេះក្តី យើងត្រូវ

ពង្រឹងការប្រុងប្រយ័ត្នបដិវត្តន៍របស់យើងនៅក្នុងបទពិសោធន៍ជាច្រើនដែលយើងបានឆ្លងកាត់។ ខ្មាំងមិនដែលបោះបង់ទេអំពីរូបភាពដ៏អាក្រក់របស់គេក្នុងការបំផ្លាញបដិវត្តន៍របស់យើងទេ"។

លោក លោកស្រីចៅក្រម! មានសេចក្ដីយោងទៅនឹងការបោកគ្រាប់បែកនៅក្នុងខេត្តសៀមរាប ឆ្នាំ១៩៧៦។ ហេតុការណ៍នោះគឺនិយាយពាក់ព័ន្ធទៅនឹងមន្ទីរ៨៧០ ដែលរៀបរាប់នឹងពាក្យដូចគ្នា ដែលលោកលោកស្រីចៅក្រមបានស្ដាប់ដែរ គឺថានៅក្នុងឯកសារ E3/1173 បាទ។

[១១:១៣:៥២]

ឯកសារបន្ទាប់ទៅនេះ គឺជាបទសម្ភាសន៍ដែលលោក ខៀវ សំផន បានឆ្លើយនៅក្នុងពេលដែលគាត់ចូលរួមនៅក្នុងសន្និបាតទីក្រុងកូឡុំបូ។ ឯកសារ E3/68-- 608 (សូមកែតម្រូវ) ឯកសារនេះគឺមានភាសាទាំងបីភាសា ដែលមានចំណងជើងថា "ខៀវ -- ត្រូវបានសម្ភាសអំពីការប្រហារជីវិតនានាដែលជាបញ្ហាប្រទេសជាតិ"។ ជាការបោះពុម្ពផ្សាយ ឬក៏ប្រតិចារឹកនៃការបោះពុម្ពផ្សាយដែលចេញមកពីប្រទេសអ៊ីតាលី ចំណងជើងដើមរបស់នោះគឺ *ហ្វាមីលា គ្រិស្ទីអាណា* គឺនៅក្នុងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦។

ឯកសារនេះមានភាពពាក់ព័ន្ធពីព្រោះថាមានការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងការចោទប្រកាន់។ នៅខែកញ្ញា ឆ្នាំ១៩៧៦ និយាយពីឧក្រិដ្ឋកម្មទូលំទូលាយនៅប្រទេសកម្ពុជា អំពីការកាប់សម្លាប់ ការសម្លាប់រង្គាលជាដើម។ ហើយយើងពិនិត្យមើលខ្មែរ ERN 00635928, បារាំង ERN 00632566, 00419841 បទសម្ភាសន៍នោះមានផ្នែកដូចខាងក្រោមនេះ។ "សំណួរ៖ លោកប្រធានតើស្ថានភាពក្នុងប្រទេសកម្ពុជានាបច្ចុប្បន្នយ៉ាងណាដែរ? ចម្លើយ៖ កម្ពុជាប្រជាធិបតេយ្យប្រឈមមុខនឹងរយៈពេលដ៏លំបាកបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ស្ថានភាពបច្ចុប្បន្នក្លាយមកពីភាពពិត ដែលថាប្រទេសរបស់យើងដ៏តូចមួយដែលបានឆ្លងកាត់សង្គ្រាមរយៈពេល៥ឆ្នាំ ប្រឆាំងនឹងសត្រូវដែលកម្លាំងរបស់ -- ខ្លាំងជាងយើង ហើយសម្បើម បើសង្កេតមើលគ្រប់ជ្រុងជ្រោយ។ ស្ថានភាព -- ក្នុងស្ថានភាពបែបនេះ ម្នាក់ៗត្រូវតែធ្វើការប្រសិនបើបញ្ហារបស់យើងនឹងត្រូវដោះស្រាយនោះ។ មានន័យថាគ្រប់ៗគ្នាត្រូវមិន -- ត្រូវធ្វើអ្វីដោយមិនគិត-- ត្រូវតែធ្វើការដោយមិនគិតពីអ្វីទាំងអស់។ សំណួរ៖ យោងតាមព័ត៌មានមួយចំនួនប្រជាជន ៦០០.០០០នាក់បានបាត់បង់ជីវិតក្នុងសង្គ្រាម។ ប្រជាជន៨០០.០០០នាក់ទៀតបានស្លាប់បន្ទាប់ពីសង្គ្រាម។ ការពោលបែបនេះគឺថាក្រុមប្រជាជន៨០០.០០០នាក់ ដែលយើងទើបនឹងថ្លែងចុងក្រោយនេះ គឺគាបសង្កត់ដោយខ្មែរក្រហម ដោយផលនយោបាយ។ តើមានការពិតទេ មាន

ការនិយាយបែបនេះ? ចម្លើយ៖ ប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតនៅក្នុងសង្គ្រាម គឺថាច្រើនជាង ១លាននាក់។ រឿងរ៉ាវនៃការកាប់ នៃការសម្លាប់រង្គាលត្រូវកំពុងបានផ្សព្វផ្សាយដោយផ្នែកមួយ ដោយសារព័ត៌មានបរទេស គឺជាការប្រមាថមើលងាយ ដែលគឺជាការនិយាយបង្ខូចកេរ្តិ៍ឈ្មោះផ្សព្វផ្សាយដោយជនក្បត់ ដែលបានរត់ភៀសខ្លួនចេញទៅប្រទេសកម្ពុជាប្រជាធិបតេយ្យ។ ឥឡូវនេះអ្នកដែលរត់ចេញទៅប្រទេសបារាំង ឥឡូវនេះត្រឡប់មកកម្ពុជាវិញហើយ។ សំណួរ៖ តើលោកបានដាក់ពាក្យបណ្តឹងជាទៀងទាត់ប្រឆាំងនឹងឧក្រិដ្ឋជនសង្គ្រាម ឬបានកម្ទេចយ៉ាងឆាប់រហ័សដែលបានចេញពីប្រទេសកម្ពុជាដែរឬទេ? ចម្លើយ៖ "ហេតុអ្វីយើងត្រូវតែនិយាយអំពីបញ្ហានេះរហូត។ ឧក្រិដ្ឋជនទាំងនោះបានប្រព្រឹត្តិបទល្មើសបែបនេះប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ រហូតដល់ពួកគេសក្តិសមនឹងទទួលបានការស្អប់ខ្ពើមដ៏ខ្លាំងបំផុត។ លើសពីនេះគឺជាអ្វីដែលអ្នកទាំងនោះចង់បាន។ ខ្ញុំចង់សន្តោសប្រណីណាស់ចំពោះអ្នកទាំងនេះ។ អ្នកបដិវត្តន៍មិនមែនជាអ្នកសម្លាប់ទេ"។

[១១:១៧:៥៨]

"សំណួរ៖ លោកប្រធាន សូមមេត្តាជួយឆ្លើយបន្ថែមទៀត ចំពោះសំណួររបស់ខ្ញុំ? ចម្លើយ៖ "ជនក្បត់ទាំងនេះដែលស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យត្រូវបានកាត់ទោសប្រហារជីវិតហើយ។ សំណួរ៖ តើប្រជាជនកម្ពុជាបច្ចុប្បន្នមានប៉ុន្មាន? ចម្លើយ៖ ចំនួនប្រជាជនសរុបបច្ចុប្បន្ននៅកម្ពុជាប្រជាធិបតេយ្យគឺ ៥លាននាក់។ សំណួរ៖ នៅពេលចាប់ផ្តើមសង្គ្រាម គឺថាមាន៧លាននាក់។ តើ១លាននាក់ស្លាប់នៅក្នុងសង្គ្រាម តើអ្នកផ្សេងទៀតទៅឯណា? ចម្លើយ៖ វាជារឿងមិនគួរឲ្យជឿទេ ដែលលោកនិយាយពីការស្មានអំពីអ្នកស្លាប់។ បើសិនជាលោកចង់បានតួរលេខច្បាស់លាស់ យើងត្រូវពិចារណាចំនួនប្រជាជនដែលបានចាកចេញទៅប្រទេសថៃ បារាំង សហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត"។

[១១:១៨:៥៥]

ហើយនៅទីបំផុតមុននឹងយើងបញ្ចប់ឯកសារនេះ គឺនៅក្នុងខ្មែរ ERN 00635935, បារាំង ERN 00632567, អង់គ្លេស ERN 00419843។ "សំណួរ៖ តើវាអាចទៅរួចយ៉ាងដូចម្តេចសម្រាប់ប្រជាជនក្រុមដែលមានចរិតអាត្មានិយម ប្រពៃណី ដូចជាប្រជាជនកម្ពុជាទទួលយកប្រព័ន្ធរដ្ឋាភិបាលដែលបន្ទាបមនុស្សម្នាក់ៗឲ្យដល់កម្រិតអ្វីស្មើគ្នា? ចម្លើយ៖ "យើងទើបតែងើបផុតពីសង្គ្រាមដែលបំផ្លាញពីរភាគបួន -- បីភាគបួននៃប្រទេសរបស់យើង គឺជាសង្គ្រាមដែលធ្វើឡើងដោយចក្រពត្តិមូលធននិយម។ ក្នុងស្ថានភាពបែបនេះយើងមិនអាចយល់ពីបញ្ហាអាត្មានិយមពីភាពឆើតឆាយមួយចម្លែកនោះទេ។

សំណួរ៖ ប្រជាជនកម្ពុជាតែងតែគោរពជំនឿសាសនាណាស់ តើរដ្ឋបាលថ្មីគោរពសេរីភាពសាសនាទេ? ចម្លើយ៖ រដ្ឋធម្មនុញ្ញថ្មីគោរពសេរីភាពសាសនាក៏ដូចជាគោរពជំនឿដទៃទៀត ទាំងអស់ដែរ។ ជាការពិត បញ្ហានេះមិនបញ្ជាក់ពីការគោរពចំពោះបុព្វសិទ្ធមួយចំនួនដែលត្រូវបានវណ្ណៈសាសនានេះ ឬដោយអ្នកដទៃតែងតែមាននោះទេ ក៏ដូចជនគ្រប់រូបផ្សេងទៀតដែរ។ ទោះបីជាព្រះសង្ឃ ព្រះពុទ្ធ សាសនា ក៏មានភារកិច្ច និងកាតព្វកិច្ចត្រូវធ្វើការដែរ"។

[១១:២០:៣០]

នេះខ្ញុំសូមបញ្ចប់ពីសុន្ទរកថាដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះក្នុងឆ្នាំនោះ។ ហើយនិងខ្ញុំចូលទៅសុន្ទរកថាផ្សេងទៀត។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានតុលាការ ដើម្បីបង្ហាញបញ្ចាំងវីដេអូ គឺឯកសារ D295/2/2.65R។ វីដេអូនេះគឺចុះកាលបរិច្ឆេទគឺចុងឆ្នាំ១៩៧៧ ហើយនិងមានរូបភាពអំពីប្រធានាធិបតីឡាវ សុផានុវង្ស មកប្រទេសកម្ពុជា។ នៅក្នុងវីដេអូនេះ អ្វីដែលយើងខ្ញុំអាចបញ្ជាក់ជូនតុលាការបាននោះគឺមានវត្តមាន ខៀវ សំផន, នួន ជា, អៀង សារី ហើយ វន វ៉េត ផងដែរ។

ដូចដែលលោក លោកស្រីចៅក្រមជ្រាបហើយថា គាត់ក៏ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ដែរ វន វ៉េត នេះ។ យើងមានផ្នែក៦ ជាមួយអង្គភាពសោតទស្សន៍ ហើយយើងនឹងសុំការអនុញ្ញាតដើម្បីដាក់ជូនតុលាការជ្រាប។ ឥឡូវនេះវីដេអូដែលខ្ញុំស្នើចាក់មុនគេនោះគឺនៅក្នុង C1, 2, 3, 5, 7 និង 13 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! អ្នកបច្ចេកទេសខាងសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:២២:១២]

*(ការបង្ហាញឯកសារជារូបភាព)*

[១១:២៨:៣៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

ភាពពាក់ព័ន្ធនៃវីដេអូនេះគឺនិយាយអំពី មានរូបថតវីដេអូរបស់ ខៀវ សំផន នៅក្នុងនោះ ដែលគាត់បំពេញការងារក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជា ហើយថាគាត់បានធ្វើដំណើរទូទៅប្រទេស បានពិនិត្យមើលកម្មាភិបាលរបស់គាត់នៅក្នុងការដ្ឋាននានានៅពេលនោះ បាទ។ ឥឡូវនេះនៅឆ្នាំ១៩៧៧ សុន្ទរកថាដែលមាននៅក្នុងសំណុំរឿងដែលលោក ខៀវ សំផន បានអាននោះគឺថា គឺនៅក្នុង

ខួបជោគជ័យជម្នះឆ្នាំ១៩៧៧ គឺឯកសារ E3/201 ជាសុន្ទរកថារបស់ ខៀវ សំផន នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧។ ដូចដែលបានឃើញនេះ គឺថាមានបញ្ហាពាក់ព័ន្ធជាច្រើនដែលនិយាយអំពីតម្រូវការក្នុងការប្រុងប្រយ័ត្នបដិវត្តន៍ ហើយនិងការប្រយុទ្ធខ្លាំង ហើយនិងការបែងចែកនូវរបបអាហារពីគណៈមជ្ឈិមទៅទូទាំងប្រទេស ការទទួលស្គាល់ការដ្ឋានការងារធំៗដែលមានប្រជាជនរាប់ពាន់ រាប់ម៉ឺននាក់ធ្វើការងារ ហើយនិងសាលារៀនមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ។ ខ្មែរ ERN ដែលយើងខ្ញុំចាប់ផ្ដើមនោះគឺ 00292804 រហូតដល់ 05, បារាំង ERN 00612166, ហើយអង់គ្លេស ERN គឺមិនមានទេ ឥឡូវនេះខ្ញុំមិនទាន់បាន គឺនៅទំព័រ២ នៃឯកសារនេះ។ អត្ថបទរបស់ខ្ញុំមិនមានជា ERN ទេ ខ្ញុំនឹងជម្រាបជូននៅពេលក្រោយ។

[១១:៣០:៥៧]

បាទ ផ្នែកដំបូងគឺដូចខាងក្រោមនេះ សូមដកស្រង់ "ជោគជ័យបន្ទាប់ពីរំដោះភ្លាម យើងទទួលបាននូវការលំបាកមិនអាចថ្លែងបាន ដូចដែលយើងទើបតែងើបពីសង្គ្រាមបំផ្លិចបំផ្លាញរបស់ចក្រពត្តិអាមេរិក។ សត្រូវបានទទួលបរាជ័យក្នុងការនាំឲ្យយើងរងការលំបាកណាមួយ ថ្ងៃនេះ ខ្មាំងមិនអាចធ្វើអ្វីឲ្យយើងបានទេ។ យើងមានជំនឿយ៉ាងមុតមាំថា ដែលចេញពីភស្តុតាងជាក់ស្ដែង។ ប៉ុន្តែទោះយ៉ាងណាក្ដី យើងត្រូវតែបន្តភារកិច្ចការពារកម្ពុជាប្រជាធិបតេយ្យរបស់យើង ការពាររដ្ឋបាល កម្មករ កសិកររបស់យើង រក្សាការពារសមិទ្ធិផលបដិវត្តន៍កម្ពុជារបស់យើង តាមរយៈការទប់ស្កាត់ដាច់ខាតនូវសត្រូវទាំងអស់ រារាំងពួកវាពីការឈ្លានពាន ពីការជ្រៀតជ្រែក ឬធ្វើវិទ្ធង្សនាប្រឆាំងនឹងយើង។ យើងត្រូវបោសសម្អាតសត្រូវក្នុងសមត្ថភាពរបស់យើងជាម្ចាស់លើស្ថានភាព ដើរតាមមាគ៌ានយោបាយក្នុងស្រុក នយោបាយបរទេស នយោបាយយោធារបស់បដិវត្តន៍របស់យើង។ ត្រូវធ្វើអ្វីៗគ្រប់យ៉ាងឲ្យបានប្រណីតគ្រប់ជ្រុងជ្រោយ។ យើងមិនត្រូវមានចិត្តរាយមាយ ធ្វេសប្រហែស ភ្លេចភ្លាំង ដោយសារជោគជ័យអតីតកាលទេ។ ផ្ទុយទៅវិញយើងត្រូវតែប្ដេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច រក្សាស្មារតីបដិវត្តន៍ឥតងាករេ បន្តវាយប្រយុទ្ធ និងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា"។ ខ្ញុំបានទទួលផ្នែកនេះគឺ 00004165 ជាភាសាអង់គ្លេស នេះជាលេខERN ភាសាអង់គ្លេសបាទ។

[១១:៣៣:០៥]

ផ្នែកបន្ទាប់និយាយអំពីបញ្ហានៃស្បៀងអាហារ ម្ហូបអាហារ ហើយបាននិយាយថា សូមដកស្រង់ "នៅឆ្នាំ១៩៧៦ យើងដោះស្រាយបញ្ហាក្នុងការ ផែនការបង្កបង្កើនផល ជាលទ្ធផលយើងបានប្រមូល

ផលដំណាំល្អសម្រាប់ឆ្នាំ១៩៧៧។ ឥឡូវនេះយើងអាចចិញ្ចឹមប្រជាជនយើងតាមបែបចែករបបអាហារគ្រប់គ្រាន់ពីរដ្ឋ យើងនៅសល់ស្រូវសម្រាប់ហូបទៀតផង -- សម្រាប់នាំចេញទៀតផង"។ ភាពពាក់ព័ន្ធនៅទីនេះគឺថាការទទួលស្គាល់របស់គាត់អំពីរបបអាហារ គឺត្រូវបានរដ្ឋជាអ្នកកំណត់។

ផ្នែកបន្ទាប់គឺថា ពីរបីកថាខណ្ឌខាងក្រោមនៅខ្មែរ ERN 00292807, បារាំង ERN 00612 167 ត្រង់ចំណុចនេះនិយាយអំពីការដ្ឋានធ្វើការងារ ដែលគេបង្កើតឡើងនៅកម្ពុជានាសម័យនោះ "ដូច្នេះយើងអាចមើលឃើញជនបទមានការប្រែប្រួលយ៉ាងខ្លាំង។ ការដ្ឋានសាងសង់ អាងស្តុកទឹក ប្រឡាយទឹក ឬទំនប់នីមួយៗមានកម្មករធ្វើការប្រហែល១០.០០០ ឬក៏ ១២.០០០ ឬ ៣០.០០០ នាក់។ ហេតុដូច្នេះហើយការងារមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

[១១:៣៤:៣៦]

កថាខណ្ឌបន្ទាប់មួយទៀត "តើសមិទ្ធិផលទាំងនេះធ្វើឡើងដោយម៉ាស៊ីនដែរឬទេ? អត់ទេ យើងមិនមានម៉ាស៊ីនអ្វីទេ។ យើងធ្វើអ្វីៗទាំងអស់គឺ ផ្អែកលើកម្លាំងរបស់ប្រជាជនយើង។ យើងធ្វើការពឹងផ្អែកទាំងស្រុងលើខ្លួនឯង។ នេះបង្ហាញពីវីរភាពដ៏លើសលុបរបស់ប្រជាជនយើង នេះក៏បង្ហាញអំពីកម្លាំងដ៏អស្ចារ្យរបស់ប្រជាជនដែរ។ ទោះជាបាតដៃទទេក៏ដោយ ពួកគេអាចធ្វើអ្វីបានគ្រប់យ៉ាងដែរ។

ឥឡូវនេះកថាខណ្ឌបីខាងក្រោមទៅខាងក្រោមបីទៀតនេះ គាត់បាននិយាយដូចខាងក្រោមនេះ៖

"អ្វីធ្វើឲ្យមានការកែប្រែដល់ជីវិតរបស់ប្រជាជន ជីវភាពរបស់ប្រជាជនគឺទាក់ទងទៅនឹងការការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ។ គ្រប់កិច្ចប្រឹងប្រែងក្នុងការរួបរួម ក្នុងការពង្រឹកការគ្រប់គ្រងកម្មករ ពលករ ដើម្បីកសាងប្រទេសរបស់យើង។ ប្រទេសរបស់យើងមានការប្រជាជនតិច ដែលធ្វើឲ្យយើងមានការចាំបាច់ ដើម្បីពង្រឹងឲ្យបានឆាប់រហ័ស ហើយពង្រីកប្រជាជនរបស់យើង។ ការពារកម្លាំងដែលមាន ផ្តល់ស្បៀងអាហារ ហើយនិងពង្រីកកម្លាំងឲ្យបានច្រើន។ នេះជាមាគ៌ានយោបាយរបស់យើង គឺកំណត់ដោយអង្គការបដិវត្តន៍របស់យើង។ ដូច្នេះយើងត្រូវតែរួបរួមប្រជាជនយើងឲ្យមានគ្រប់ចំនួនពីរ ឬក៏អង្ករឲ្យបានគ្រប់គ្រាន់ប្រចាំថ្ងៃ ជាពិសេសតាមអ្វីដែលគេត្រូវការ។ នៅក្នុងអតីតកាល តើកសិករក្រីក្របានបង្អែមដែរឬទេ? គឺដោយកម្រណាស់។ ពួកគេអាចៗទទួលបានតែត្រប់ែក និងអាហារផ្សេងទៀត ប៉ុន្តែឥឡូវនេះពួកគាត់បានបង្អែមបីដងក្នុង១ឆ្នាំ ដែលគ្រប់គ្រាន់សម្រាប់ការពារសុខភាពរបស់គាត់នោះ"។

[១១:៣៥:៥៤]

អត្ថបទមួយទៀតត្រង់ខ្មែរ ERN 00292811, បារាំងមានលេខ 00612170 គឺទំព័របន្ទាប់ពីភាសាងអង់គ្លេសអម្បាញ់មិញដែលយើងទើបតែបានអាន។ ដកស្រង់សម្តី "ហេតុដូច្នេះគោលបំណងរបស់យើងគឺធ្វើការងារបម្រើការកសាងប្រទេស និងសិក្សាអំពីបញ្ហាបច្ចេកទេសនៅពេលតែមួយ។ មិនថាតែអាងស្តុកទឹក ឬក៏ទំនប់ ដែលយើងបានកសាងកាលពី៥ -- ១០ឆ្នាំមុននោះ វាមិនជាបញ្ហានោះទេ។ ក្នុងរយៈពេល៥ ឬ១ឆ្នាំខាងមុខយើងនឹងវិវត្តន៍ អភិវឌ្ឍច្រើន កាន់តែមាន មានបទពិសោធន៍ជាងពេលបច្ចុប្បន្ន ហើយយើងនឹងមានជំនាញបច្ចេកទេសជាងនាពេលបច្ចុប្បន្ន"។

បន្ទាប់មកគឺគាត់បានបញ្ចប់សុន្ទរកថា ដោយយោងអំពីភាពចាំបាច់ក្នុងការធ្វើការក្តោបក្តាប់គោលជំហររឹងប៉ឹងបដិវត្តន៍ គឺអត្ថបទខាងក្រោម អត្ថបទដែលខ្ញុំអានអម្បាញ់មិញ។ គាត់បានលើកឡើងថា សូមដកស្រង់សម្តី "យើងត្រូវតែមានមោទនភាពចំពោះជោគជ័យរបស់យើងអតីតកាល យើងមិនត្រូវធ្វេសប្រហែស មិនយកចិត្តទុកដាក់ ឬភ្លេចភ្លាំងចំពោះសមិទ្ធិផលរបស់យើងនោះទេ។ ផ្ទុយមកវិញយើងត្រូវតែដាក់ខ្លួនប្រុងប្រយ័ត្ន ហើយគោរពមាគ៌ាអង្គការបដិវត្តន៍របស់យើងឲ្យបាននឹងនរ។ ប្រសិនបើយើងអាចធ្វើដោយអង់អាច យើងពិតជាទទួលបានជោគជ័យក្នុងការពង្រឹង និងពង្រីកបន្ថែមជោគជ័យរបស់យើង។

[១១:៣៨:៤២]

យើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍គ្រប់ពេលវេលា ប្រឆាំងនឹងសត្រូវមកពីគ្រប់ទិសទី ទាំងក្នុង និងក្រៅប្រទេស ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋបាល កម្មករ កសិករ និងរក្សាឲ្យបាននូវសមិទ្ធិផលនៃបដិវត្តន៍យើងដាច់ខាត និងជាអចិន្ត្រៃយ៍"។

សេចក្តីថ្លែងការណ៍ជាសាធារណៈ ឬសុន្ទរកថាជាសាធារណៈដែល ខៀវ សំផន បានថ្លែងឡើងមាននៅក្នុងសំណុំរឿង យើងឃើញមាននៅក្នុងឯកសារ D108/28.123។ គឺបច្ចុប្បន្ននេះមិនទាន់ដាក់សម្គាល់ E នៅឡើយទេ។ ឯកសារនេះគឺជាសេចក្តីថ្លែងការណ៍ថ្លែងឡើងដោយ ខៀវ សំផន នៅថ្ងៃ -- ធ្វើឡើងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ៧៧។ ជាពិសេសគឺឯកសារនេះលើកឡើងអំពីការផ្តាច់ទំនាក់ទំនងជាមួយនឹងសាធារណរដ្ឋវៀតណាម។ ការពាក់ព័ន្ធនៃឯកសារនេះគឺក្នុងនោះរួមមានកិច្ចពិភាក្សាអំពីការចោទប្រកាន់ការធ្វើ -- ការបំផ្លិចបំផ្លាញមកលើប្រទេសកម្ពុជា ហើយនិងការបម្រុងធ្វើរដ្ឋប្រហារ។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបស្រាប់រួចមកហើយ ប្រធានបទនេះគឺថាវាមានលើកឡើង ដដែលៗរបស់ថ្នាក់ដឹកនាំ ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ហាគោលនយោបាយប្រឆាំងនឹងខ្មាំងសត្រូវ។

[១១:៤០:៣៩]

អត្ថបទដែលខ្ញុំសូមលើកឡើងនេះ គឺចាប់ផ្ដើមឡើងដោយខ្មែរ ERN លេខ 00229017, បារាំងមានលេខ 00345466, អង់គ្លេសមានលេខ 00166065។ នៅក្នុងចំណុចនេះ ខៀវ សំផន បានលើកឡើងអំពីការប៉ះទង្គិចផ្នែកយោធាជាមួយនឹងខាងវៀតណាម នៅតាមព្រំដែលវៀតណាមក្នុងឆ្នាំ១៩៧៧។ ហើយគាត់បានលើកឡើងអំពីហេតុផលដែលនាំឲ្យមានការប៉ះទង្គិចគ្នា និងការចោទប្រកាន់អំពីការឈ្លានពានដោយកងកម្លាំងរបស់វៀតណាម។ គាត់លើកឡើងដូចតទៅ ដកស្រង់សម្ដី “ហេតុផលមួយដែលនាំឲ្យកងកម្លាំងវៀតណាមធ្វើការឈ្លានពាន ការបំផ្លិចបំផ្លាញ និងឆក់ប្លន់នៅក្នុងទឹកដីកម្ពុជា និងយកស្រូវលើប្រជាជនរបស់ប្រជាជនកម្ពុជា។ ពាក់ព័ន្ធនឹងហេតុការណ៍ពិតប្រាកដ និងយុត្តិសាស្ត្ររបស់វៀតណាម គឺហេតុផលដែលនាំឲ្យមានបញ្ហានេះ មានដូចតទៅ៖ មូលហេតុភ្លាមៗ ការឈ្លានពានរបស់កងកម្លាំងវៀតណាម ធ្វើឡើងមកលើការរំលោភបំពាន ឈ្លានពានក្នុងទឹកដីកម្ពុជា ដើម្បីឆក់ប្លន់ស្រូវរបស់ប្រជាជនកម្ពុជា ដើម្បីដោះស្រាយបញ្ហាអត់ឃ្លានរបស់ពួកវា”។

[១១:៤២:២២]

កថាខណ្ឌពីរក្រោមបន្ទាប់មកទៀតគឺមានការលើកឡើងដូចតទៅ “ក៏ប៉ុន្តែហេតុផលចម្បងនោះគឺថាកងកម្លាំងរបស់វៀតណាម គឺប្រើយុទ្ធសាស្ត្រដើម្បីធ្វើយ៉ាងណាដាក់បញ្ចូលកម្ពុជាស្ថិតនៅក្រោមការក្ដោបក្ដាប់ក្នុងឥណ្ឌូចិនរបស់ខ្លួន។ យោងតាមយុទ្ធសាស្ត្រនេះ ខាងកងកម្លាំងវៀតណាម បានធ្វើការគាបសង្កត់ជាច្រើនឆ្នាំរួចមកហើយ ហើយបានជំរុញឲ្យប្រទេសកម្ពុជាធ្វើយ៉ាងណាដើម្បីទប់ស្កាត់ប្រទេសកម្ពុជាកុំឲ្យមានឯករាជ្យភាព និងអធិបតេយ្យ”។

កថាខណ្ឌបន្ទាប់មកទៀតគឺចំណុចទី៣ អត្ថបទដូចខាងក្រោម សរសេររៀបរាប់ដូចតទៅ៖ “ដោយសារតែជំហរត្រឹមត្រូវរបស់ប្រទេសកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាមបានអនុវត្តកលល្បិចជាច្រើន បានប្រព្រឹត្តអំពីឧក្រិដ្ឋជាច្រើន ដែលរួមមានការញុះញង់ពួកក្បត់កម្ពុជាមួយចំនួនឲ្យបង្កើតបក្សថ្មី ជាឧបករណ៍របស់ខ្លួនដើម្បីបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា។ នៅពេលពួកគេបង្កើតជម្រករបស់ពួកគេនៅក្នុងទឹកដីកម្ពុជាចាប់តាំងពីឆ្នាំ១៩៦៥ និងជាពិសេសនៅក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សាធារណរដ្ឋសង្គមនិយមវៀតណាមបានតែងតាំងមនុស្សគ្មានសីលធម៌មួយក្រុមជាសម្ងាត់ និងបានឲ្យពួកគេចូលជាកងទ័ពកម្ពុជា ពិសេសជាឧបករណ៍របស់ខ្លួនលើទឹកដីកម្ពុជា ដោយបង្កើតរដ្ឋបាលរដ្ឋកម្ពុជាពិសេសដើម្បីប្រឆាំង និងវាយប្រហារអំណាចរដ្ឋបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំ

របស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីបំបែក និងបំផ្លាញកងទ័ពបដិវត្តន៍កម្ពុជាជាដើម។

[១១:៤៤:៣០]

ទោះបីជាយ៉ាងនេះក្តី ផែនការទាំងនេះរបស់វៀតណាមត្រូវបានធ្វើឲ្យបរាជ័យទាំងស្រុងដោយប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជាពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៥”។

កថាខណ្ឌបីបន្ទាប់ខាងក្រោមគឺឆ្នាំ១៩៧៥ និង៧៦ និយាយអំពីឆ្នាំទាំងអស់នោះ។ ERN ជាភាសាខ្មែរគឺ 00229020, បារាំងមានលេខ 00345468, អង់គ្លេសមានលេខ 00166067។ អត្ថបទដែលខ្លី តែវាពាក់ព័ន្ធ សូមដកស្រង់សម្តី “នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ វៀតណាមនៅតែបន្តឈ្លានពាន និងប្រព្រឹត្តបទឧក្រិដ្ឋក្នុងគោលបំណងធ្វើរដ្ឋប្រហារផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ តាមរយៈកម្លាំងក្បត់មួយចំនួន ដែលជាភ្នាក់ងាររបស់វៀតណាម”។

ផ្នែកដែលពាក់ព័ន្ធនៅក្នុងសុន្ទរកថាមួយនេះគឺថា ចម្លើយសារភាពរបស់ទាហានវៀតណាម ដែលបានឆ្លើយសារភាពនៅពេលនោះគឺថា យើងខ្ញុំបានលើកឡើងមុននេះ គឺបានលើកឡើងអំពីការធ្វើវិទ្ធង្សនារបស់វៀតណាម និងការប៉ុនប៉ងធ្វើរដ្ឋប្រហារលើថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ។

[១១:៤៦:១៧]

សុន្ទរកថាចុងក្រោយដែលយើងខ្ញុំយកមកធ្វើការពិភាក្សាគឺ គម្រប់ខួបនៅឆ្នាំ១៩៧៨ ដែលថ្លែងឡើងដោយ ខៀវ សំផន។ ឃើញមាននៅក្នុងឯកសារ E3/169។ សុន្ទរកថានេះក៏ឃើញមាននៅក្នុងឯកសារ E3/562។ តែដំបូងខ្ញុំអានឯកសារ E3/169 ជាមុន។ ឯកសារនេះ គឺនិយាយអំពីសុន្ទរកថាថ្លែងឡើងដោយសមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យក្នុងសន្និបាតមហាជន ដែលប្រព្រឹត្តធ្វើនាឱកាសពិធីបុណ្យខួបលើកទី៣ នៃទិវាមហាជ័យជម្នះថ្ងៃ១៧ ខែមេសា និងទិវានៃការបង្កើតកម្ពុជាប្រជាធិបតេយ្យ។ សុន្ទរកថានេះពាក់ព័ន្ធដោយសារតែក្នុងនេះវារួមមានការឯកភាព និងការគាំទ្រចំពោះគោលនយោបាយរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។

សុន្ទរកថានេះចាប់ផ្តើមដោយលើកពិភាក្សាអំពីមហាជោគជ័យ ថ្ងៃទី១៧ មេសា។ ហើយខ្ញុំនឹងអានអត្ថបទខ្លីមួយ ឃើញនៅមានលេខ S00704515, បារាំងមានលេខ S00004802 ហើយអង់គ្លេសមានលេខ 00000389 ក្នុងនេះសរសេរថា “បច្ចុប្បន្ននេះប្រជាជនកសិករ កម្មករ កសិករ កងទ័ពបដិវត្តន៍របស់យើងបានក្លាយទៅជាម្ចាស់នៃជោគវាសនារបស់ខ្លួនទាំងស្រុង ប្រកបដោយឯករាជ្យភាព និងអធិបតេយ្យភាពពេញលេញ។ ពុំមានពួកចក្រពត្តិនិយម ពួកអាណានិគមនិយម និងពួកមានវណ្ណៈ

ជិះជាន់កេងប្រវ័ញ្ចណាមួយអាចសម្រេចអំពីជោគវាសនារបស់ប្រជាជន កម្មករ កសិករ កងទ័ពបដិវត្តន៍កម្ពុជារបស់យើងបានទៀតឡើយ។ សេចក្ដីថ្លៃថ្នូរ និងកិត្តិយសរបស់ប្រជាជន កម្មករ កសិករកម្ពុជាដែលបានធ្លាក់ក្នុងភក់ជ្រាំអស់ជាច្រើនសតវត្សរ៍ ពេលនេះបានជ្រោងឡើងយ៉ាងខ្ពស់ត្រដែត និងចិញ្ចាចចិញ្ចែង។ សម័យអន្ធការ បានកន្លងផុតទៅ ហើយនឹងមិនអាចវិលត្រឡប់មកវិញបានឡើយ"។

[១១:៤៩:០៦]

អត្ថបទបន្ទាប់មួយទៀត គឺនិយាយអំពីការចោទប្រកាន់ចំពោះវិទ្ធង្សនារបស់វៀតណាម និងការព្រួយបារម្ភរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ខ្មែរERN គឺ S00704517 បារាំង S00004803 អង់គ្លេសមានលេខ 00280391។ សូមដកស្រង់សម្ដី "ពាក់ព័ន្ធទៅនឹងព្រំដែនខាងកើត ការវាយប្រយុទ្ធរវាងយើង និងវៀតណាមមានលក្ខណៈស្វិតស្វាញក្ដៅគគុក និងឥតឈប់ឈរ ដោយហេតុថាប្រទេសវៀតណាមបានបង្កប់ទៅដោយមហិច្ឆតាដ៏ខ្មៅកខ្វក់ក្នុងការលេបទឹកដីកម្ពុជា តាមផែនការសហព័ន្ធឥណ្ឌូចិនរបស់ខ្លួន។ ហើយយួនបាននឹងកំពុងអនុវត្តផែនការនេះបានយ៉ាងខ្ជាប់ខ្ជួន។ ឆ្នាំនេះការវាយប្រយុទ្ធមានលក្ខណៈក្ដៅគគុកជាងឆ្នាំមុន ដោយហេតុថាកលល្បិចនិងទង្វើរបស់យួនក្នុងការលេបទឹកដីកម្ពុជាជាពិសេសការធ្វើវិទ្ធង្សនា ការធ្វើសកម្មភាពចារកម្ម ខ្មាំងបង្កប់ផ្ទៃក្នុង និងការប៉ុនប៉ងធ្វើរដ្ឋប្រហារនានាដើម្បីផ្ដួលរំលំបក្សកុម្មុយនីស្ដកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានទទួលរងបរាជ័យដ៏ជូរចត់។

[១១:៥០:៣៧]

អត្ថបទមួយទៀតដែលខ្ញុំមានបំណងអាន គឺនិយាយអំពីការអំពាវនាវឲ្យកងទ័ពធ្វើការលុបបំបាត់និងបំផ្លិចបំផ្លាញចោលជនឈ្លានពានវៀតណាម ខ្មែរ ERN គឺ S00704591, បារាំងមានលេខ S0000 4804, អង់គ្លេសមានលេខ 00280392។ សូមកែតម្រូវលេខខ្មែរ គឺ S00704519។ សូមដកស្រង់សម្ដី "យើងខ្ញុំបានប្ដេជ្ញាចិត្តដើរតាមគំរូវីរភាពបដិវត្តន៍ថ្លៃថ្នូរឧត្តុង្គឧត្ដមរបស់កងទ័ពបដិវត្តន៍យើង ដោយក្រោកឈរឡើងយ៉ាងខ្ពស់ត្រដែត និងបណ្ដុះនូវគំនិតស្នេហាជាតិបដិវត្តន៍ មោទនភាពបដិវត្តន៍ចំពោះជាតិប្រជាជន កងទ័ពបដិវត្តន៍ បដិវត្តន៍របស់យើង ព្រមទាំងបក្សរបស់យើងឲ្យបានរឹងមាំដូចដែកថែប ដោយតម្កល់ផលប្រយោជន៍របស់ជាតិរបស់វណ្ណៈ របស់ប្រជាជន និងរបស់បដិវត្តន៍ឲ្យខ្ពស់ជាងផលប្រយោជន៍បុគ្គលនិងគ្រួសារ ព្រមទាំងប្រឹងប្រែងអស់កម្លាំងកាយចិត្តដើម្បីបំពេញភារកិច្ចដែលបក្សប្រគល់ជូនដល់យើងគ្រប់រូប ព្រមទាំងដើម្បីរួមចំណែកតាមរយៈសកម្មភាពប្រចាំថ្ងៃរបស់យើង ដើម្បីកម្ចាត់បង់ឲ្យអស់

និងជារៀងរហូតពីទឹកដីកម្ពុជានូវរាល់សត្រូវឈ្លានពានពីគ្រប់ទិសទី ជាពិសេសសត្រូវយួនឈ្លានពាន វាតទីនិយម និងលេបទឹកដី”។

[១១:៥២:៣៣]

អត្ថបទបន្ទាប់ទៀតគឺនិយាយអំពីសារៈសំខាន់នៃការៗអប់រំផ្នែកនយោបាយទៅដល់កម្មាភិបាល ជាពិសេសកម្មាភិបាលនៅក្នុងចលនាបដិវត្តន៍។ ឯកសារនេះគឺពាក់ព័ន្ធនឹងសញ្ញាណដែលថាកម្ពុជាប្រជាធិបតេយ្យគឺជារដ្ឋប្រជាធិបតេយ្យមួយ។ ខ្មែរERN គឺ S00704522, បារាំងមានលេខ S00004806, អង់គ្លេសមានលេខ 00280395។ សូមដកស្រង់សម្ដី “តើយើងត្រូវសិក្សាបច្ចេកទេស និងវិទ្យាសាស្ត្រដែរឬទេ? វាប្រាកដណាស់ ប៉ុន្តែយើងត្រូវបញ្ជាក់ឲ្យច្បាស់ថា យើងមិនសិក្សាបច្ចេកទេសដែលកាត់ផ្ដាច់ពីការងារកសាងប្រទេសជាតិរបស់យើងឡើយ។ ការសិក្សាបច្ចេកទេសជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការអនុវត្តនិងផលិតកម្ម។ ដោយអនុវត្តយ៉ាងដូច្នេះ យើងត្រូវកសាងសេដ្ឋកិច្ចមួយដែលឯករាជ្យពង្រឹងនិងពង្រីកសេដ្ឋកិច្ចឯករាជ្យសម្រាប់ពេលអនាគត។ ចំណុចនេះហើយដែលជាការងារដែលមានលក្ខណៈសមស្របនិងវិទ្យាសាស្ត្រ”។

[១១:៥៤:០៦]

កថាខណ្ឌបន្ទាប់ទៀត គឺលើកឡើងដូចតទៅ “ធ្វើដូច្នេះហើយមហាជនទាំងអស់អាចទទួលចំណេះដឹង ហើយបានដឹងអំពីអំណាចរបស់រដ្ឋខ្លួន។ បាទ សូមកែតម្រូវដែលវាមិនមែនជាអំណាចរបស់រដ្ឋ ហើយវាជាអំណាចរបស់បុគ្គលម្នាក់ៗ។ “រាល់ប្រជាជនទាំងអស់គឺជាម្ចាស់របស់ប្រទេស ម្ចាស់របស់អំណាចនិងក្ដាប់ក្នុងដៃនូវជោគវាសនារបស់ប្រទេស ហើយចូលរួមយ៉ាងសកម្មដល់ការងារកសាងជាតិ។ ដូច្នេះ អំណាចនេះមានលក្ខណៈរឹងមាំខ្លាំង។ យើងបានបង្វឹកកម្មាភិបាលរបស់យើង កម្មាភិបាលនយោបាយ និងកម្មាភិបាលបច្ចេកទេស។ យើងបានបង្វឹកពួកគេនៅក្នុងចលនាបដិវត្តន៍ យើងមានជឿជាក់ថា យើងអាចបណ្ដុះបណ្ដាលពួកគេបន្តិចម្ដងៗ ប្រសិនបើយើងបណ្ដុះបណ្ដាលកម្មាភិបាលរបស់យើងនៅតែក្នុងសាលារៀន ដោយកាត់ផ្ដាច់ពីចលនាបដិវត្តន៍របស់មហាជន យើងមិនអាចធ្វើការឆ្លើយតបទៅនឹងតម្រូវការនៃចលនាបដិវត្តន៍នេះបានឡើយ។

កថាខណ្ឌពីរទៀតនៅខាងក្រោម គឺឯកសារនេះលើកឡើងនិយាយអំពីបញ្ហាចក្រពត្តិនិយម និងវាតទីនិយម។ សូមដកស្រង់សម្ដី “ក្នុងរយៈពេលកន្លងមក កងកម្លាំងបដិវត្តន៍របស់យើងបានកសាងជាកម្លាំង ប្រជាជនរបស់យើងបានវាយដើម្បីការពារប្រឆាំងនឹងដបិវត្តន៍ពួកលេបទីនិយម និងពួកវាតទី

និយមមកពីគ្រប់ប្រភពទាំងអស់ ដែលបានធ្វើ -- ដើម្បីធ្វើយ៉ាងណាឲ្យមានសង្គមនិយមរបស់យើង និងធ្វើឲ្យផលិតកម្មយើងកើនឡើង"។

[១១:៥៥:៥០]

កថាខណ្ឌបន្ទាប់សរសេរថា "ក្នុងពេលតែមួយប្រជាជនរបស់យើងមានការពេញចិត្ត ពេញថ្លើមចំពោះរបបសង្គមនិយមសម្ពហភាពរបស់យើងកាន់តែខ្លាំងឡើងៗ។ ពួកគេយល់កាន់តែច្បាស់ឡើងៗអំពីអានុភាពនៃរបបនេះ ដែលអាចធ្វើការការពារប្រទេសប្រកបដោយប្រសិទ្ធភាព កសាងប្រទេសឲ្យបានខ្លាំងក្លា និងលើកកម្ពស់កម្រិតជីវភាពប្រជាជនបានយ៉ាងឆាប់រហ័ស ប្រកបដោយឯករាជ្យភាព និងអធិបតេយ្យភាព និងដោយពឹងផ្អែកលើកម្លាំងខ្លួនឯងផ្ទាល់ក្នុងកម្រិតខ្ពស់"។

ក្រោមនេះបន្តិច ខ្មែរ ERN គឺ S00704525, បារាំងមានលេខ S00004807, អង់គ្លេសមានលេខ 00280397។ ដកស្រង់សម្ដី "ការដែលយើងបានការពារប្រទេសរបស់យើងប្រកបដោយជោគជ័យ ដោយបានកម្ទេចជាផេះផង់នូវរាល់សកម្មភាពបំផ្លិចបំផ្លាញរបស់ចក្រពត្តិនិយមអាមេរិក និងបក្ខពួក ការដែលយើងបានបំផ្លាញដោយជោគជ័យនូវសកម្មភាពបំផ្លិចបំផ្លាញរបស់ពួកវាតទីនិយម ពួកប្រតិកិរិយាពីគ្រប់ទិសទី ជាពិសេសទង្វើឧក្រិដ្ឋរបស់យួនឈ្លានពានវាតទីនិយម និងលេបទឹកដី និងការដែលយើងត្រូវលើកកម្ពស់សេដ្ឋកិច្ចរបស់យើងក្នុងរយៈពេលមួយខ្លី កសាងប្រទេសរបស់យើងយ៉ាងឆាប់រហ័សលើគ្រប់វិស័យ យ៉ាងមហាលោតផ្លោះ មហាអស្ចារ្យ និងលើកកម្ពស់ -- កម្រិតជីវភាពរបស់ប្រជាជនយើងបានយ៉ាងឆាប់រហ័សប្រកបដោយឯករាជ្យភាព និងអធិបតេយ្យភាព ដោយពឹងផ្អែកលើកម្លាំងរបស់ខ្លួនឯងផ្ទាល់ បានជំរុញឲ្យប្រទេសជាមិត្តជិតឆ្ងាយទាំងអស់ព្រមទាំងប្រជាជាតិទាំងឡាយដែលស្នេហាឯករាជ្យភាព និងយុត្តិធម៌នៅក្នុងពិភពលោកសម្ដែងនូវសមាណចិត្តរបស់ខ្លួនចំពោះកម្ពុជាហើយបន្តការគាំទ្រកាន់តែសកម្មឡើងពីមួយថ្ងៃទៅមួយថ្ងៃ"។

[១១:៥៧:៥៧]

គាត់បានបញ្ចប់សុន្ទរកថានេះដោយលើកឡើងអំពាវនាវឲ្យមានការរួបរួមគ្នាចំពោះការជោគជ័យនេះ។ គាត់បានលើកឡើងដូចតទៅ "យើងត្រូវតែរួបរួម និងអភិវឌ្ឍជោគជ័យរបស់យើង ហើយបន្តវាយសម្រុកទៅមុខ។ ដូច្នេះយើងត្រូវតែបន្តប្រយុទ្ធប្រឆាំងយ៉ាងអង់អាចដើម្បីបំពេញភារកិច្ចរបស់បក្សទៅតាមអង្គភាព និងទៅតាមជំនាញរបស់ខ្លួនរៀងៗខ្លួន។ ជាក់ស្ដែងភារកិច្ចទី១ យើងត្រូវធ្វើការការពារប្រទេសបដិវត្តន៍ អំណាច ប្រជាជន កងទ័ព បក្ស និងពូជសាសន៍កម្ពុជាជាដាច់ខាត។ យើងអាចធ្វើការ

ការពារប្រទេសយើងបានតែក្នុងលក្ខខណ្ឌ ដែលយើងអនុវត្តតាមមាគ៌ារបស់បក្សទាំងនៅក្នុងការការពារប្រទេសពីខាងក្រៅ និងពីខាងផ្ទៃក្នុងប្រទេស។ រាល់អង្គភាពទាំងអស់នៅទូទាំងប្រទេសត្រូវតែបន្តបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់”។

មុននេះបន្តិច លោក លោកស្រីជាទីគោរព! ខ្ញុំបានយោងទៅលើឯកសារមួយ ដែលក្នុងនោះមានការកត់ត្រាប្រតិចារឹកនៃសុន្ទរកថានេះ។ ឯកសារ E3/562 មូលហេតុដែលឯកសារទី២នេះ វាគួរឲ្យចាប់អារម្មណ៍ និងមានភាពពាក់ព័ន្ធដោយសារតែឯកសារមួយនេះរួមមានសេចក្តីសម្រេចមួយចំនួនដែលបានអនុម័តនៅក្នុងកិច្ចប្រជុំមហាជន ដែលក្នុងពេលនោះ ខៀវ សំផន បានថ្លែងសុន្ទរកថា។ សេចក្តីសម្រេចនោះគឺវែងណាស់ ក៏ប៉ុន្តែខ្ញុំនឹងដកស្រង់ដោយខ្លីៗតែប៉ុណ្ណោះចេញពីសេចក្តីសម្រេចរួម។ ខ្មែរ ERN គឺមានលេខ 00249989, បារាំងមានលេខ 00280379, អង់គ្លេសមានលេខ 00010563 សេចក្តី -- ឯកសារនេះមានលើកឡើងដូចតទៅ ខាងផ្នែកការពារជាតិ សេចក្តីសម្រេចខាងក្រោមមានដូចតទៅត្រង់ចំណុចលេខ៤៖

“៤) បណ្តេញចេញ និងកម្ទេចឲ្យអស់ពួកឈ្លានពាន ពួកវាតទីនិយមវៀតណាម សាហាវព្រៃផ្សៃឲ្យចេញផុតពីទឹកកម្ពុជា។ ៥) កម្ទេចឲ្យអស់រាល់បណ្តាភ្នាក់ងារពួកឈ្លានពាន ពួកវាតទីនិយមវៀតណាម សាហាវព្រៃផ្សៃដែលមាននៅក្នុងអង្គភាព ព្រមទាំងទឹកដីប្រទេសកម្ពុជាយើងជារៀងរហូត។ ទី៦) កម្ទេចឲ្យអស់រាល់បណ្តាភ្នាក់ងារ សេ.អ៊ី.អា ដែលមាននៅក្នុងអង្គភាព និងដឹកដីប្រទេសកម្ពុជាជារៀងរហូត”។ និងចំណុចចុងក្រោយ ចំណុចទី៩ ខ្ញុំដកស្រង់ “៩) ពង្រឹងសីលធម៌ កម្លាំងចិត្តកម្លាំងកាយរៀងៗខ្លួន តាមអង្គភាពនីមួយៗ និងរបស់ជាតិទាំងមូល ព្រមទាំងពង្រីក ពង្រឹងការរួបរួមជាតិជាការតស៊ូ ក្នុងការកម្ទេចចោលខ្មាំងតាមគ្រប់រូបភាពទាំងអស់ ជាពិសេសពួកឈ្លានពាន ពួកខ្មាំងវាតទីនិយមវៀតណាម ដើម្បីរក្សាការពារជាតិ និងជាតិសាសន៍កម្ពុជាជារៀងរហូត”។

[១២:០១:៤១]

លោក លោកស្រីចៅក្រមជាទីគោរព! ទាំងអស់នេះហើយគឺជាសេចក្តីថ្លែងការណ៍សុន្ទរកថាដែលយើងខ្ញុំសូមបង្ហាញនៅក្នុងថ្ងៃនេះ។ នៅពេលនេះខ្ញុំសូមចូលទៅដល់ប្រធានបទមួយផ្សេងទៀតដែលនិយាយអំពីការឆ្លើយតបរបស់ ខៀវ សំផន ដោយអង្គការលើកលែងទោសអន្តរជាតិពាក់ព័ន្ធទៅនឹងការរំលោភបំពាននៅក្នុងប្រទេសកម្ពុជា។ តែនេះជាពេលវេលាសម្រាក ត្រូវឈប់សម្រាកសិន ឬក៏អនុញ្ញាតខ្ញុំបន្តទៀតលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលវេលាសមស្របសម្រាកពិសាថ្ងៃត្រង់ហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៥:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការដាក់ឯកសារ អង្គជំនុំជម្រះធ្វើការកត់សម្គាល់មួយដោយសារនៅក្នុងដីកាបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន ចូលមកចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ ការដាក់បង្ហាញឯកសារនេះ គឺផ្អែកទៅលើមូលដ្ឋាននៃបណ្តាឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងគាត់ ហើយការប្រមើលមើលនៅក្នុងកាលវិភាគពេលវេលា គឺទំនងជាត្រូវការប្រើប្រាស់ពេលវេលា១ថ្ងៃ គឺពីម្សិលមិញមួយព្រឹក ហើយនៅ -- ពីម្សិលមិញរសៀល ហើយនិងថ្ងៃនេះមួយព្រឹក។ ប៉ុន្តែឥឡូវនេះមិនទាន់ចប់ទេ ដូច្នេះអង្គជំនុំជម្រះបង្គាប់ឲ្យលោក ខៀវ សំផន ចូលរួមពីចម្ងាយនៅឯបន្ទប់ឃុំខ្លួនខាងក្រោមនេះ ដើម្បីតាមដានកិច្ចដំណើរការសវនាការក្នុងការដាក់បង្ហាញឯកសារដែលធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន ខ្លួនឯងរហូតដល់ចប់។

[១៣:៣៧:១៤]

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាបន្តការដាក់បង្ហាញឯកសារ។

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន សួស្តីលោក លោកស្រីចៅក្រម អស់លោក លោកស្រីជាទីគោរព!

ក្នុងបទបង្ហាញចុងក្រោយរបស់ខ្ញុំ ខ្ញុំបានកំណត់អត្តសញ្ញាណឯកសារ E3/201 ដែលសុន្ទរកថាខែមេសា ឆ្នាំ១៩៧៧ ថ្លែងឡើងដោយ ខៀវ សំផន។ នៅពេលនេះ ខ្ញុំផ្តល់ សូមផ្តល់លេខ ERN ជាភាសាអង់គ្លេស ហើយវាពាក់ព័ន្ធទៅនឹងអត្ថបទដែលខ្ញុំអានគឺ 00419512 -- 513 ដល់ 513, 514, 516, 517។

ពាក់ព័ន្ធទៅនឹងសុន្ទរកថាថ្លែងឡើងដោយ ខៀវ សំផន នេះគឺថាធ្វើឡើងក្នុងអំឡុងឆ្នាំ៧៥ ដល់ ៧៩។ ខ្ញុំកត់សម្គាល់ចំណុចពាក់ព័ន្ធមួយទៀតផងដែរ គឺត្រង់ថា សុន្ទរកថារំឭកខួបទាំងអស់គឺបានធ្វើឡើងក្រោយថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ សេចក្តីសម្រេចចុះពេលនោះ។ ឯកសារនេះគឺយើងយកមកពិភាក្សាគ្នាកាលពីលើកមុន គឺឯកសារលើកឡើងកាលពីម្សិលមិញ ឯកសារដែលពាក់ព័ន្ធសេចក្តីសម្រេចឲ្យកម្ទេច សិទ្ធិកម្ទេចនៅក្នុងខាងក្នុងខាងក្រៅជួរ។ គឺឯកសារ E3/12 ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ៧៦ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ដែលនៅក្នុងនោះ ខៀវ សំផន ជាសមាជិកផងដែរ។ ហើយខ្ញុំបានបញ្ជាក់ហើយថា សុន្ទរកថាថ្លែងលើខួបរបស់សម័យនោះគឺថាវាបង្ហាញអំពីចំណុចហ្នឹងផងដែរ។

[១៣:៣៩:៣៥]

ក្រុមឯកសារមួយក្រុមទៀត ដែលយើងខ្ញុំនឹងជូនឲ្យលោក លោកស្រីចៅក្រមពិនិត្យនោះ គឺកំណត់ហេតុមួយក្រុមតូចដែលពាក់ព័ន្ធទៅនឹងរបាយការណ៍ និងការឆ្លើយតប ឆ្លើយតបដោយអង្គការលើកលែងទោសអន្តរជាតិ ដែលចម្លើយតបនេះ ដើម្បីឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺថាបានជ្រាបពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពីឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងអស់នេះគឺពាក់ព័ន្ធជាមួយនឹងខៀវ សំផន ហើយបានឆ្លើយតបទៅគាត់ដោយផ្ទាល់ ហើយក៏វាពាក់ព័ន្ធទៅនឹងជនជាប់ចោទផ្សេងទៀតផងដែរ ដោយសារតែឯកសារនេះជារួមគឺឆ្លើយតប ទៅនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងសកម្មភាពរបស់រដ្ឋាភិបាលនោះ។

ឯកសារដំបូងនៅក្នុងបណ្តុំឯកសារទាំងនេះ គឺឯកសារ D84/2.5 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ១៩៧៧ បាទសូមអធ្យាស្រ័យមិនមែន ២០ ទេ គឺ២៨ -- ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ៧៨ កែតម្រូវដោយសហព្រះរាជអាជ្ញា។

[១៣:៤១:០១]

នៅពេលនោះគឺមានបុគ្គលម្នាក់ ដែលជាលេខាធិការរបស់អង្គការលើកលែងទោសអន្តរជាតិ ដែលបានសរសេរលិខិតឆ្លើយតបទៅលោក ខៀវ សំផន។ ហើយឯកសារដើមជាភាសាបារាំង នេះជាឯកសារបកប្រែជាភាសាខ្មែរតែប៉ុណ្ណោះ។ ឯកសារមួយនេះគឺលើកឡើងអំពីការធ្វើមាតុភូមិនិវត្តរបស់

ប្រជាជនកម្ពុជាមកប្រទេសខ្លួនវិញ។ ហើយអត្ថបទដែលពាក់ព័ន្ធនោះគឺមានដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ខ្ញុំសរសេរជូនលោកនៅក្នុងថ្ងៃនេះ ពាក់ព័ន្ធទៅនឹងបញ្ហាដែលធ្វើឲ្យមានការព្រួយបារម្ភនៅក្នុងឆាកអន្តរជាតិ ហើយសង្ឃឹមថាលោកនឹងអាចផ្ដល់យោបល់បានពាក់ព័ន្ធទៅនឹងជោគវាសនារបស់ប្រជាពលរដ្ឋ២៦នាក់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ បុគ្គល២៦នាក់នេះ គឺប្រព្រឹត្តខុសនៅសិរីសោភ័ណ ខេត្តបាត់ដំបង ហើយអ្នកទាំងអស់នេះត្រូវបានរាយការណ៍ថា ធ្វើដំណើរឆ្លងកាត់ទៅព្រំដែនថៃ នៅថ្ងៃ១៧ ខែតុលា។ របាយការណ៍នៅថ្ងៃទី២៣ អាជ្ញាធរថៃបានបញ្ជូនអ្នកទាំងអស់នេះមកអាជ្ញាធរកម្ពុជាវិញនៅព្រំដែនអារញ្ញប្រទេស"។

កថាខណ្ឌនៅក្នុងឯកសារនេះ គឺបានលើកឡើងទៀតថា "នៅក្រោយការបញ្ជូនទាំង២៦នាក់នោះបន្តិចមក អត្ថបទសារព័ត៌មានជាច្រើនបានសរសេរថា ពួកគត្រូវបានគេប្រហារជីវិតនៅកម្ពុជា។ ជាពិសេសមានរបាយការណ៍ដោយឡែកមួយបានអះអាងថា មនុស្សចំនួន២០នាក់បានត្រូវប្រហារជីវិត ហើយ៦នាក់ទៀតត្រូវបានជាប់ឃុំឃាំង"។ ព័ត៌មានផ្សេងទៀតបានផ្សាយថា ក្រុមមនុស្សទាំង២៦នាក់នោះត្រូវបានប្រហារជីវិត ក្រោយពីបានស្នាក់នៅរយៈពេល ៣ថ្ងៃនៅមង្គលបុរី។

[១៣:៤៣:០៣]

នៅចំពោះមុខនៃការចោទប្រកាន់ធ្ងន់ធ្ងរនេះ អង្គការលើកលែងទោសអន្តរជាតិអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យបើកការស៊ើបអង្កេតមួយ និងបំភ្លឺអំពីជោគវាសនារបស់មនុស្សទាំង២៦នាក់នោះ។

ខ្ញុំសូមទាញចំណាប់អារម្មណ៍របស់លោក ទៅលើរបាយការណ៍ដែលមានជាបន្តបន្ទាប់ស្ដីអំពីការគំរាមកំហែង ឬអំពើព្រៃផ្សៃដែលប្រជាពលរដ្ឋកម្ពុជាត្រូវបានរងពីសំណាក់អាជ្ញាមូលដ្ឋាននៅតំបន់មួយចំនួននៃប្រទេសកម្ពុជា។ ពាក្យចចាមអារាមដែលគួរឲ្យភ្ញាក់ផ្អើលកំពុងតែត្រូវផ្សព្វផ្សាយជាច្រើនលើកច្រើនគ្រាអំពីការនាំប្រជាពលរដ្ឋ ដែលអ្នកតំណាងអាជ្ញាធរមួយចំនួនចាត់ទុកថាជាខ្មាំង ចេញពីកន្លែងទៅធ្វើការ ទៅទិសដៅមិនស្គាល់ ដោយមិនបានជូនព័ត៌មានអំពីវាសនារបស់ពួកគេនៅក្នុងក្រុមគ្រួសារពួកគេឡើយ។ របាយការណ៍ខ្លះក៏បាននិយាយអំពីការប្រហារជីវិតដោយមិនមានការជំនុំជម្រះ ហើយនៅពេលថ្មីៗនេះ គេមានរាយការណ៍ថាមានជំរំមួយ ដែលមានគ្រួសារចំនួន១.២០០ស្នាក់នៅ ស្ថិតនៅក្នុងតំបន់ភ្នំធិបតី នៅក្នុងខាងកើតក្រុងបាត់ដំបង។

[១៣:៤៤:១៥]

ខាងក្រោមបន្ថិច គឺមានសរសេរដូចតទៅ "ដូចដែលខ្ញុំបានចង្អុលបញ្ជាក់នៅក្នុងលិខិតចុះថ្ងៃ១១ ខែឧសភា ឆ្នាំ១៩៧៦ អង្គការលើកលែងទោសអន្តរជាតិមិនមានលទ្ធភាពធ្វើអត្ថាធិប្បាយអំពីសភាវពិត និងត្រឹមត្រូវនៃអំណះអំណាងទាំងនោះទេ។ ទាំងបីជាយ៉ាងណាក៏ដោយ ហេតុដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមិនបានធ្វើអត្ថាធិប្បាយពីហេតុការណ៍នេះទាល់តែសោះនោះ បានធ្វើឲ្យអង្គការយើង និងអង្គការអន្តរជាតិដទៃទៀតមានចំណាប់អារម្មណ៍ និងដោយចង់ដឹងយ៉ាងខ្លាំងអំពីទស្សនៈរបស់រដ្ឋាភិបាលលោក"។

លោកប្រធានគឺនៅក្នុងស្មារតីនេះហើយ ដែលយើងខ្ញុំសូមឲ្យលោកពិចារណាលើកសំណើឲ្យកម្ពុជាប្រជាធិបតេយ្យទទួលគណៈប្រតិភូមួយក្រុមរបស់អង្គារលើកលែងទោសអន្តរជាតិក្នុងគោលបំណងបំបាត់កង្វល់ និងសេចក្ដីបារម្ភជាទូទៅចំពោះរឿងនេះ។ លិខិតនេះគឺបញ្ចប់ដោយរៀបរាប់ថា "សូមលោកប្រធានមេត្តាទទួលយកនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ, ម៉ាតាំង អេនណាល់ *(Martin Ennals)* អគ្គលេខាធិការអង្គការលើកលែងទោសអន្តរជាតិ។ នៅក្នុងនេះគឺមានឈ្មោះបុគ្គលមួយចំនួនដែលត្រូវបានគេបញ្ជូនលិខិតនេះទៅ យោងតាមអង្គការលើកលែងទោសអន្តរជាតិ គឺអាជ្ញាធរថៃនេះ បានបញ្ជូនមកដល់អាជ្ញាធរកម្ពុជានៅក្នុងហ្នឹងមានឈ្មោះបុគ្គលដែលទទួលបានលិខិតទាំងអស់នេះ"។ នៅក្នុងសំណុំរឿងគឺយើងមើលឃើញថាវាជាកំណត់ហេតុ -- បណ្ដុំនៃកំណត់ហេតុជាច្រើន ឯកសារទាំងអស់នោះមានលេខ E3/961។ ឯកសារ E3/961 គឺជារបាយការណ៍ ឬតារាងដែលចេញដោយកម្ពុជាប្រជាធិបតេយ្យ គឺ ដោយគណៈកម្មាធិការយោធាបដិវត្តន៍ភូមិភាគពាយព្យ មានចំណងជើងថា "សំបុត្រផ្ញើមនុស្សជូនអង្គការ"។

[១៣:៤៦:១១]

ឯកសារនេះសរសេរថា "យើងខ្ញុំសូមបញ្ជូនពួកក្បត់ដែលថៃបញ្ជូនមកកម្ពុជាវិញចំនួន២៥នាក់" ដូចមានឈ្មោះខាងក្រោមនេះ យើងខ្ញុំនឹងព្យាយាមបង្ហាញតារាងនេះនៅលើអេក្រង់។

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេល ដែលយើងប្រៀបធៀបឈ្មោះនៅក្នុងតារាងនេះដែលផ្ញើជូនទៅដល់អង្គការដែលក្នុងនោះគឺមានមនុស្ស ២៥នាក់ជាជនក្បត់។ ហើយយើងប្រៀបធៀបតារាងហ្នឹងជាមួយបញ្ជីឯកសារ D84/2.5 ដែលជាលិខិតរបស់អង្គការលើកលែងទោសអន្តរជាតិនោះគឺថាបុគ្គលទាំងហ្នឹងមានឈ្មោះស្រដៀងគ្នា។ ឧទាហរណ៍ថា បុគ្គលទី១ នៅក្នុងបញ្ជីនេះថាមានឈ្មោះថា ច្រុក យឹម អាយុ៣១ ភេទប្រុស ហើយបុគ្គលនេះមាននៅក្នុងលេខ៤ ក្នុងលិខិតរបស់អង្គការលើកលែង

ទោសអន្តរជាតិ។ លេខ៤ គឺ ប៊ុត -- លេខ២ គឺ យឹម ឡេត អាយុ៣៩ឆ្នាំ ប្រុស មាននៅក្នុងលិខិតរបស់អង្គការលើកលែងទោសជួរទី -- បុគ្គលលេខ១៥ ហើយដើម្បីជាឧទាហរណ៍បញ្ជាក់ទៀតនៅក្នុងនេះ លេខ៤ ប៊ុត ធិន អាយុ២៥ឆ្នាំ ប្រុស បុគ្គលរូបនេះនៅក្នុងជួរ -- នៅក្នុងបញ្ជីឈ្មោះលេខ៧ នៃលិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ។ ហើយយើងឃើញថាចំពោះអ្នកផ្សេងទៀតនៅក្នុងនេះគឺដូចគ្នានឹងបុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជីរបស់អង្គការលើកលែងទោសអន្តរជាតិ ដែលអ្នកទាំងអស់នោះបាត់ខ្លួនតាមការរៀបរាប់របស់អង្គការលើកលែងទោសអន្តរជាតិ។

អ្វីដែលគួរឲ្យកត់សម្គាល់នោះទៀតផងដែរ គឺពាក់ព័ន្ធនឹងលិខិត តារាងដែលបញ្ជូនទៅអង្គការមួយនេះ គឺករណីដែលថា ឯកសារនេះត្រូវបានគេចាត់ទុកនៅក្នុងសំណុំរឿង០០១ ហើយប្រតិចារឹកដែលយោង -- ឯកសារដែលយោងហ្នឹងគឺថា D8288/4. --

**អ្នកបកប្រែ៖**

សូមអនុញ្ញាតលោកប្រធានឲ្យព្រះអាជ្ញាបញ្ជាក់លេខឯកសារឡើងវិញ។

**លោក អាប់ឌុលឡាក់ ថារីក៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់លេខឯកសារឡើងវិញ ព្រោះស្តាប់ -- អ្នកបកប្រែស្តាប់អត់ទាន់ទេ។

[១៣:៤៨:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ជាការពិត ខ្ញុំអាចបញ្ជាក់បាន។ សំណុំរឿងឯកសារលេខគឺ ឯកសារនេះមានលេខដូចតទៅពីសំណុំរឿង០០១ D288/4.28.1 ចុះថ្ងៃ០៨ ខែមិថុនា ឆ្នាំ២០០៩។ ការបញ្ជាក់ដោយ ឌុច នោះគឺថារបាយការណ៍កំណត់ហេតុនេះមានយថាភាពជាឯកសារពិត ហើយដោយក្នុងនោះក៏មានចំណារនៅចុងក្រោយ ហើយយើងឃើញនៅក្នុងប្រតិចារឹកត្រង់ខ្មែរលេខ ERN 00338771 រហូតទៅដល់ 774, បារាំងមានលេខ 00338661 ទៅដល់ 665, អង់គ្លេសមានលេខ 00338548 ទៅដល់លេខ 51។

អង្គការលើកលែងទោសអន្តរជាតិបានបន្តបង្ហាញអំពីការព្រួយបារម្ភពាក់ព័ន្ធទៅ នឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យបន្ថែមទៀតផងដែរ។ ហើយជាការពិត នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ អង្គការលើកលែងទោសអន្តរជាតិបានចេញសេចក្តីប្រកាស

ព័ត៌មានមួយ គឺឯកសារលេខ D313/1.2.331 គឺសេចក្ដីថ្លែងការណ៍ព័ត៌មាននេះ គឺដូចទៅនឹងឯកសារដែលយើង មើលពីមុន។ នេះគឺជាឯកសារតែមួយទំព័រតែប៉ុណ្ណោះ។ អង្គការសិទ្ធិមនុស្សអន្តរជាតិបាននិយាយថា "នៅក្នុងខែកុម្ភៈ ឆ្នាំនេះ ខ្លួនបានធ្វើសេចក្ដីអំពាវនាវឲ្យលោកប្រធាន ខៀវ សំផន ដើម្បីឲ្យត្រួតពិនិត្យមើលជោគវាសនារបស់ពលរដ្ឋកម្ពុជាចំនួន២៦រូប ដែលត្រូវបានប្រទេសថៃចាប់ បញ្ជូនដោយបង្ខំមកកម្ពុជាវិញ នៅខែកក្កដា ឆ្នាំ១៩៧៦។ ជនទាំង២៦រូបនោះ ភាគច្រើនជាកសិករ ប៉ុន្តែរួមមានទាំងកុមារ១១ឆ្នាំម្នាក់ផងដែរ ដែលត្រូវបានគេរាយការណ៍នៅពេលក្រោយមកទៀតថា ត្រូវបានគេប្រហារជីវិត បន្ទាប់ពីវិលត្រឡប់ចូលប្រទេសកម្ពុជាបានមួយរយៈពេលខ្លី"។

[១៣:៥១:០០]

វំលងមួយកថាខណ្ឌ សេចក្ដីប្រកាសព័ត៌មាននេះលើកឡើងថា "សេចក្ដីអំពាវនាវដែលផ្ញើទៅលោកប្រធាន ខៀវ សំផន គឺជាសំបុត្រមួយច្បាប់ដែលបាននិយាយផង អំពីរបាយការណ៍ដែលបានលើកឡើងអំពីការសង្ខេបការប្រហារជីវិត និងការធ្វើបាបលើប្រជាពលរដ្ឋ ធ្វើដោយអាជ្ញាធរមូលដ្ឋាននៅតាមតំបន់មួយចំនួនក្នុងកម្ពុជា។ រីឯចម្ងល់នាពេលមុន ដែលសួរដោយអង្គការលើកលែងទោសអន្តរជាតិចំពោះរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ លិខិតនោះនៅមិនទាន់ទទួលបានចម្លើយតបនៅឡើយទេ"។

លោក លោកស្រីចៅក្រមជាទីគោរព! យើងខ្ញុំសូមចូលទៅដល់ឯកសារបន្ទាប់មួយទៀត គឺឯកសារនេះ ជាថ្មីម្ដងទៀត គឺវាពាក់ព័ន្ធ ដោយសារវាបានបង្ហាញអំពីការព្យាយាមរបស់អង្គការលើកលែងទោសអន្តរជាតិផ្សព្វផ្សាយជាសាធារណៈ អំពីការចោទប្រកាន់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា។ ឯកសារនេះ គឺ D84-ឧបសម្ព័ន្ធ១-០១ ឯកសារ D84ឧបសម្ព័ន្ធ(ក)០១។ ឯកសារចុះឆ្នាំ៧៥ ដល់៧៦ របាយការណ៍លើកលែងទោសអន្តរជាតិដែលវាចេញផ្សាយនៅក្នុងឆ្នាំ៧៧នោះទេ។ ខ្មែរ ERN គឺ 00597825, បារាំងមានលេខ 00607934, អង់គ្លេសមានលេខ 00004213។ ការដកស្រង់ដែលខ្ញុំសូមលើកឡើងនោះ គឺមានដូចតទៅ៖

[១៣:៥៣:០៨]

"ក្នុងរយៈពេល១២ខែ ដែលបន្ទាប់ពីប្រ្កុង -- ក្នុងអំឡុង១២ខែ ដែលបានកន្លងផុតទៅ ចាប់តាំងពីរាជរដ្ឋាភិបាលនៃសហព័ន្ធជាតិខ្មែរប្រ្កុង ដែលបច្ចុប្បន្ននេះហៅថា "រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ" បានចូលកាន់អំណាច ចំនួនកើនឡើងនៃរបាយការណ៍ដែលមានជនភៀសខ្លួនត្រូវបានផ្សព្វផ្សាយ

ក្នុងសារព័ត៌មានអន្តរជាតិ។ របាយការណ៍ទាំងនេះបានលើកឡើងអំពីការប្រហារជីវិតមានលក្ខណៈទូលាយ។ របាយការណ៍នេះពាក់ព័ន្ធទៅនឹងមេដឹកនាំចំនួន៧រូប នៃអតីតរដ្ឋាភិបាល លន់ នល់ ដែលមានឈ្មោះថា ជនក្បត់កំពូលនឹងត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយសមាជជាតិនៃប្រជាជនកម្ពុជាលើកទី២ កាលពីខែកុម្ភៈ ឆ្នាំ១៩៧៥។ មេដឹកនាំចំនួន៤រូប ក្នុងចំណោមមេដឹកនាំទាំង៧រូប បានភៀសខ្លួនចេញប្រទេសកម្ពុជាមុនកងទ័ពរំដោះបានចូលមកទីក្រុងភ្នំពេញ។ នៅខែវិច្ឆិកា ឆ្នាំ៧៥ ឧបនាយករដ្ឋមន្ត្រី អៀង សារី បានបញ្ជាក់ការអះអាងនៅក្នុងពេលដំណើរការទស្សនកិច្ចទៅកាន់ទីក្រុងបាងកក ថាមេដឹកនាំ៣រូបនៃរបបចាស់ ត្រូវបានប្រហារជីវិតហើយ"។

[១៣:៥៤:១៣]

ខ្ញុំសូមកត់សម្គាល់សម្រាប់ប្រតិចារឹកថា ឯកសារពាក់ព័ន្ធមួយទៀតគឺ D313/1.2.352 គឺឯកសារ E3/3316។ ឯកសារចុះថ្ងៃទី៣0 ខែមីនា ឆ្នាំ១៩៧៨ ឯកសារសេចក្តីប្រកាសព័ត៌មានអង្គការលើកលែងទោសអន្តរជាតិ ដែលអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាឆ្លើយតបទៅនឹងរបាយការណ៍ចោទប្រកាន់អំពីការប្រហារជីវិត។

ឯកសារមួយទៀត គឺE109 -- E190.1.312 ឯកសារចុះខែកក្កដា ឆ្នាំ៧៨។ គឺលើកឡើងអំពីការរំលោភសិទ្ធិមនុស្សដែលមិនត្រូវបានឆ្លើយតបដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារនេះក៏បានលើកឡើងអំពីបទប្បញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះគឺលើកឡើងការព្រួយបារម្ភពាក់ព័ន្ធទៅនឹងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា តាមការយល់ឃើញរបស់អង្គការលើកលែងទោសអន្តរជាតិ។

[១៣:៥៥:៥២]

មានឯកសារពីរផ្សេងទៀតដែលក៏ពាក់ព័ន្ធទៅនឹងបញ្ហានេះផងដែរ។ ខ្ញុំសូមកត់សម្គាល់តែប៉ុណ្ណោះមិនអានទេ។ លិខិតពីរពីមុននោះ គឺបានសរសេរទៅលោក ខៀវ សំផន D84/2.3 និង D84/2.4។ ឯកសារទាំងពីរនេះមិនមាននៅក្នុងបញ្ជីនោះទេ ដូច្នេះហើយខ្ញុំមិនលើកឡើងនោះឡើយ -- លើកឡើងបង្ហាញនោះឡើយ គ្រាន់តែធ្វើការកត់សម្គាល់បញ្ជាក់ ដែលបញ្ជាក់ថាឯកសារនេះពាក់ព័ន្ធទៅនឹងការឆ្លើយតប ឬក៏លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ បញ្ជូនការព្រួយបារម្ភទៅឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានដឹងតែប៉ុណ្ណោះ។ ហើយជាការពិតគឺនៅក្នុងលិខិតទាំងពីរនោះគឺថាបានលើកឡើងអំពីការចោទប្រកាន់ទាំងឡាយដែលគេបានលើកឡើង។

លោក លោកស្រីចៅក្រម បណ្ដុំឯកសារមួយទៀតដែលយើងខ្ញុំសូមបង្ហាញផងដែរនោះ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ ខៀវ សំផន ទាក់ទងទៅនឹងមុខងាររបស់ក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារដែលពាក់ព័ន្ធនោះ គឺថាមានលេខ E3/182។ កំណត់ហេតុចុះថ្ងៃ០៩ ខែតុលា ឆ្នាំ៧៥ ដែលខ្ញុំបានលើករួចមកហើយ ដែលនៅពេលនោះសមមិត្តលេខា ដែលនៅពេលនោះ ខៀវ សំផន បានត្រូវបានលើកឡើងអំពីបញ្ហាពាណិជ្ជកម្ម។

[១៣:៥៨:៥៩]

នៅក្នុងឯកសារនេះសមមិត្ត ធុច ឬក៏ កុយ ធួន ត្រូវបានចាត់តាំងឲ្យទទួលភារៈលើពាណិជ្ជកម្មអន្តរជាតិ។ ហើយយើងដឹងហើយ តាមកំណត់គឺថា ធុច ឬ កុយ ធួន នេះត្រូវបានគេសម្លាប់ចោលហើយក្នុងនេះមាន វន នៅជួរទី៧ នៃឯកសារ គឺ វន វ៉េត ទទួលភារៈឧស្សាហកម្មខាងផ្លូវដែក និងខាងនេសាទ ហើយបុគ្គលរូបក៏ត្រូវបានគេសម្លាប់ចោលដែរនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ។

អ្វីដែលសំខាន់នោះ គឺថាខ្ញុំសូមបង្ហាញតាមរយៈឯកសារនេះ នៅថ្ងៃទី១០ ខែ១០ ឆ្នាំ២០១២ សហសេវិករបស់ខ្ញុំក៏បានបង្ហាញអំពីតួនាទីរបស់ក្រសួងពាណិជ្ជកម្ម។ ដូច្នេះខ្ញុំមិនចាំបាច់លើកលម្អិតនោះទេ ខ្ញុំគ្រាន់តែបញ្ជាក់អំពីភាពពាក់ព័ន្ធនៃឯកសារនេះតែប៉ុណ្ណោះ។ ឯកសារនេះមានលេខ E3/233 ដែលនៅក្នុងនេះ ខៀវ សំផន ទទួលភារៈការទិញទំនិញពីបរទេស។

[១៣:៥៩:២០]

ឯកសារ E3/220 ដែលលោក លោកស្រីចៅក្រមចាំហើយថា សមមិត្ត ឌឿន មកពីមន្ទីរ៨៧០ ត្រូវបានគេចាត់តាំងឲ្យទទួលខុសត្រូវមួយចំនួនពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មចំនួន៣ខែ គឺខែសម្រាប់ខែឧសភា, មិថុនា និងកក្កដា ឆ្នាំ១៩៧៦។ ឯកសារទី២ រួមមានសេចក្ដីណែនាំដែល វ៉ាន់ រិត ត្រូវធ្វើដំណើរទៅទីក្រុងហុងកុង ដើម្បីធ្វើការបង្កើតទំនាក់ទំនងទិញទំនិញ។

លោក លោកស្រីចៅក្រមប្រហែលជាចាំហើយ សហសេវិករបស់ខ្ញុំនៅថ្ងៃ១០ ខែតុលា បានបង្ហាញរបាយការណ៍មួយចំនួនដែលបានផ្ញើជូនទៅ ឌឿន ពីក្រសួងពាណិជ្ជកម្មដែលនៅក្នុងរបាយការណ៍ទាំងអស់នោះ គឺក្រសួងក៏បានលើកឡើងអំពីសមមិត្ត ឌឿន ធ្វើការចរចាជាមួយនឹងរដ្ឋាភិបាលអន្តរជាតិ ហើយចាប់ពីខែតុលា ឆ្នាំ៧៦ របាយការណ៍ទាំងអស់នោះគឺថាបានបញ្ជូនដាច់ដោយឡែកតែទៅ ខៀវ សំផន តែប៉ុណ្ណោះ។ ជាការពិតឯកសារទាំងអស់នេះគឺជាឯកសារដែលយើងមានហើយនៅសល់ពីរបបនោះ។

ដូចដែលសហសេវិករបស់ខ្ញុំបានបញ្ជាក់ហើយ មានឯកសារសរុប២៨ច្បាប់ ដែលក្នុងនោះមានរបាយការណ៍ផ្ញើជូនដោយផ្ទាល់ទៅ ខៀវ សំផន។ ដូចដែលខ្ញុំបានបញ្ជាក់រួមមកហើយ ឯកសារទាំងអស់នោះពាក់ព័ន្ធទៅនឹងរយៈកាលពីខែតុលា ៧៦ រហូតដល់ចុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:០១:១៦]

សហសេវិករបស់ខ្ញុំក៏បានបង្ហាញឯកសារចំនួនពីរទៀតផងដែរ ក៏ប៉ុន្តែខ្ញុំនឹងគ្រាន់តែបន្ថែមទៅលើឯកសារទាំងអស់នេះដោយគ្រាន់តែបង្ហាញចំណុចមួយចំនួន និងបង្ហាញដោយសង្ខេបអំពីរចនាសម្ព័ន្ធអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ហើយឯកសារទាំងពីរនោះ គឺឆ្លុះបញ្ចាំងចំណុចនេះ។ ឯកសារទី១ គឺ E3/1618 ឯកសារនេះក៏មានលេខ E3/3513 ផងដែរ ជារបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម គឺឯកសារលេខ ០៦៩១/៧៧ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ៧៧។ បង្ហាញអំពីអ្នកបច្ចេកទេសពីប្រទេសយូហ្គោស្លាវីទៅទស្សនកិច្ចកំពង់សោម។ ហើយអ្នកដែលចូលរួមខាងកម្ពុជាមាន វិច និង សមមិត្ត រិត និងសមមិត្ត ល្មុត ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនោះ តំណាងខាងកម្ពុជា។ អ្វីដែលសំខាន់ពាក់ព័ន្ធសម្រាប់កម្ពុជា -- សម្រាប់ឯកសារនេះនោះគឺថាអ្វីដែលឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងក្រសួងពាណិជ្ជកម្ម និង ហែម គឺយើងអាចមើលឃើញត្រង់ខ្មែរ ERN 00002846, បារាំងមានលេខ ERN 00665471, អង់គ្លេសមានលេខ 00680478។ នៅត្រង់ទំព័រនេះ អ្នកដែលរៀបចំរបាយការណ៍នេះបានលើកឡើងថា នៅក្នុងពេលនោះ តំណាងគឺបានលើកឡើងអំពីឧបករណ៍ដែលទើបតែមកដល់ប្រទេសកម្ពុជា ក្រោយពីមានការណែនាំរបស់អ្នកៗ គឺថាយើងអាចដោះស្រាយដូចខាងក្រោម។

[១៤:០៣:៣៨]

យើងខ្ញុំមិនលើកឡើងខ្លឹមសារសំខាន់នៃឯកសារនេះទេ ដោយសារវាពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស និងបញ្ហាពាណិជ្ជកម្ម។ របាយការណ៍នេះបញ្ចប់ដោយការលើកឡើងដូចតទៅ "សូមឲ្យបងៗទទួលព័ត៌មាននេះ ហើយផ្តល់ជាយោបល់លើបញ្ហាជាក់លាក់"។ នៅក្នុងឯកសារនេះក៏មានចំណារថា ឯកសារនោះមួយច្បាប់បានបញ្ជូនទៅ បងហែម និង បងវន ផងដែរ។

ឯកសារមួយទៀតគឺ ឯកសារមួយទៀតដែលស្ថិតនៅក្នុងសំណុំឯកសារដែលខ្ញុំដាក់បង្ហាញនៅក្នុងរសៀលនេះផងដែរគឺ E3/1637។ វាជារបាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្មចុះថ្ងៃ១២ ខែវិច្ឆិកា ៧៨ នៅក្នុងនេះវាពាក់ព័ន្ធទៅនឹងការចរចាជាមួយនឹងខាងគណៈប្រតិភូយូហ្គោស្លាវី។ របាយ-ការណ៍នេះជាថ្មីម្តងទៀត គឺថាគេសរសេរថា "ខ្ញុំចង់ឲ្យបងៗទទួលព័ត៌មានពាក់ព័ន្ធរបាយការណ៍នេះ

ហើយសូមអញ្ជើញក្រសួងមានសមត្ថកិច្ចលើបញ្ហាគ្រឿងបន្លាស់នេះមកពិភាក្សាគ្នាដើម្បីសម្រេច។ ចុះហត្ថលេខាដោយគណៈកម្មាធិការពាណិជ្ជកម្ម។ ឯកសារនេះនៅខាងឆ្វេង ខាងលើ មានចំណារសរសេរថា "បានបញ្ជូនទៅឲ្យបងហែម រួចហើយ"។ ហើយលោក លោកស្រីចៅក្រម អាចពិនិត្យមើលនៅលើអេក្រង់បាន។

នេះគឺជាការចរចាជាមួយនឹងភាគីប្រតិភូយូហ្គោស្លាវី ហើយយើងមានឯកសារពីរទៀតទាក់ទងទៅនឹងប្រតិភូប្រទេសចិន។ ឯកសារទី១គឺ E3/3461 "ផ្ញើជូនចំពោះបងហែមជាទីគោរព និងស្នេហា"។ វាគឺជាសេចក្ដីរាយការណ៍អំពីការជួបមិត្តចិន កាលពីថ្ងៃទី២៤ មករា ៧៨។ គឺខាងកម្ពុជាមានសមមិត្ត រិត, សី និង ឆេង។ ឯកសារនេះគឺនិយាយអំពីបញ្ហាបច្ចេកទេស ហើយលិខិតនេះបានបញ្ចប់ដោយការសរសេរដូចតទៅនេះ "ខ្ញុំសូមជម្រាបជូនបង -- ជម្រាបជូនព័ត៌មានចំពោះបង ហើយនិងសូមឲ្យបងផ្ដល់នូវមតិយោបល់"។ ហើយឯកសារនេះបានផ្ញើជូនបងហែម, បងវន, ក-៥១ ហើយនិងឯកសារ។

[១៤:០៦:៣៣]

ហើយជាចុងក្រោយ ឯកសារ E3/3455 គឺជារបាយការណ៍មួយទៀតនៃការចរចាគ្នាជាមួយអ្នកតំណាងប្រទេសចិន គឺទាក់ទងទៅលើបញ្ហានាំចេញ និងនាំចូលរវាងប្រទេសទាំងពីរ។ ឯកសារនេះគឺចេញដោយក្រសួងពាណិជ្ជកម្ម "ផ្ញើជូនចំពោះបងហែមជាទីគោរព និងស្នេហា"។ ហើយនៅក្នុងកិច្ចប្រជុំនេះខាងកម្ពុជាចូលរួមដោយសមមិត្ត រិត, សី ហើយនិង ឆេង ហើយឯកសារនេះស្នើសុំឲ្យមានការផ្ដល់ការណែនាំពី ខៀវ សំផន។ ឯកសារនេះផ្ញើជូនបងហែម, បងវន, ក-៥១ ហើយនិងរក្សាទុកពីរច្បាប់នៅក្នុងឯកសារ។ ហើយឯកសារនេះចុះនៅថ្ងៃទី២៤ មករា ៧៨។

ប្រសិនបើយើងមើលទៅលើឯកសារនេះ ខ្ញុំសូមបញ្ជាក់ជាកំណត់ត្រាថា ដីកាដំណោះស្រាយបានចុះនៅក្នុងកថាខណ្ឌ១១៩០ ដែលបញ្ជាក់ថា មានបុគ្គលប្រហែលជា៤៨២នាក់ មកពីក្រសួងពាណិជ្ជកម្មត្រូវបានគេបញ្ជូនទៅ ស-២១។ ហើយនេះគឺជាបញ្ហាដែលពាក់ព័ន្ធ នៅពេលដែលយើងពិចារណាអំពីការទទួលខុសត្រូវ និងតួនាទី ព្រមទាំងការចូលរួមរបស់ខៀវ សំផន នៅក្នុងក្រសួងពាណិជ្ជកម្មនេះ។

[១៤:០៨:៣០]

បន្ថែមពីលើការផ្ញើលិខិតជូន ខៀវ សំផន នៅក្នុងសំណុំរឿងក៏មាននូវឯកសារចំនួន៥១ ដែលជាតារាង ឬមួយក៏ជាសៀវភៅធំ ដែលជាការកត់ត្រានូវការនាំចេញ នាំចូល ដែលក្នុងនោះគឺមានរៀបរាប់អំពីការផ្ដល់ក្រេឌីតទៅឲ្យប្រទេសកម្ពុជា ដោយប្រទេសចិន។ យើងអាចមើលទៅលើឧទាហរណ៍មួយ

ចំនួន។ ហើយមុនពេលដែលខ្ញុំបង្ហាញឯកសារ ខ្ញុំសូមបញ្ជាក់សាជាថ្មីថា សហការីខ្ញុំបានបង្ហាញនូវបញ្ជីចំនួនពីរដែលផ្ញើជូន បងហែម ដែលក្នុងនេះគឺមានបណ្តុំនៃឯកសារចំនួន៥១ គាត់ធ្វើនៅថ្ងៃ១០ និងថ្ងៃ១៨ ខែតុលា ២០១២ គឺឯកសារ D66/7.1.487 ដែលជារបាយការណ៍ប្រចាំសប្តាហ៍អំពីស្រូវ គឺមានលេខ 18.68 ហើយក្នុងនោះគឺមានរៀបរាប់នូវបញ្ជីមួយចំនួន។

[១៤:១០:០២]

ឯកសារពីរដែលខ្ញុំចង់បង្ហាញនៅពេលនេះ គឺជាការបង្ហាញនូវបញ្ជីដែលខ្ញុំនឹងបង្ហាញដោយសង្ខេប ទី១ គឺ E3/312 ហើយនេះគឺជាបញ្ជីដែលនិយាយអំពីការប្រើប្រាស់ឥណទាន ដែលខ្ញុំបាននិយាយពីដើមរួចមកហើយ។ គឺជាការទទួលឥណទានពីរដ្ឋាភិបាលចិន។ គឺថាឯកសារនេះបានផ្ញើជូន បងហែម និង បងវន។ គឺជាអ្វីដែលយើងឃើញនៅលើ ចំណារនៅផ្នែកខាងលើ គឺជាចំណារដែលនៅខាងឆ្វេង ចុះថ្ងៃទី២២ ខែ៥ គឺនៅថ្ងៃទី២១ ខែ៥ ឆ្នាំ៧៨។

អ្វីដែលពាក់ព័ន្ធទៅនឹងឯកសារ ដែលក្រៅពីការរាយការណ៍អំពីរចនាសម្ព័ន្ធនោះ គឺវាបានឆ្លុះបញ្ចាំងអំពីការនាំចេញស្រូវអង្ករ។ ខ្មែរ ERN មានលេខ 00007292, បារាំងមានលេខ 0066510, ភាសាអង់គ្លេស គឺមានលេខ 00685468 ហើយបញ្ជីនេះគឺបានកត់ត្រាអំពីការនាំចេញទៅប្រទេសម៉ាដាហ្គាស្កា។ គឺស្រូវចំនួន ១៤.៦២៣,១៤៥ តោន ហើយយើងឃើញនៅលើអេក្រង់ច្បាស់អំពីតួលេខទាំងអស់នេះ។

បន្តទៅទៀត គឺជាបញ្ជីមួយទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ ចុះថ្ងៃទី២០ ខែ១០ ឆ្នាំ៧៨ គឺឯកសារដែលមានលេខ E3/2515 ហើយឯកសារនេះ "ផ្ញើជូន បងវន និងបងហែម" ហើយយើងមើលឃើញនូវទំព័រទី១ គឺមានចំណារដែលសរសេរដូច្នេះ។ ហើយឯកសារនេះគឺនិយាយអំពីការប្រើប្រាស់ឥណទានចំនួន ១៤០លានយ័ន ប៉ុន្តែប្រសិនបើយើងមើលពីរទំព័រខាងក្រោមគឺបាននិយាយអំពីការនាំចេញទៅប្រទេសចិន។ ខ្មែរ ERN មានលេខ 00278318, បារាំងមានលេខ 00760043 និង ភាសាអង់គ្លេសមានលេខ 00748405 នៅទំព័រនេះគឺទំនិញលេខ៧ គឺអង្ករ១៥ភាគរយ មានទម្ងន់ ៥.០១៧តោន។

[១៤:១៣:២០]

ឯកសារពីរទៀតដែលធ្វើការកត់ត្រាអំពីមុខងាររបស់ក្រសួងពាណិជកម្ម ហើយដែលបង្ហាញថា ដឹកនាំដោយលោក ខៀវ សំផន នោះគឺជាឯកសារដែលមានលេខ E3/1640 វាគឺជាលិខិតមួយដែលជូន

ចំពោះស្ថានទូតសាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី ចុះថ្ងៃទី១៥ កក្កដា ១៩៧៨ ហើយនៅលើឯកសារនេះគឺមានចំណារដែលសរសេរថា “ជូនបងហែម ផ្ទាល់ដៃ” ហើយមានចុះហត្ថលេខាដាក់ថ្ងៃ១៦ ខែកក្កដា។ លិខិតហ្នឹងគឺមានការចាប់អារម្មណ៍ដោយសារតែលិខិតហ្នឹងបានបញ្ជាក់អំពីអ្វីដែលយើងឃើញនៅលើអេក្រង់ទាំងអស់គ្នានេះ គឺការរៀបចំនាំចេញអង្ករសចំនួន ៥.០០០តោន ក្នុងនោះមាននាំចេញគ្រាប់កាហ្វេ ៣.២៤២, កាហ្វេលេខមួយ ៣.២៤២, លេខពីរ ២.៦១០តោន ហើយនិងមានលេខបន្តបន្ទាប់ទៀត។ លិខិតក៏បានបញ្ជាក់ថា ការនាំចេញហ្នឹងមិនអាចធ្វើបានដោយសារតែមានបញ្ហាបច្ចេកទេស ឬក៏ដោយសារតែមានការពន្យារពេលពីខាងប្រទេសយូហ្គោស្លាវី។ ប៉ុន្តែនៅខាងក្រោមបានបញ្ជាក់ថា “នៅដើម៧៧ ក្រសួងពាណិជ្ជកម្មបានរៀបចំការនាំចេញ អង្ករ ស្រូវចំនួន៥.០០០តោន ក៏ដូចជា កាហ្វេ ម្រេច និងសណ្តែកដីមួយចំនួនទៀត ដើម្បីនាំទៅប្រទេសយូហ្គោស្លាវី ដោយដឹកតាមកំពង់សោម”។ លិខិតនេះបានចុះហត្ថលេខាដោយឈ្មោះ វិត។

[១៤:១៥:២៦]

ឯកសារចុងក្រោយនៅក្នុងបណ្តុំឯកសារដែលយើងបានពិភាក្សានេះ គឺ E3/3533 គឺឯកសារដែលមានលេខ E3/3533 គឺនៅលើឯកសារនៅទំព័រមានចំណារដែលសរសេរថា “ឯកសារនេះបានយកជូន បងហែម” ហើយនិយាយអំពីទិន្នន័យនៃការនាំចេញទៅប្រទេសចិន។ គឺសរុបស្ថិតិទំនិញនាំចូលទីផ្សារចិនផ្នែកពាណិជ្ជកម្ម។ ហើយនៅក្នុងនេះ គឺមានបញ្ជីក្រសួង មានរៀបរាប់នូវក្រសួងជាច្រើនហើយនិងអក្សរកាត់របស់ក្រសួងនោះ។ ភាពពាក់ព័ន្ធនៃឯកសារនេះ គឺថាខ្ញុំសូមបញ្ជាក់ក្រៅពីរចនាសម្ព័ន្ធសិទ្ធិអំណាច ក៏ដូចជារចនាសម្ព័ន្ធនៃសិទ្ធិអំណាចរបស់ ខៀវ សំផន ដែលបង្ហាញនៅក្នុងឯកសារនេះ។ ឯកសារនេះក៏បានបញ្ជាក់ផងដែរ អំពីការសម្របសម្រួលជាបែបរួមគ្នារបស់ក្រសួងពាណិជ្ជកម្មហើយនិងការនាំចេញនូវផលិតផលទាំងអស់នេះ។ ហើយនិងការសម្របសម្រួលដោយក្រសួងពាណិជ្ជកម្មជាមួយនឹងក្រសួងដទៃទៀត ទាក់ទងទៅនឹងការនាំចេញចូល។ ឯកសារនេះ គឺផ្តល់នូវការស្វែងយល់អំពីការទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាបង្ហាញអំពីសិទ្ធិអំណាចរបស់ ខៀវ សំផន នៅក្នុងក្រសួង។

[១៤:១៧:២៣]

បណ្តុំឯកសារបន្ទាប់ ដែលទាក់ទងទៅនឹងក្រសួងពាណិជ្ជកម្មផងដែរ គឺជាប្រធានបទមួយដែលប្លែកពីប្រធានបទមុន គឺនិយាយអំពីការទំនាក់ទំនងរវាងក្រសួងពាណិជ្ជកម្មជាមួយនឹងកម្មាភិបាលនានា

ដែលត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅទីក្រុងហុងកុង។ គឺធ្វើការនៅក្រុមហ៊ុនរ៉េនហ្វុង គឺជាក្រុមហ៊ុនដែលយើងបានបញ្ជាក់ច្រើនដងហើយនៅក្នុងសវនាការនេះ។ ភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះ គឺបញ្ជាក់អំពីការបង្ហាញឈ្មោះលោក ខៀវ សំផន នៅក្នុងឯកសារមួយចំនួន។ គឺការបញ្ចូលឈ្មោះ ខៀវ សំផន។ គឺឯកសារ E3/323 ដែលចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៧។ វាគឺជាលិខិតមួយដែលផ្ញើពីគណៈកម្មាធិការពាណិជ្ជកម្ម “ជូនចំពោះសមមិត្ត សុខ ជាទីស្នេហា និងនឹករឭក”។ សុខ គឺសំដៅទៅលើឈ្មោះ អ៊ុំ សុខ ដែលជាអ្នកគ្រប់គ្រងនិងជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនរ៉េនហ្វុងនៅក្នុងប្រទេសហុងកុង។ នៅក្នុងឯកសារនេះ គឺយើងឃើញចំណារដែលថា “បានផ្ញើជូន បងហែម ដើម្បីពិនិត្យមុនផ្ញើឲ្យហុងកុង”។ ឯកសារនេះ គឺបញ្ជាក់អំពីការចូលរួមរបស់ ខៀវ សំផន នៅក្នុងឯកសារទំនាក់ទំនងមួយនេះ។

[១៤:១៩:១២]

ឯកសារបន្ទាប់ទៀត គឺ E3/334។ ហើយឯកសារនេះ គឺជាលិខិតដែលផ្ញើជូន បងសុខ ដោយគណៈកម្មាធិការ ចុះថ្ងៃទី០៣ កុម្ភៈ ឆ្នាំ១៩៧៨។ ហើយនៅទំព័រទី១នៃឯកសារនេះ គឺមានចំណារដែលសរសេរថា “ជូនបងហែម ដើម្បីសុំមតិណែនាំសិន មុនផ្ញើទៅហុងកុង”។ ប្រសិនបើយើងមើលបន្តទៅទៀត គឺមានឯកសារមួយចំនួននៅក្នុងបណ្តុំឯកសារនេះ ដែលគេបង្ហាញពីឈ្មោះ ហែម ឬក៏ ហែម បានផ្តល់នូវឯកសារទៅរ៉េនហ្វុង ឬក៏ទៅដល់ឈ្មោះ សុខ ហើយខ្ញុំនឹងអាននូវឯកសារពាក់ព័ន្ធមួយចំនួនដោយមិនបាច់បង្ហាញឯកសារនៅលើអេក្រង់។ ខ្ញុំធ្វើដូច្នេះដើម្បីសន្សំពេលវេលា។

ឯកសារទី១ គឺ 21.98 ចុះថ្ងៃ០៣ មីនា ៧៨។ មួយទៀតគឺ D161/1.47 ចុះថ្ងៃ០៩ ខែមិថុនា ឆ្នាំ៧៨។ មួយទៀតគឺឯកសារ D161/1.4 ជាឯកសារថ្ងៃ០៧ មករា -- ០៧ កុម្ភៈ ៧៨, ០៧ កក្កដា ៧៨។ ឯកសារមួយទៀតគឺ D161/1.3, D161/1.46 ចុះថ្ងៃ០៣ ខែ៩ ខែ៨ ៧៨។ មួយទៀតគឺ D161/1.43 ចុះថ្ងៃទី១១ ខែ៨ ៧៨។ ឯកសារទាំងអស់នេះ គឺជាឯកសារដែលផ្ញើជូនក្រុមហ៊ុនរ៉េនហ្វុងនៅហុងកុង ឬមួយក៏ផ្ញើជូនលោក សុខ, ជូនបងសុខ។ ហើយឯកសារទាំងអស់នេះសុទ្ធតែចម្លងជូនលោក ហែម គឺ ខៀវ សំផន ដែលមានឈ្មោះហៅថា ហែម។

[១៤:២១:៤៥]

បណ្តុំឯកសារបន្ទាប់ដែលខ្ញុំនឹងលើកយកមកបង្ហាញ គឺជាបណ្តុំឯកសារដែលឆ្លុះបញ្ចាំងអំពីការរៀបចំនូវការវិលត្រឡប់របស់លោក អ៊ុំ សុខ និងភរិយារបស់គាត់។ ហើយនិងការផ្ទេរក្រុមហ៊ុនដែលគាត់ទទួលខុសត្រូវទៅឲ្យបុគ្គលដទៃទៀត។

ស្ថានភាពនេះគឺវាមានលក្ខណៈស្មុគស្មាញដោយសារតែយើងមិនមានឯកសារគ្រប់គ្រាប់ ប៉ុន្តែខ្ញុំនឹងលើកបង្ហាញឯកសារដែលពាក់ព័ន្ធបំផុតដើម្បីយកមកបង្ហាញ គឺយើងយកមកប្រើប្រាស់ដើម្បីគោលដៅក្នុងពេលបច្ចុប្បន្ន។ គឺឯកសារ E3/1902 ហើយឯកសារនេះ ផ្ញើពីសមមិត្ត រិន -- សមមិត្ត គ្រិន ទទួលខុសត្រូវនៅក្នុងកំពង់សោម ហើយគាត់ជាអ្នកចុះហត្ថលេខា ហើយគាត់រាយការណ៍អំពីហុងកុង។

ហើយនៅក្នុងឯកសារ E3/1902 គាត់បានសរសេរដូចតទៅនេះ “សូមជម្រាបអង្គការជាទីគោរព ក្រោយពេលបានទទួលចម្លើយរបស់មេធាវីថាគេពុំអាចជួយផ្ទេរឈ្មោះរវាងសមមិត្តសុខ និងខ្ញុំបានទេ ព្រោះរដ្ឋការហុងកុង គឺអង់គ្លេសមិនទទួលស្គាល់ហត្ថលេខានិងត្រារបស់ក្រសួងការបរទេសយើងទេ។ ខ្ញុំបានទៅពឹងចិនម្នាក់ដែលចេះភាសាបារាំង ជូនខ្ញុំទៅសួរច្បាប់ទម្លាប់ផ្ទេរនេះនៅក្រុមហ៊ុនច្បាប់មួយទៀត។ ក្រុមហ៊ុននេះគេថាគេអាចជួយបាន ប៉ុន្តែត្រូវបង់សោហ៊ុយច្រើន។ ប្រសិនបើអង្គការយល់ស្រប សូមឲ្យក្រសួងពាណិជ្ជកម្មធ្វើការសម្រេចចិត្ត ហើយនិងចេញលិខិតផ្ទេរសិទ្ធិដូចដែលបានធ្វើជាមួយខ្ញុំ ប៉ុន្តែទុកនៅចន្លោះដើម្បីចុះហត្ថលេខាសមមិត្ត ណាត ដើម្បីឲ្យមេធាវីជាអ្នកចុះហត្ថលេខាជំនួសវិញ”។ សមមិត្ត នារីណាត គឺជាភរិយារបស់សមមិត្ត រិត -- ជាសមមិត្ត សុខ។ ហើយយើងនឹងឃើញអំពីការផ្ទេរនូវកម្មសិទ្ធិពីប្ដីប្រពន្ធ សុខ និងណាត ទៅឲ្យឈ្មោះ គ្រិន។

[១៤:២៤:២៧]

ឯកសារបន្ទាប់ដែលពាក់ព័ន្ធនៅក្នុងសវនាការមួយដែល គឺ E3/1907 ដែលនិយាយអំពីបញ្ហានៅក្នុងការផ្ទេរភាគហ៊ុន ដែលក្នុងនេះបង្ហាញថាសមមិត្ត សុខ បានមកដល់ប្រទេសកម្ពុជា គឺចុះថ្ងៃ២៧ ខែតុលា ឆ្នាំ៧៨ ដែលនិយាយថា “ជម្រាបមកសមមិត្ត គ្រិន, ណាត ជាទីស្នេហានឹករឭក”។ យើងដឹងហើយថា ណាត គឺជាភរិយារបស់ សុខ ហើយខ្ញុំនឹងអាននូវកថាខណ្ឌមួយចំនួន “យើងខ្ញុំបានទទួលដំណឹងពីអង្គការស្ដីពីសំបុត្ររាយការណ៍របស់សមមិត្តក្នុងរឿងផ្ទេរឈ្មោះរវាងសមមិត្ត គ្រិន និងសមមិត្ត សុខ និងការផ្ទេរភាគហ៊ុនពីសមមិត្ត ណាត ជូនសមមិត្តផ្សេងទៀត”។ ហើយក្នុងឯកសារនេះនិយាយអំពីបញ្ហាក្នុងការផ្ទេរភាគហ៊ុន ដែលក្នុងនេះបង្ហាញថា “សុខ មិនមានវត្តមាននៅហុងកុងនោះទេ”។ កថាខណ្ឌទី៤ បានអានដូចតទៅ “អំពីរឿងភាគទុនរបស់សមមិត្ត ណាត ស្នើលក់ជូនសមមិត្ត គ្រិន ផ្ទាល់ចុះ ប្រសិនបើឃើតយ៉ាវរឿងកាត់ឈ្មោះលក់ភាគហ៊ុនទៀត គឺមានជម្រើសទី២ សមមិត្ត ណាត និងសមមិត្ត គ្រិន នាំគ្នាទៅចំពោះមុខអ្នកច្បាប់ហុងកុង ធ្វើការផ្ទេរអំណាចពីសមមិត្ត ណាត ជូនសមមិត្ត

គ្រិន។ ដោយជួលសមមិត្ត គ្រិន ឲ្យទទួលខុសត្រូវក្រុមហ៊ុន"។ ហើយនៅក្រោមបន្តិចបានបញ្ជាក់ថា "ធ្វើយ៉ាងម៉េចក៏ដោយគឺត្រូវធ្វើយ៉ាងណាដើម្បីឲ្យសមមិត្ត គ្រិន មានអំណាចគ្រប់គ្រងក្រុមហ៊ុនបានតាមផ្លូវច្បាប់ដែលរដ្ឋការហុងកុង។

[១៤:២៦:២៦]

ឯកសារនៅក្នុងសំណុំរឿងបានបញ្ជាក់ថា "នៅក្នុងពេលនេះ ខៀវ សំផន នៅតែមានឈ្មោះនៅក្នុងឯកសារ ទំនាក់ទំនងរវាងរដ្ឋបាលនៅកម្ពុជាជាមួយនិងក្រុមហ៊ុននៅហុងកុង"។ ហើយឯកសារមួយទៀតគឺ E3/1771 ហើយក៏មានលេខមួយទៀតគឺ E3/1779 គឺជាលិខិតចុះថ្ងៃ០១ ធ្នូ ៧៨ ដែលចេញពីហ្វូតត្រា គឺជាក្រុមហ៊ុនកម្ពុជាមួយដែលចុះបញ្ជី នៅក្នុងនេះ គឺក្រុមហ៊ុនបានចេញនូវការណែនាំឲ្យណាត ត្រឡប់មកប្រទេសកម្ពុជាវិញ គឺឯកសារ E3/875 គឺចុះថ្ងៃទី១០ ធ្នូ ៧៨ ហើយលិខិតនេះផ្ញើជូនសមមិត្ត គ្រិន ហើយនិងសមមិត្ត ណាត ដោយក្ដីស្រលាញ់ និងនឹករឭក។ ហើយខ្ញុំនឹងដកស្រង់នូវសម្រង់មួយចំនួន "អង្គការបានណែនាំយើងថា សមមិត្ត សុខ និងសមមិត្ត ណាត ត្រូវទទួលបានភារកិច្ចថ្មីនៅក្នុងអនាគតឆាប់ៗនេះ ដោយនៅពេលនេះបក្សបានបើកសាលាអប់រំកម្មាភិបាលរបស់បក្ស ជាបន្តបន្ទាប់សម្រាប់ឆ្នាំ១៩៧៨។ សមមិត្តបានរៀនសូត្រមុនពេលចេញទៅបំពេញភារកិច្ចថ្មី ស្នើសមមិត្តទាំងពីររៀបចំការងារនៅក្នុងក្រុមហ៊ុនឲ្យបានស្រួល មានបញ្ហាណាដែលពុំទាន់ដោះស្រាយ ស្នើរួមគ្នាដោះស្រាយឲ្យបានបានចប់សព្វគ្រប់។ ក្រោយពីរៀបចំការងារបានចប់ហើយ យើងខ្ញុំស្នើឲ្យសមមិត្ត គ្រិន ជួយរៀបចំដំណើរវិលមកក្នុងប្រទេសវិញរបស់មិត្ត ណាត និងកុមារ សាន ហ្វេង ឲ្យបានស្រួលផង និងធានាដល់សុខភាព"។

ឯកសារដែលខ្ញុំអាននេះ គឺមាននៅលើអេក្រង់កុំព្យូទ័រ។ "យើងសង្ឃឹមថា សមមិត្តទាំងពីរនឹងខិតខំរួមគ្នាដោះស្រាយការងារ ហើយសូមជូនពរសមមិត្តទាំងពីរមានសុខភាពល្អបរិបូណ៌ និងទទួលជ័យជម្នះក្នុងភារកិច្ចជាបន្តបន្ទាប់"។ គឺជាឯកសារដែលបញ្ជាឲ្យសមមិត្តនារី ណាត និងកូនរបស់គាត់ធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ។

[១៤:២៨:៥៩]

ឯកសារបន្ទាប់ដែលខ្ញុំនឹងលើកយកមកបង្ហាញនៅពេលនេះ គឺឯកសារ E3/1532 គឺជាបញ្ជីអ្នកទោសមកពីស-២១ ហើយវាជាប្រវត្តិរូបរបស់ឈ្មោះ អ៊ឹង សុក គឺជាបុគ្គលដែលយើងបានឃើញនៅក្នុងលិខិតដែលផ្ញើមកពីក្រសួងពាណិជ្ជកម្ម។ ហើយនៅក្នុងលេខ៣ នៃក្រសួងនេះ គឺបានបញ្ជាក់អំពី

តួនាទីរបស់គាត់ថា "ជាប្រធានដឹកជញ្ជូនជើងគោក ប្រធានពាណិជ្ជកម្មប្រចាំការនៅហុងកុង" ហើយ "ក្នុងលេខ១១ គឺទីកន្លែងឃាត់ខ្លួនពាណិជ្ជកម្ម និងទី១២ ទីកន្លែងឃាត់ខ្លួនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ៧៨"។

ឯកសារបន្ទាប់ដែលខ្ញុំសូមបង្ហាញនៅលើអេក្រង់ផងដែរនោះ គឺឯកសារមួយទៀតដែលជាបញ្ជីអ្នកទោស ស-២១ គឺ E3/1533 គឺជាបញ្ជីឈ្មោះអ្នកទោសឈ្មោះ ផល វ៉ា ហៅ ណាត គឺជាបុគ្គលដែលយើងបានឃើញនៅក្នុងឯកសារដែលខ្ញុំបានបង្ហាញមុននេះមកហើយ។ ហើយតួនាទីរបស់គាត់នៅក្នុងលេខបី គឺបានបញ្ជាក់ថា ជាសមាជិកគណៈកម្មាធិការពាណិជ្ជកម្មប្រចាំហុងកុង។ ទីកន្លែងចាប់ខ្លួនគឺនៅក្រសួងពាណិជ្ជកម្ម ហើយថ្ងៃចាប់ខ្លួន គឺថ្ងៃទី៣០ ធ្នូ ឆ្នាំ៧៨។ ជាសង្ខេបមក នៅពេលដែលទទួលបានការបញ្ជាឲ្យត្រឡប់មកប្រទេសកម្ពុជានៅថ្ងៃទី៣០ -- ថ្ងៃទី១០ ធ្នូ ៧៨ ត្រឹមថ្ងៃ៣០ ធ្នូ ៧៨ សមមិត្តនារីណាត និងប្ដីរបស់គាត់ត្រូវបានគេចាប់ខ្លួនបញ្ជូនទៅ ស-២១។

[១៤:៣១:១១]

ឯកសារ E3/1533 គឺឯកសារចុងក្រោយ ក៏មានរៀបរាប់ -- ក៏មានបង្ហាញផងដែរនូវរូបថតបុគ្គលដែលពាក់ព័ន្ធដែលយើងបានដាក់នៅក្នុងសំណុំរឿង ដោយសហចៅក្រមស៊ើបអង្កេត។ ឯកសារពីរ គឺបង្ហាញរូបរបស់ អ៊ុម សុក គឺរូបរបស់ អ៊ឹង សុក។ រូបថតនេះបង្ហាញសមមិត្ត អ៊ឹង សុក នៅពេលដែលគាត់នៅក្នុងប្រទេសកម្ពុជា។ ហើយរូបភាពបន្ទាប់ នេះគឺជារូបភាពរបស់ អ៊ឹង សុក ហើយនិងភរិយារបស់គាត់ឈ្មោះ ផល វ៉ា ដែលនៅទីក្រុងហុងកុង។ ហើយក្រោមបន្តិចទៀត គឺជារូបថតនៅហុងកុងរបស់លោក អ៊ឹង សុក និងរូបថតចុងក្រោយនៅទំព័របន្ទាប់គឺជារូបថតរបស់ ផល វ៉ា នៅក្នុងការិយាល័យរបស់គាត់នៅទីក្រុងហុងកុង ហើយនិងរូបថតរបស់គាត់នៅក្នុងបញ្ជីឈ្មោះអ្នកទោសស-២១ ដែលយើងឃើញនៅខាងស្ដាំដៃនេះ។ ខ្ញុំសូមបញ្ចប់ផ្នែកដែលពាក់ព័ន្ធជាមួយនឹងក្រសួងពាណិជ្ជកម្ម ហើយនិងតួនាទីរបស់ ខៀវ សំផន។

ឯកសារផ្នែកបន្ទាប់ ដែលខ្ញុំនឹងលើកយកមកនិយាយនេះគឺបង្ហាញអំពីបណ្ដុំឯកសារដែលនិយាយអំពីចម្លើយរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា។ ព្រោះថាឯកសារមួយចំនួនត្រូវបានធ្វើឡើងក្រោយពីដួលរលំរបបកម្ពុជាប្រជាធិបតេយ្យភ្លាមៗ ហើយឯកសារនេះវាបានឆ្លុះបញ្ចាំងអំពីគំនិតរបស់គាត់ ឬក៏ចម្លើយដែលគាត់បានផ្ដល់ឲ្យ។

[១៤:៣៣:១៦]

ឯកសារ E3/628 គឺជាអត្ថបទរបស់ទស្សនាវដ្ដីថៃមស៍ម៉ាហ្គាហ្ស៊ីន ដែលនិយាយថាជាការ

អំពាវនាវឲ្យមានការគាំទ្រពីអន្តរជាតិ។ ឯកសារនេះគឺចុះថ្ងៃទី១០ មីនា ឆ្នាំ១៩៨០។ ឯកសារនេះបាន បង្ហាញនូវការសម្ភាសដ៏កម្រមួយជាមួយនឹងលោក ខៀវ សំផន។

ខ្ញុំសូមអាននូវការសម្ភាសមួយផ្នែក គឺខ្មែរ ERN មានលេខ 00709453, និងភាសាបារាំងមាន លេខ 00740913។ “សំណួរ៖ តើលោកគិតថារដ្ឋាភិបាលរបស់លោកបានប្រព្រឹត្តនូវកំហុសដែរឬទេ នៅពេលដែលដឹកនាំប្រទេសកម្ពុជាប្រហែល៣ឆ្នាំ? បន្ទាប់ពីសង្គ្រាមជាមួយនឹងរបបលន់ នល់ ដែល មានការគាំទ្រពីលោកខាងលិច គឺយើងយល់ឃើញថា យើងមានការជោគជ័យមួយ គឺយើងដោះស្រាយ បញ្ហាស្បៀងអាហារសម្រាប់ប្រជាជនយើង។ ជាការពិតណាស់យើងមានការខ្វះខាតមួយចំនួន សូម្បី តែកម្មាភិបាលមន្ត្រីកុម្មុយនីស្តរបស់យើងក៏ជួបកង្វះខាតដែរ។ សំណួរ៖ មានការប៉ាន់ប្រមាណផ្សេងៗ ថាមនុស្សជាច្រើនត្រូវបានសម្លាប់ក្នុងអំឡុងពេលលោកកាន់កាប់អំណាចនៅទីក្រុងភ្នំពេញ។ តើមាន ប្រជាជនប្រហែលប៉ុន្មាននាក់ដែលត្រូវបានគេសម្លាប់? ចម្លើយ៖ យើងមិនដែលពាក់ព័ន្ធក្នុងការសម្លាប់ មនុស្សដ៏ច្រើននោះទេ។ គ្មានមូលហេតុណាមួយដែលយើងត្រូវប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ។ មនុស្សមួយចំនួននិយាយថាយើងសម្លាប់មនុស្សជាង៣លាននាក់។ រឿងនេះមិនពិតនោះទេ។ សំណួរ៖ តើលោកប៉ាន់ប្រមាណថាប្រជាជនប៉ុន្មាននាក់ នៅពេលលោកធ្វើបដិវត្តន៍? ចម្លើយ៖ អ្វីដែលខ្ញុំអាច និយាយបាននោះ គឺថាមានប្រជាជនមិនលើសពី១ម៉ឺននាក់នោះទេ។ ដូច្នេះលោកកំពុងនិយាយថា ការធ្វើ សក្ខីកម្មស្ទើរតែឯកច្ឆ័ន្ទរបស់ជនភៀនខ្លួននៅក្នុងប្រទេសថៃ និងការបញ្ជាក់របស់សាក្សីផ្សេងទៀតសុទ្ធតែ មិនត្រឹមត្រូវមែនដែរឬទេ? ចម្លើយ៖ អ្វីដែលពួកគេនិយាយនិងមើលឃើញនោះ មិនត្រឹមត្រូវទេ។ មនុស្ស តិចចំនួនណាស់ប្រឆាំងពួកយើង។ ដូច្នេះហើយបានជាយើងបានទទួលជោគជ័យនៅក្នុងសង្គ្រាមរបស់ ប្រជាជនយើង ប្រឆាំងនឹងទាហានឈ្លានពានវៀតណាមក្នុងរយៈពេល១ឆ្នាំមកនេះ។ យើងមិនអាចទទួល ជោគជ័យនោះទេ ប្រសិនបើគ្មានប្រជាជនគាំទ្រដល់យើង។ អំពីការសម្លាប់មនុស្សទាំងនោះ វាជារឿង អតីតកាល”។

[១៤:៣៦:០៣]

ឯកសារបន្ទាប់មកទៀត នៅក្នុងនេះ ដោយធ្វើឡើងដោយ ថ្លែងឡើងដោយ ខៀវ សំផន ពាក់ព័ន្ធ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងក្នុងអំឡុងពេលខ្មែរក្រហមនោះ។ គឺឯកសារ E3/203 វាជាកំណត់ប្រតិចារឹក នៃកិច្ចសម្ភាសន៍ដោយខ្សែអាត់ជាមួយនឹងលោក ខៀវ សំផន ធ្វើឡើងដោយលោក ស្ទីវ ហេដឌ័រ។ យើង ឃើញមានអត្ថបទពាក់ព័ន្ធច្រើនដែរ ដែលទាក់ទងទៅនឹងសង្គ្រាមពីមុនជាមួយនឹងវៀតណាម ជាមួយ

នឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ តែឯកសារនេះ វាក្រោយឆ្នាំ៧៩ ដូច្នេះ ខ្ញុំនឹងមិនលើកយកមកពិភាក្សានៅទីនេះទេ។ ប៉ុន្តែឯកសារនេះ ក៏បានលើកឡើងអំពីការចោទប្រកាន់ដែលកម្ពុជាប្រជាធិប-តេយ្យបានប្រព្រឹត្តឡើងនៅក្នុងពេលនោះ។ នៅក្នុងនេះ គឺបានចាប់ផ្តើម ផ្នែកនេះ គឺចាប់ផ្តើមដោយខ្មែរ ERN 00385409, បារាំងមានលេខ 00434231, អង់គ្លេសមានលេខ 00424013។

ហើយខ្ញុំអានដោយចោះៗទៅនឹងឯកសារ -- ពីឯកសារនេះ ដោយសារវាជាឯកសារមួយវែងណាស់។ ខៀវ សំផន បានឆ្លើយដូចខាងក្រោមនេះ៖ “ក៏ប៉ុន្តែមានមនុស្សស្លូតត្រង់ដែលបានលើកឡើង ខ្ញុំសូមបញ្ជាក់ថា វាមានពាក់ព័ន្ធនឹងយួន។ ខ្មែរដែលជាក្រោមស្ថិតការបិទបាំងរបស់យួននោះ អ្នកទាំងអស់នោះមានតួនាទីសំខាន់ៗណាស់”។ ខាងក្រោមបន្តិច “ដូចដែលលោកបានដឹងហើយក្នុងអំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១ មានវៀតណាមធ្វើការគ្រប់គ្រងនៅក្នុងប្រទេសកម្ពុជា ហើយក្តោបក្តាប់ចលនាកម្ពុជា។ នៅពេលដែលគេបង្កើតភ្នាក់ងាររបស់គេនៅឥណ្ឌូចិនហើយនោះ ពី១ឆ្នាំទៅ១ឆ្នាំវាចេះតែមាននាទីសំខាន់ៗ ហើយវាបង្កប់ខ្លួននៅក្នុងចលនារបស់យើងខ្ញុំ។ នៅក្នុងឆ្នាំ១៩៧៥ អ្នកទាំងអស់នោះហើយមានតួនាទីសំខាន់ៗ”។

[១៤:៣៩:២១]

ខាងក្រោមបន្តិច គឺគាត់បានលើកឡើងអំពីហេតុការណ៍ការប៉ុនប៉ងចាប់ សោ ភឹម ដែលជាលេខាភូមិភាគមួយរូប។ ផ្នែកនោះគឺថាមារៀបរាប់ដូចតទៅ ដកស្រង់សម្តី “ខ្ញុំសូមបញ្ជាក់ថា ហេង សំរិន ឧទាហរណ៍ជាមេបញ្ជាកងពលត្រូវបានរៀបចំដោយយួន។ តាំងពីទសវត្សរ៍៧០ ឬយ៉ាម៉េច? ឆ្លើយ៖ តាំងពីទស្សវត្សរ៍៧០ ខ្ញុំធ្វើការប្រយុទ្ធប្រឆាំងនឹងគាត់ដើម្បីរក្សាទ័ព។ ថាតើពេលណាដែលគាត់រត់ទៅយួន? ឆ្លើយ៖ នៅក្នុងឆ្នាំ៧៧ ពេលដែលយើងខ្ញុំ ៧៧-៧៨ គឺខ្ញុំប្រយុទ្ធហើយ។ សំណួរ៖ មុនព្រឹត្តិការណ៍ សោ ភឹម? ឆ្លើយ៖ ក្នុងពេលព្រឹត្តិការណ៍ សោ ភឹម ហ្នឹងគឺរត់ទៅស្រុកយួន។ សំណួរ៖ លោកបាននិយាយថាអ្នកទាំងអស់នោះប្តូរមាគ៌ា។ ខ្ញុំចង់សួរថាតើពួកគេហ្នឹងមានបានដើរតួនាទីអ្វីខ្លះនៅក្នុងមាគ៌ានុំង? ឆ្លើយ៖ គឺនៅក្នុងនោះគឺថាមានលើកឡើងអំពីការពិភាក្សាដែលថាពាក់ព័ន្ធនឹងមាគ៌ាបក្សពិតជាដូច្នោះមែន។ ពួកគេពិតជាដូច្នោះមែន។ ពួកគេមានតួនាទីសំខាន់ កាន់តួនាទីសំខាន់។ ដូច្នេះពួកគេបានចូលរួមក្នុងការបង្កើតគោលនយោបាយតាំងពីទសវត្សរ៍ទី៦០ គេបានបង្កើតគោលនយោបាយ និងគោលការណ៍ ហើយព្យាយាមគ្រប់គ្រងជោគវាសនារបស់ចលនារបស់ប្រជាជន។ នៅពេលនោះ ប្រជាជននៅទីនោះ ពួកគេជាភ្នាក់ងារយួន បម្រើយុទ្ធសាស្ត្រយួនឥណ្ឌូចិន”។

[១៤:៤១:១២]

ខាងក្រោមបន្តិច "ពួកគេបានធ្វើការងារទៅតាមនេះ ហើយបន្ទាប់មកបានតួនាទីកាន់តែសំខាន់។ ពីចន្លោះឆ្នាំ៧៥ ដល់៧៨ ពួកវាបានអនុវត្តសកម្មភាពរបស់វា"។

ខាងក្រោមបន្តិច "សំណួរ៖ នៅក្នុងឆ្នាំ១៩៧៥ ថាតើពួកគេនៅក្នុងជួរមជ្ឈិមឬក៏ក្នុងអចិន្ត្រៃយ៍របស់មជ្ឈិម។ ពួកហ្នឹងមានប្រហែលជាប៉ុន្មាន? មានច្រើន។ សំណួរ៖ ដល់ពាក់កណ្ដាលទេ? ឆ្លើយ៖ គឺក្នុងមជ្ឈិមពាក់កណ្ដាលទេ តែក្នុងអចិន្ត្រៃយ៍ វាជិតពាក់កណ្ដាល"។ ផ្នែកដែលពាក់ព័ន្ធនៅចំពោះអត្ថបទទាំងអស់នេះគឺថា សមាជិករបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ត្រូវបានគេសម្លាប់ចោលក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យតាមរយៈភស្តុតាងនៅក្នុងសំណុំរឿង។

អត្ថបទមួយទៀតដែលខ្ញុំនឹងអាននោះ គឺពាក់ព័ន្ធទៅនឹងលទ្ធភាព ឬក៏សំណួរថាតើការចាប់ខ្លួននោះទាក់ទងកម្មាភិបាលស្លូតត្រង់ឬយ៉ាងម៉េច? ខ្មែរ ERN គឺ 00385413, បារាំង 00434236។ "សំណួរ៖ ខ្ញុំចង់សួរលោក ក្នុងចំណោមៗបក្សនោះ គឺថាមានអ្នកមួយចំនួនដែលត្រូវបានគេចោទលទោសស្លាប់តាំងពីឆ្នាំ៧៥ មានខ្លះដែលស្លាប់ដោយគ្មានកំហុសទេ ដោយសារគេត្រូវឆ្លើយដាក់ ឬដោយសារតែភ្នាក់ងារយួនការសម្លាប់ពួកហ្នឹង? ឆ្លើយ៖ អ្នកដឹកសំខាន់ៗមិនមានទេ ប៉ុន្តែកម្មាភិបាលខ្លះមាន។ សំណួរ៖ កម្មាភិបាល? ឆ្លើយ៖ ដោយសារតែភ្នាក់ងារយួនវាៗចោទប្រកាន់ដោយរំលោភយ៉ាងនេះ"។

[១៤:៤៣:២២]

កថាខណ្ឌមួយចំនួនខាងក្រោមសួរថា "ប៉ុន្តែពេលដែលខ្ញុំចង់សួរលោកនោះ គឺថានៅពេលនោះមានការចោទប្រកាន់ថាបុគ្គលមួយចំនួនជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ភ្នាក់ងារយួន។ ខ្ញុំចង់សួរថាតើអ្នកទាំងអស់នោះត្រូវបានគេចោទប្រកាន់ថាជាភ្នាក់ងារយួរដែរឬទេ ដើម្បីយកពួកគេមកសម្លាប់ចោល? ដើម្បីសម្លាប់អ្នកស្នេហាជាតិ? តើវាមានកើតឡើងទេក្នុងចំណោមថ្នាក់លើនោះ? ឆ្លើយ៖ ពិតជាមានការកើតឡើង។ មានសមមិត្តមកពីខាងបស្ចិម គាត់គឺជាបុគ្គលចាស់មួយរូប គាត់ត្រូវបានគេចោទប្រកាន់ថាជាភ្នាក់ងារយួន។ ពួកគេទទួលខុសត្រូវ ហើយគេចោទប្រកាន់គាត់ ប៉ុន្តែបញ្ហានេះគឺមិនបានចោទប្រកាន់សម្រេចនោះទេ តែយើងជាអ្នកស៊ើបអង្កេតបញ្ហាហ្នឹងបានទាន់ពេលវេលា"។

[១៤:៤៤:១៧]

មុនពេលដែលខ្ញុំបញ្ចប់ឯកសារនេះ ខ្ញុំសូមបញ្ជាក់ថា កិច្ចសម្ភាសន៍ កាលបរិច្ឆេទកិច្ចសម្ភាសន៍នោះ គឺនៅក្នុងឆ្នាំ១៩៩១។ ប្រសិនបើយើងមើលឯកសារផ្សេងទៀតដែលខ្ញុំយកមកបង្ហាញក្នុងបទបង្ហាញ

របស់ខ្ញុំពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនោះ គឺឯកសារ E3/687 គឺឯកសារញូវយ៉កថែមស៍ អត្ថបទញូវយ៉កថែមស៍ ចុះថ្ងៃ០៩ កក្កដា ៨២ គឺកត់ត្រាទុកចម្លើយតបរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ជាសម្ព័ន្ធមិត្ត។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥នាទី ដល់ម៉ោង ១៥:១០ នាទី)*

[១៥:១០:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារ។

ឈប់សិនតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សួស្តីសហព្រះរាជអាជ្ញាសហភាគី។ សួស្តីលោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះ។ ខ្ញុំស្នើសុំសហព្រះរាជអាជ្ញាកុំលើកឯកសារណាដែលគាំទ្រទៅលើអង្គហេតុ ឬបទល្មើសចោទប្រកាន់ទៅលើជនជាប់ចោទ។ ពីព្រោះនៅទីនេះ យើងនិយាយតែពីតួនាទី គឺមុខងារ និងនាទីរបស់ជនជាប់ចោទម្នាក់ៗទេ។ មានចែងច្បាស់នៅក្នុងដីកាលេខ E124 ហើយនិងមានលម្អិតនៅក្នុង E124/7.3។

[១៥:១១:៤៣]

ឧទាហរណ៍ដូចជាចង់និយាយ -- ខ្ញុំមិនលើកពីជនជាប់ចោទផ្សេងទេ ខ្ញុំចង់លើកពីលោក អៀង សារី តែម្តង។ ឧបមាថា ចង់និយាយពីតួនាទីរបស់គាត់អីជាសមាជិកមជ្ឈិម គណៈមជ្ឈិម ជាសមាជិកគណៈអចិន្ត្រៃយ៍ ជារដ្ឋមន្ត្រីក្រសួងការបរទេស។ បង្ហាញតែឯកសារហ្នឹងមកថា គាត់មានមុខងារមានតួនាទីអីចឹងមែន។ បើសិនជាយើងពន្លាតយកឯកសារ ឬអានចម្លើយទាំងឡាយណាដែលដាក់បន្ទុកទៅលើជនជាប់ចោទ អានេះវាខុសពីគោលដៅដែលយើងកំពុងធ្វើនេះ ព្រោះសវនាការយើងនេះបើខ្ញុំយល់មិនច្រឡំទេ និយាយពីរឿង អង់គ្លេសហៅថា“រ៉ូល” បានន័យ នាទី ឬមុខងាររបស់ជនជាប់ចោទហ្នឹងម្នាក់ៗ កាលនុ៎ងធ្វើអី? ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យធ្វើអី? មុននឹងធ្វើអី? ជាស្អីប៉ុណ្ណឹងតើ! ដើម្បីចាប់អ្នកទាំងអស់ហ្នឹងកុំឲ្យប្រកែកថាមិនមែនទេ! មិនមែនកាន់នាទីហ្នឹងទេ! តែប៉ុណ្ណឹងតើ! បើសិនជាយើងពន្លាតទៅដល់អី ការទទួលខុសត្រូវលើបទល្មើស អាហ្នឹងវាខុសពីគោលដៅនៃសវនាការយើងនៅនេះហើយ។ ពីព្រោះកិច្ចការទាំងនោះ យើងកំពុងតែហៅសាក្សី និងអ្នកជំនាញដទៃមកសួរដេញដោលជាបណ្តើរៗហើយទេ។ សូមអរគុណ។

[១៥:១៣:២១]

**លោក អាប់ឌុលឡាក់ ថាវីកៈ**

លោកប្រធាន ខ្ញុំសូមអញ្ញាតដើម្បីឆ្លើយតបដូចទៅនេះ។ សហភាតាខ្ញុំនិយាយដោយខុស ទាក់ទងទៅនឹងភាពពាក់ព័ន្ធជាមួយនឹងចំណុចនានានៅក្នុងដីកាដំណោះស្រាយ ដែលការបង្ហាញនេះបានលើកឡើងឯកសារ E124 ដែលបាននិយាយអំពីកថាខណ្ឌដែលពាក់ព័ន្ធទៅនឹងការជំនុំជម្រះអំពីតួនាទីរបស់ជនជាប់ចោទ ក៏ដូចជាការលើកបង្ហាញអំពីតួនាទីរបស់លោក ខៀវ សំផន កថាខណ្ឌនៅចាប់ផ្តើមពីលេខ១១២៤, ១១២៦ ខ្ញុំសូមលើកឡើងថា “គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ក៏ដូចជាតួនាទីរបស់គណៈប្រធានរដ្ឋ ក៏ដូចជាក្រសួងពាណិជ្ជកម្ម...។ល។” ចំពោះខ្ញុំ ខ្ញុំគិតថាអ្វីដែលបានលើកឡើងទាក់ទងទៅនឹងបទបង្ហាញរបស់លោក អៀង សារី គឺថាបានបញ្ចប់។ ខ្ញុំសូមបញ្ជាក់ថា ការធ្វើបទបង្ហាញអំពីលោក អៀង សារី គឺនិយាយដោយផ្ទាល់តែទៅលើតួនាទីរបស់គាត់ ហើយចំពោះ ខៀវ សំផន ក៏យើងលើកយកតែទៅលើអ្វីដែលបាននិយាយនៅក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយតែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

[១៥:១៤:៤២]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធានសាថ្មី ហើយខ្ញុំសូមការអនុញ្ញាត។ ខ្ញុំមិនឡើងមកជំទាស់នឹងការសួរទេ តែខ្ញុំស្នើដល់ព្រះរាជអាជ្ញាសូមកុំឱ្យធ្វើបែបនេះប៉ុណ្ណោះ ព្រោះធ្វើយ៉ាងនេះវាអាចនឹងជាន់កិច្ចការដែលយើងបានធ្វើកន្លងមកហើយ ឬនឹងធ្វើទៅអនាគតតែប៉ុណ្ណឹងទេ។ ហើយពីព្រោះយើងកុំឱ្យខាតពេលវេលាផង យើងគួរតែធ្វើឱ្យត្រូវតាមក្រឹត្យក្រមប៉ុណ្ណឹងទេ ហើយបើសិនជាធ្វើបែបនេះបានយើងនឹងចំណេញពេលវេលាច្រើនតែប៉ុណ្ណឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាធ្វើតាមបច្ចេកទេសដែលលោកបានធ្វើចុះ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

មុនពេលដែលយើងឈប់សម្រាក យើងបានមើលឯកសារ E3/687 ដែលខ្ញុំបានបញ្ជាក់ថា ផ្នែកដែលពាក់ព័ន្ធគឺថា ទាក់ទងទៅនឹងពេលវេលា ហើយនេះជាកិច្ចសម្ភាសន៍នៅថ្ងៃទី០៩ កក្កដា ឆ្នាំ១៩៨២ ជាមួយសារព័ត៌មានញូវយ៉កថែមស៍។ ហើយការសម្ភាសនេះបានបញ្ជាក់ថា ខៀវ សំផន បានបញ្ជាក់ថា គាត់បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចជាសមូហភាព ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយកម្លាំង។ គឺឯកសារ E3/687 ខ្មែរមានលេខ 00681187, ភាសាបារាំងមាន 006225450, អង់គ្លេសមានលេខ 00122280។ នៅត្រង់ចំណុចនេះ លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញនូវខ្សែវីដេអូខ្លីមួយ ដែលមានរយៈពេលប្រហែលជាតិចជាង ៣នាទីតែប៉ុណ្ណោះ គឺចាប់ពីឆ្នាំ៨៣ -- បើផ្អែកទៅលើព័ត៌មាននៅក្នុងសំណុំរឿង គឺជាកិច្ចសម្ភាសន៍ជាមួយលោក ខៀវ សំផន។ ហើយឯកសារដែលពាក់ព័ន្ធគឺមានលេខ D232/110.1.1.6R ហើយនៅក្នុងបញ្ជីរបស់ខាងសោតទស្សន៍គឺខ្សែវីដេអូ E។ ដូច្នេះសូមអនុញ្ញាតលោកប្រធានមេត្តាឱ្យខាងផ្នែកសោតទស្សន៍ចាក់បង្ហាញនូវខ្សែវីដេអូនេះ។ សូមលោកប្រធានអនុញ្ញាត។

[១៥:១៧:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! បុគ្គលិកបច្ចេកទេសខាងសោតទស្សន៍ចាក់ផ្សាយវីដេអូលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៥:១៧:៣៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អ្នកសម្ភាសៈ លោកប្រធាន លោកដឹងថារូបភាពរបស់ខ្មែរក្រហមមានលក្ខណៈអវិជ្ជមានដល់កម្រិតណាហើយ? ខ្មែរក្រហមត្រូវបានផ្សារភ្ជាប់ទៅនឹងអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាលប្រជាជនកម្ពុជាអស់រាប់សែននាក់។ តើលោកបដិសេធពិរុទ្ធភាពទាំងស្រុងតែម្ដង ឬក៏លោកទទួលខុសត្រូវខ្លះដែរ?" ខៀវ សំផន "ពិតជាមានការប្រព្រឹត្តកំហុសមែន។ ប៉ុន្តែខ្ញុំសូមធានាថា កំហុសទាំងអស់នេះត្រូវបានប្រព្រឹត្តពាក់ព័ន្ធទៅនឹងការសម្លាប់។ លោកអាចយល់ច្បាស់អំពីសភាពការណ៍ក្រោយសង្គ្រាមហើយ ក្នុងគ្រប់បដិវត្តន៍ទាំងអស់តែងតែមានការប្រព្រឹត្តហួសហេតុនៅទីនេះ នៅទីនោះ ហើយករណីនៃបដិវត្តន៍របស់យើងក៏មិនខុសគ្នានោះដែរ។ វាមានការសងសឹកផ្ទាល់ខ្លួន ការសងសឹកពីសំណាក់អ្នកជនបទមួយចំនួនទៅលើអ្នកមកពីទីក្រុង។ យើងបានប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីបញ្ឈប់ ឬបញ្ចៀសការសងសឹក។ ប៉ុន្តែការនិយាយថា មានការសម្លាប់រង្គាលជាប្រព័ន្ធនោះ ខ្ញុំសូមធានាថាគ្មានទេ"។ អ្នកសម្ភាស "ឈ្មោះរបស់ប៉ុល ពត ត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងការសម្លាប់រង្គាល។ នៅពេលគេនិយាយពីប៉ុល ពត គឺគេសំដៅទៅដល់ឃាតករបាតដៃប្រឡាក់ឈាម។ ក៏ប៉ុន្តែឥឡូវនេះ ប៉ុល ពត មិនកាន់អំណាចទៀតទេ ហើយលោកជំនួស ប៉ុល ពត តើលោកមិនយល់ស្របនឹងការសម្រេចមុនៗរបស់ប៉ុល ពត ដែរឬទេ?" ខៀវ សំផនៈ "ប៉ុល ពត មិនមានតួនាទីអវិជ្ជមាននោះទេ។ គាត់ដូចជាយើងទាំងអស់គ្នាដែរ គាត់ជាអ្នកស្នេហាជាតិដ៏ស្មោះត្រង់ម្នាក់។ ប៉ុល ពត ស្រឡាញ់ប្រជាជន។ ប៉ុល ពត ស្រឡាញ់ប្រទេសជាតិដូចយើងទាំងអស់គ្នា ដូចខ្ញុំដែរ ហើយប្រជាជនក៏ដឹងដែរ។ ប្រជាជនយើងដឹងថា យើងបានប្រព្រឹត្តកំហុស កំហុសនេះ កំហុសនោះ។ ប៉ុន្តែប្រជាជនយើង ក៏ដឹងផងដែរថា យើងបានលះបង់គ្រប់បែបយ៉ាង ដើម្បីប្រជាជន និងមាតុភូមិយើង។ ចំណុចនេះ ប្រជាជនក៏ដឹងដែរ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២០:៤២]

**លោក អាប់ឌុលឡាក់ ថារីកៈ**

សូមអរគុណ។

លោក លោកស្រីចៅក្រម ភាពពាក់ព័ន្ធនៃឯកសារវីដេអូមួយនេះ គឺជាការពិភាក្សារបស់លោក ខៀវ សំផន ដែលនិយាយអំពីមូលហេតុដែលនាំទៅដល់បទឧក្រិដ្ឋ ក៏ដូចជាតួនាទីរបស់គាត់

ជាមួយនឹង ប៉ុល ពត។ ឯកសារបន្ទាប់ដែលខ្ញុំនឹងធ្វើការបង្ហាញជូនអស់លោក លោកស្រីចៅក្រម គឺ E3/703។ ឯកសារចុះថ្ងៃ១៥ កក្កដា ឆ្នាំ១៩៨៧ គឺឯកសារនេះ ចេញពីការិយាល័យ ទីស្ដីការអនុប្រធាន កម្ពុជាប្រជាធិបតេយ្យ ហើយនៅពេលនោះ គឺជារបស់ ខៀវ សំផន។ ឯកសារនេះ មានចំណងជើងថា "តើមានការពិត និងយុត្តិធម៌អ្វីខ្លះអំពីការចោទប្រកាន់នានា ទៅលើកម្ពុជាប្រជាធិបតេយ្យចំពោះការសម្លាប់រង្គាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨"។ នេះគឺឯកសារមួយដែលមានទំហំវែង ដូច្នេះខ្ញុំសូមដកស្រង់តែផ្នែកមួយចំនួនតែប៉ុណ្ណោះ។ គឺដកស្រង់អំពីអំពើឃោរឃៅ និងការទទួលខុសត្រូវ។ ឯកសារនេះបានបដិសេធថា រដ្ឋាភិបាលមិនបានទទួលខុសត្រូវទៅលើការស្លាប់របស់ប្រជាជនជាទ្រង់ទ្រាយធំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

[១៥:២២:២៧]

ហើយខ្មែរ ERN មានលេខ 00700550, ភាសាបារាំងមានលេខ 00693794 ហើយនិងទំព័របន្តបន្ទាប់ ភាសាអង់គ្លេស 00004001។ ក្នុងផ្នែកនោះ គឺមាននិយាយចំណងជើងថា "ប្រជាជនដែលសម្លាប់ដោយមូលហេតុផ្សេងៗ ចន្លោះពីអំឡុងពេលគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ៧៥ ដល់៧៨។ ១) ចំនួនប្រជាជនស្លាប់ដោយសារជំងឺ និងកង្វះម្ហូបអាហារ។ តាមរយៈការវាយតម្លៃបឋម ប៉ុន្តែធ្វើឡើងដោយមានការយកចិត្តទុក ចំនួនប្រជាជនដែលបានស្លាប់ដោយសារជំងឺ និងកង្វះម្ហូបអាហារក្នុងអំឡុងរយៈ៣ឆ្នាំទូទាំងប្រទេស បានកើនឡើងរហូតដល់លើស២០.០០០នាក់ ដែលភាគច្រើនគឺជាប្រជាជនដែលត្រូវបានជម្លៀសចេញពីបណ្ដារទីក្រុង មិនធ្លាប់ហែលឆ្លងកាត់ការលំបាកនៅតាមជនបទ។ កង្វះម្ហូបអាហារជាក់ស្ដែង គឺបណ្ដាលមកពីភ្នាក់ងារបានជ្រៀតចូលទៅក្នុងស្ថាប័ននានារបស់រដ្ឋ ដែលជាអ្នកធ្វើសកម្មភាពវិទ្ធង្សនានានា ជាពិសេស ដើម្បីបំផ្លិចបំផ្លាញឱសថ និងសម្ភារៈផ្សេងៗទៀត ព្រមទាំងបានលួចយកស្រូវអង្ករចំនួន១០ពាន់តោនជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ដែលបញ្ជូនស្រូវអង្ករទាំងនោះ ទៅកាន់ប្រទេសវៀតណាម"។

[១៥:២៣:៥៧]

ផ្នែកបន្ទាប់គឺរៀបរាប់អំពីប្រភព ឬក៏មូលហេតុនៃការស្លាប់របស់ប្រជាជនមួយទៀត។ ខ្មែរ ERN មានលេខ 00700551 ដល់552, ភាសាបារាំង គឺមានលេខ 00693796 ដល់7, ភាសាអង់គ្លេស គឺមានលេខ 00004002។ គឺនៅក្នុងលេខរៀងទី២ "ចំនួនប្រជាជនដែលស្លាប់ដោយការរំលោភបំពានគោលនយោបាយរដ្ឋរបស់ភ្នាក់ងារវៀតណាម។ ជាលទ្ធផលនៃសកម្មភាពឧក្រិដ្ឋផ្សេងៗរបស់ភ្នាក់ងារ

វៀតណាម ប្រជាជនចំនួន១០.០០០នាក់បានស្លាប់។ វៀតណាម និងភ្នាក់ងាររបស់គេមានផែនការសម្លាប់ប្រជាជនឲ្យបានច្រើនតាមដែលអាចទៅធ្វើបាន ប៉ុន្តែពួកគេមិនអាចអនុវត្តផែនការរបស់ខ្លួនបានដូចបំណងទេ ដោយសារកម្មាភិបាលដ៏ច្រើនលើសលប់របស់យើង គឺជាមនុស្សមានការប្តេជ្ញាខ្ពស់ និងមានការគាំទ្រពីប្រជាជន”។

ផ្នែកបន្ទាប់គឺជាចំណុចដែលពាក់ព័ន្ធសំខាន់ គឺនិយាយអំពីចំនួនប្រជាជនដែលស្លាប់ដោយសារកំហុសរបស់យើង។ ខ្ញុំសូមដកស្រង់នូវក្នុងផ្នែកនេះ “ស្ថានភាពនេះកាន់តែធ្វើឲ្យមានការភាន់ច្រឡំថែមទៀតដោយសារសកម្មភាពវិទ្ធង្សនានានារបស់ភ្នាក់ងារវៀតណាម។ ហេតុនេះនៅក្នុងវិធានការរបស់យើងក្នុងការចាប់ខ្លួន និងដាក់ទណ្ឌកម្មទៅលើភ្នាក់ងារវៀតណាមទាំងនោះ យើងបានប្រព្រឹត្តកំហុសដែលបានធ្វើឲ្យប៉ះពាល់ដល់ជីវិតអ្នកដែលបានប្រព្រឹត្តបទល្មើសតូចតាច ដូចជនស៊ីលវិលមិនមានកំហុសចំនួន។ ក្នុងរយៈកាលពីឆ្នាំ៧៥ ដល់៧៨ មានប្រជាជនក្នុងចំនួនលើសពីរបីពាន់នាក់បានស្លាប់ដោយសារហេតុផលដែលបានលើកឡើងនេះ។ ដោយយើងមានលទ្ធភាពក្នុងការងារកម្ចាត់ភ្នាក់ងារវៀតណាមដែលបានជ្រៀតចូលក្នុងស្ថាប័ននានារបស់រដ្ឋយើង យើងក៏អាចមានលទ្ធក្នុងការការពារមិនឲ្យមានកំហុសបែបនោះកើតមានជាបន្តបន្ទាប់”។

[១៥:២៥:៥៦]

នៅចំណុចក្រោមបន្តិច គាត់បានរៀបរាប់អំពីវិធីសាស្ត្រក្នុងការកាត់បន្ថយចំនួនមនុស្សដែលបានស្លាប់ “យើងមានគោលនយោបាយតឹងរ៉ឹងចំពោះសត្រូវរបស់ជាតិ ហើយយើងបានអនុវត្តដូចតទៅនេះ៖

ទី១ អប់រំប្រជាជនដែលយើងមានភស្តុតាងច្បាស់ថាគេជាភ្នាក់ងារខ្មាំង។ ទី២ ដកយកតំណែងតួនាទីរបស់ពួកគេ ហើយបញ្ជូនពួកគេឲ្យទៅធ្វើការនៅក្នុងសហករណ៍ ឬកសិកដ្ឋានរបស់រដ្ឋដូចប្រជាជនសាមញ្ញ ដើម្បីឲ្យពួកគេអាចអប់រំខ្លួនឯងបាន។ ភ្នាក់ងារវៀតណាមមួយចំនួនតូចដែលបានបន្តអនុវត្តសកម្មភាពនានាជាប្រព័ន្ធ ដើម្បីផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចាប់ខ្លួន ឃុំខ្លួន និងដាក់ទោស”។

ផ្នែកបន្ទាប់ គឺផ្នែកលេខ៤ រៀបរាប់អំពីចំនួនប្រជាជនដែលបានស្លាប់ដោយសារតែការវាយប្រយុទ្ធជាមួយនឹងជនក្បត់។ ចំនួនប្រជាជនដែលបានស្លាប់ដោយសារការតស៊ូប្រឆាំងនឹងខ្មាំង ជាពិសេសនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ គឺមានចំនួនតែប៉ុន្មានសិបនាក់ប៉ុណ្ណោះ។ យើងមានលទ្ធភាពដោយរក្សានេះអាចឲ្យនៅទាបដោយសារយើងបានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីចាប់ខ្លួនជនក្បត់។ យើង

មិនបានបញ្ជូនអង្គភាពកងទ័ពទាំងមូលដើម្បីចាប់ខ្លួនទីបញ្ជាការមជ្ឈិម ឬមន្ទីរមជ្ឈិម ឬភូមិភាគមជ្ឈិម និងបញ្ជាការថ្នាក់ខេត្តនោះទេ។ យើងបានធ្វើការចាប់ខ្លួនម្នាក់ ឬពីរនាក់ ក្នុងមួយលើក។

[១៥:២៧:៣៦]

បន្ទាប់មកទៀត គាត់និយាយអំពីការចាប់ខ្លួន សោម ភីម។ ផ្នែកដែលពាក់ព័ន្ធក្នុងអត្ថបទមួយនេះ គឺអំពីការ និយាយអំពីការផ្តោតអំណាចជារួមក៏ដូចជាគោលនយោបាយជារួមក្នុងការចាប់ខ្លួនខ្មាំង។ ហើយនៅក្នុងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ នេះគឺខ្មែរមានលេខ 00700556, ភាសាបារាំង គឺមានលេខ 00693798 ដល់ 799 និងភាសាអង់គ្លេសមានលេខ 00004004។ ខ្ញុំសូមដកស្រង់ "ចំពោះការបាត់ជីវិតប្រជាជនកម្ពុជា ទោះបីជាដោយសារមូលហេតុអ្វីក៏ដោយដែលស្ថិតក្នុងរយៈពេលនោះ គឺវាស្ថិតក្នុងចំនួនតូចមួយបើធៀបជាមួយបណ្តាប្រទេសឯទៀតនៅក្នុងពិភពលោកដែលពេលកំពុងស្ថិតក្នុងកាលៈទេសៈប្រែប្រួលនៃប្រវត្តិសាស្ត្រដ៏ធំ ឬអំឡុងពេលសន្តិភាពនោះ។ ទោះបីជាយើងត្រូវប្រឈមជាមួយសកម្មភាពវិទ្ធង្សនានានារបស់វៀតណាមនៅកម្ពុជា ព្រមទាំងជាមួយសកម្មភាពឈ្លានពានទឹកដីនានានៅតាមព្រំដែនក្តី យើងតែងតែពឹងផ្អែកលើប្រជាជនក្នុងការបំបែកវិទ្ធង្សនាទាំងនេះ ដើម្បីការពារប្រទេសយើង"។

[១៥:២៩:១២]

ចុះក្រោមបន្តិច "យើងអាចមានលទ្ធភាពធ្វើដូច្នេះបាន ដោយសារយើងមានជំនឿជឿជាក់របស់យើងទៅលើប្រជាជន ព្រមជាមួយនឹងគាំទ្ររបស់ពួកគាត់។ ហ្នឹងក៏ដោយសារយើងគ្រប់គ្រងស្ថានភាពបានពេញលេញតាមរយៈការគ្រប់គ្រងមនុស្សនៅតាមបណ្តាលមន្ទីរ និងសហករណ៍នានា"។

ជាចុងក្រោយនៅទំព័របន្ទាប់ជាបីភាសា គាត់បានធ្វើការសន្និដ្ឋានដូចតទៅនេះ។ ខ្ញុំសូមដកស្រង់ "និយាយឲ្យយុត្តិធម៌ ចំនួនប្រជាជនដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ គឺមានចំនួនតិចតួចជាងចំនួនប្រជាជនដែលបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍យានយន្តប្រចាំឆ្នាំនៅតាមបណ្តាប្រទេសមួយចំនួនដែលជារៀងរាល់ឆ្នាំមានចំនួន ៣០.០០០នាក់ ឬមានអ្នកស្លាប់ច្រើនលើសនេះដោយសារគ្រោះថ្នាក់ចរាចរណ៍។ មុនពេលដែលខ្ញុំបញ្ចប់របាយការណ៍នេះ ខ្ញុំសូមបញ្ជាក់ដើម្បីជាកំណត់ត្រាថា ឯកសារបន្តគឺនិយាយ គឺបានចោទប្រកាន់ថាការស្លាប់ប្រជាជនជាង២លាននាក់ហ្នឹង គឺជាកំហុសរបស់វៀតណាមចន្លោះពីឆ្នាំ៧៩មក។

[១៥:៣០:៣១]

ឯកសារបន្ទាប់លោកប្រធាន គឺជាឯកសារដែលលោក ខៀវ សំផន បាននិយាយអំពីតួនាទីរបស់គាត់នៅក្នុងរបប ហើយនិងការដឹងរបស់គាត់អំពីគោលនយោបាយ ក៏ដូចជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺឯកសារដែលមានលេខ D366/7.1.72។ គឺជាកិច្ចសម្ភាសន៍ជាមួយនឹងសារព័ត៌មានបារាំងឈ្មោះថា ឡឺម៉ុងដ៍។ ហើយខ្ញុំនឹងធ្វើការដកស្រង់នូវការសម្ភាសចំនួនពីរផ្នែកពីការសម្ភាសទាំងមូល។ ខ្មែរ ERN មានលេខ 00002735, ភាសាបារាំងមានលេខ 00710202 និងភាសាអង់គ្លេសមានលេខ 00716438។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ "ប៉ុល ពត បាននិយាយអំពីខ្មាំងទាំងនៅក្នុង និងខាងក្រៅ។ ប៉ុន្តែខ្ញុំយល់ឃើញថា វាជាការធម្មតា ដោយសារតែយើងជាបដិវត្តន៍។ ក្នុងនាមនៃរដ្ឋអំណាចបដិវត្តន៍ក្មេងខ្ចីមួយ ដែលទទួលនូវរងទុក្ខវេទនាច្រើនណាស់មកហើយ"។

ហើយកថាខណ្ឌបន្ទាប់ ពីឆ្នាំ៧៥ ដល់៧៩ លោក ខៀវ សំផន រៀបរាប់ថា "ពុំមានការពិភាក្សាខាងនយោបាយទេ។ សម័យប្រជុំទាំងអស់របស់ការិយាល័យនយោបាយ ដែលត្រូវបានអញ្ជើញគឺជាការនិយាយតែម្នាក់របស់ ប៉ុល ពត។ ហើយនៅក្នុងឆ្នាំ១៩៩៨ ក្នុងស្ថានភាពមួយមិនត្រូវបានច្បាស់លាស់គឺបន្ទាប់ពីសង្គ្រាម។ ប៉ុន្តែគ្រប់គ្នាដែលនៅក្នុង -- គ្រប់គ្នាបានបន្តទះដៃសាទរគាត់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ហើយគាំទ្រការសម្រេចចិត្តផ្សេងៗរបស់គាត់ ពីព្រោះគាត់បានលើកឡើងពីគ្រោះថ្នាក់ដែលបង្ហាញជាថ្មីរបស់ សេ.អ៊ី.អា អាមេរិក និងពួកវៀតណាម"។ នេះជាសេចក្តីឆ្លើយដោះសាដោយខ្លីបន្តិចនៅពេលដែលការធ្វើវិសុទ្ធកម្មផ្ទៃក្នុងម៉ាស៊ីនដឹកនាំកុម្មុយនីស្តបានបន្ត។

[១៥:៣២:៤៣]

កថាខណ្ឌបន្ទាប់នៃអត្ថបទមួយនេះ ខ្មែរមានលេខ 00002738 ដល់ 39, បារាំងមានលេខ 00710204 និងអង់គ្លេសមានលេខ 00716442។ ខ្ញុំសូមដកស្រង់ "ទោះបីជាមាន ដោយទទួលស្គាល់ភាពយឺតពេលទៅហើយនូវការប្រល័យពូជសាសន៍ ខៀវ សំផន បានបន្តបញ្ចេញឲ្យដឹងគំនិតនិន្នាការផ្ទុយគ្នាចំពោះមេដឹកនាំខ្មែរក្រហមដដែល"។ គាត់បានរំឭកថា "ចំពោះខ្ញុំ ប៉ុល ពត នៅតែមានមនុស្សដែលគួរឲ្យស្រឡាញ់ចូលចិត្ត ហើយខ្ញុំអាចនិយាយថា គាត់កោតសរសើរខ្ញុំជាបញ្ញវន្តស្នេហាជាតិ។ ចំពោះខ្ញុំ ប៉ុល ពត បានប្រៀបធៀបទំនាក់ទំនងរបស់យើងទៅនឹងទំនាក់ទំនងរវាង ឡេនីន និង ហ្គូកគី ដែលហាក់ដូចជា គឺថាពួកបញ្ញវន្តមិនដែលយកជើងជាន់ដីទេ"។

ចំពោះរឿង តាម៉ុក ដែលថាការធ្វើសម្ព័ន្ធភាពជាមួយ ប៉ុល ពត មានលក្ខណៈដាច់ខាត។ ខៀវ សំផន បានដំណាលថា "ក្នុងសម័យប្រជុំផ្សេងៗ តាម៉ុក មិនដែលកត់ត្រាទុក។ នៅពេលដែល ប៉ុល ពត

ស្តីបន្ទោសឲ្យគាត់ តាម៉ុក ក៏ចាប់ផ្តើមសរសេរកត់ត្រានៅលើក្រដាសមូលបារី។ តែគាត់ធ្លាប់ដែលត្រូវគំរាមកំហែងដោយគណៈដឹកនាំខ្មែរក្រហមដែរឬទេ? ខៀវ សំផន ឆ្លើយថា៖ និយាយដោយត្រង់ទៅមិនដែលទេ។ ទោះបីជា តាម៉ុក ចូលចិត្តខ្ញុំក៏ដោយ ក៏ខ្ញុំមិនដែលមានបញ្ហាជាមួយគាត់ដែរ”។

ភាពពាក់ព័ន្ធនៃឯកសារមួយនេះ គឺចង់បង្ហាញថាវាជារបាយការណ៍ដែល ខៀវ សំផន បានទទួលស្គាល់ក្នុងការចូលរួមក្នុងកិច្ចប្រជុំ ក៏ដូចជាទំនាក់ទំនងរបស់គាត់ជាមួយ ប៉ុល ពត ហើយនិងការចូលរួមរបស់គាត់នៅក្នុងការប្រជុំរវាង តាម៉ុក និង ប៉ុល ពត ឬក៏យើងអាចនិយាយថា គាត់មានវត្តមាននៅពេលដែល តាម៉ុក ជាមួយ ប៉ុល ពត បានជួបប្រជុំគ្នា។

[១៥:៣៤:៣៦]

ឯកសារបន្ទាប់គឺ E3/198 គឺជាកិច្ចសម្ភាសន៍នៅឆ្នាំ២០០៩ របស់ ខៀវ សំផន ជាមួយនឹងសូអាស គឺជាសាលារៀនមួយនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង គឺជាឯកសារខ្លីមួយ។ ឯកសារដែលលើកយកមកនិយាយនេះ គឺបានបញ្ជាក់នូវព័ត៌មានមួយចំនួន គឺការបញ្ជាក់របស់ ខៀវ សំផន ដែលថាគណៈមជ្ឈិមបានទទួលរបាយការណ៍ពីខាងភូមិភាគ។ ទោះបីជាគាត់ធ្លាប់បាននិយាយថា ខាងគណៈមជ្ឈិមមិនអាចគ្រប់គ្រងទៅលើខាងភូមិភាគបានក៏ដោយ។ នៅក្នុងឯកសារនេះគាត់ក៏បានបញ្ជាក់ថាគាត់បានដឹងអំពីការចាប់នៅភូមិភាគឧត្តរ បន្ទាប់ពីគេឲ្យ កង ចាប ធ្វើជាអ្នកទទួលខុសត្រូវ។

មុនពេលដែលយើងបន្តទៅសៀវភៅពីរក្បាលទៀត ដែលនិពន្ធដោយលោក ខៀវ សំផន ខ្ញុំសូមអនុញ្ញាតចាក់បង្ហាញនូវវីដេអូឯកសារដែលយើងបានឃើញពីមុនរួចមកហើយ គឺឯកសារដែលមានចំណងជើងថា “ប៉ុល ពត និង ខៀវ សំផន ត្រូវប្រឈមជាមួយបទប្រល័យពូជសាសន៍” ដែលធ្វើនៅឆ្នាំ២០០៧ ឬក៏២០០៨ ដែលមាននូវខ្សែវីដេអូដែលជាការសម្ភាសជាមួយនឹងលោក ខៀវ សំផន គឺឯកសារ E109/2.3R។ ហើយនៅក្នុងតារាង អេ.វី គឺបង្ហាញថាជាខ្សែវីដេអូអក្សរ លី (តាមសំឡេងបកប្រែ)។

[១៥:៣៦:៤៤]

លោកប្រធានខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធានអនុញ្ញាតឲ្យបង្ហាញនូវផ្នែកទី១ នៃខ្សែវីដេអូនេះ ហើយសូមឲ្យខាង អេ.វី ចាក់បង្ហាញនូវខ្សែវីដេអូដែលមានចំណងជើង ដូចខ្ញុំបានបញ្ជាក់ពីខាងលើ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! បុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍

តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៥:៣៧:២៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“នៅពេលដែលយើងសួរខៀវ សំផន អំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម គាត់បានស្វែងរកសៀវភៅនៅក្នុង -- បើកទំព័រនានានៅក្នុងសៀវភៅរបស់គាត់។ គាត់ត្រូវតែបើកមើលសៀវភៅរបស់គាត់ជាមុនសិន មុននឹងធ្វើការឆ្លើយ។ ខៀវ សំផន៖ ទី១ អ្នកនិពន្ធភាគច្រើនបានប្រព្រឹត្តកំហុសជាច្រើនក្នុងការបកស្រាយហេតុការណ៍។ ឧទាហរណ៍ អ្នកនិពន្ធទាំងនេះ ក្នុងនោះមានលោក ប៊ែន ឃៀរនិន ផងដែរ សរសេរថា ក្នុងក្របខ័ណ្ឌនៃយុទ្ធនាការណ៍ប្រឆាំងនឹងការត្រួតត្រារបស់ពួកកុម្មុយនីស្តវៀតណាម ប៉ុល ពត បានចងសម្ព័ន្ធភាពជាមួយ តាម៉ុក និង កែ ពក ដើម្បីប្រឆាំងនឹងសោ ភឹម។ បើតាមយោបល់របស់លោក តើមានមនុស្សស្លាប់ប៉ុន្មាននាក់នៅក្នុងរបបខ្មែរក្រហម? ខៀវ សំផន៖ ខ្ញុំមិនអាចប្រាប់ពីតួលេខពិតប្រាកដនោះទេ ពិតណាស់ថា មានច្រើន ក៏ប៉ុន្តែខ្ញុំមិនជឿថាមានមនុស្សស្លាប់រហូតទៅដល់២លាននាក់នោះទេ។ វាដូចជាពន្លើសបន្តិចហើយ។ អ្នកសម្ភាស៖ តើលោកទទួលខុសត្រូវអ្វីខ្លះចំពោះអ្វីដែលបានកើតឡើង? ខៀវ សំផន៖ ការទទួលសខុសត្រូវរបស់ខ្ញុំ? អ្នកសម្ភាស៖ ពិតមែនហើយ។ លោក ខៀវ សំផន៖ ខ្ញុំគ្មានអំណាចអ្វីទាល់តែសោះ។ បើនិយាយអំពីការទទួលខុសត្រូវ គេមិនអាចបន្ទោសខ្ញុំបានទេ ពីព្រោះថាខ្ញុំមិនដឹងអ្វីទាំងអស់។ ខ្ញុំមិនដឹងរឿងអ្វីទាល់តែសោះ។ ហេតុអ្វីបានជាខ្ញុំមិនដឹង? ហេតុអ្វីបានជាខ្ញុំមិនព្យាយាមចង់ដឹង? ប្រហែលជាលោកអាចបន្ទោសខ្ញុំបានពីការទទួលខុសត្រូវនោះ។ ប៉ុន្តែចំពោះខ្ញុំបានជាខ្ញុំមិនព្យាយាមចង់ដឹង គឺដោយសារតែខ្ញុំគោរពវិន័យបក្ស។ អ្នកសម្ភាស៖ តើលោកមានអារម្មណ៍ថាត្រូវបាន ប៉ុល ពត បោកប្រាស់ដោយមិនបានប្រាប់ព័ត៌មានទាំងអស់នោះឲ្យលោកដឹងដែរឬទេ? ខៀវ សំផន៖ ទេ។ ពីព្រោះខ្ញុំយល់ថា ប៉ុល ពត ធ្វើត្រូវ អ្វីដែល ប៉ុល ពត បានធ្វើគឺគាត់ធ្វើត្រូវ។ អ្នកសម្ភាស៖ ចុះ ស-២១? ខៀវ សំផន៖ ស-២១ ខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងទាល់តែសោះ។ ដូច្នេះមិនអាចទម្លាក់កំហុសនេះទៅលើ ប៉ុល ពត នោះទេ ដោយសារតែខ្ញុំមិនដឹងថាមានស-២១ នោះទេ។ អ្នកសម្ភាស៖ លោកចង់មានន័យថា ប៉ុល ពត មិនមែនជាអ្នកទទួលខុសត្រូវមែនទេ? ខៀវ សំផន៖ សួរថាម៉េច? អ្នកសម្ភាស៖ លោកមិនគិតថាអ្នក ប៉ុល ពត ជាអ្នកទទួលខុសត្រូវនោះទេ មែនទេ? ខៀវ សំផន៖ ពិតណាស់ ព្រោះថាគាត់ជាប្រធានបក្ស ទោះជាគាត់មិនដឹងក៏ដោយ តែគាត់ជាប្រធានបក្ស គាត់ត្រូវតែទទួលខុសត្រូវ។ អ្នកសម្ភាស៖ ចំណុចនេះធ្វើឲ្យលោកផ្លាស់ប្ដូរការគោរពរបស់លោកចំពោះ ប៉ុល ពត ដែរឬទេ? ខៀវ*

*សំផន៖ ខ្ញុំបាននិយាយរួចហើយ បញ្ហាស្មុគស្មាញណាស់។ គេមិនអាចនិយាយថា អ្នកឯងខុស អ្នកឯងត្រូវទទួលទោស អ្នកឯងត្រូវតែចាកចេញនោះទេ វាមិនមែនងាយស្រួលបែបហ្នឹងពេកទេ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៤១:១០]

**លោក អាប់ឌុលឡាក់ ថាវីក៖**

នៅពេលនេះគឺយើងបន្តនិយាយអំពីសៀវភៅពីរក្បាលដែលសរសេរ ដែលនិពន្ធដោយ ខៀវ សំផន ហើយបន្ទាប់មកយើងនឹងមើលឯកសារ ខ្សែឯកសារនេះឡើងវិញដោយមានការអនុញ្ញាតពីលោកប្រធាន។ នៅពេលនេះ គឺយើងមើលឯកសារ E3/16 ឯកសារ សៀវភៅចំណងជើងថា “ពិចារណាប្រវត្តិសាស្ត្រប្រទេសកម្ពុជាតាំងពីដំណាក់ដំបូងរហូតដល់ដំណាក់កាលកម្ពុជាប្រជាធិបតេយ្យ”។ ជំពូកទី៥ វាជាសៀវភៅមួយដែលមានច្រើនទំព័រ ជាង៣០០ទំព័រជាភាសាខ្មែរ។ ដូច្នេះ ខ្ញុំសូមដកស្រង់អត្ថបទខ្លីៗតែប៉ុណ្ណោះ ដែលនៅក្នុងនោះ ខៀវ សំផន បានលើកឡើងអំពីការយល់ឃើញរបស់គាត់ អំពីចលនាខ្មែរក្រហម ហើយគាត់ក៏បានលើកអំពីបញ្ហាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។

អត្ថបទពាក់ព័ន្ធទី១ គឺខ្មែរ ERN 00380351, បារាំងមានលេខ 00343824, អង់គ្លេសមានលេខ 00498222។ គាត់បានលើកឡើងដូចតទៅ “ការរៀបរាប់នោះគឺបង្ហាញអំពីលទ្ធភាពរបស់គាត់វិភាគសម័យខ្មែរក្រហម។ ខ្ញុំមានជំនឿតាមការយល់ឃើញរបស់ខ្ញុំជាទូទៅលើចលនាដោយផ្អែកលើហេតុផលពីរ។ ដំបូងខ្ញុំធ្វើដំណើរជាមួយនឹងចលនាជាង៣០ឆ្នាំ ហើយខ្ញុំដល់ផ្លូវបត់បែនជាច្រើនលើកច្រើនសា ពេលខ្លះស្របជាមួយនឹងជីវិតរបស់ខ្ញុំ។ ទី២ ខ្លួនខ្ញុំផ្ទាល់ខ្ញុំដឹងវីរជនជាច្រើនដែលគេមិនស្គាល់ យុទ្ធជន សមមិត្ត ជនស្នេហាជាតិ ស្ត្រីនិងបុរសដែលពលីជីវិតរបស់ខ្លួនដើម្បីបុព្វហេតុជាតិនិងយុត្តិធម៌។ អ្នកទាំងអស់នោះគឺមានបំណងដើម្បីគោលបំណងដូច្នេះ”។

[១៥:៤៣:២១]

អត្ថបទបន្ទាប់ទៀត ពាក់ព័ន្ធទៅនឹង ខៀវ សំផន ការយល់ឃើញរបស់ ខៀវ សំផន។ ចំពោះការយល់ឃើញអំពី ចាន់ ចក្រី ជាមេបញ្ជាការកងពលភូមិភាគបូព៌ា។ ខ្មែរ ERN គឺ 00380444, បារាំងមានលេខ 00643877, អង់គ្លេសមានលេខ 00498272 នេះជាអ្វីដែលលើកឡើង។ “ចំពោះចក្រី ប៉ុល ពត មិនជឿគាត់ក្នុងពេលមួយចំនួន។ ឧទាហរណ៍នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ៧៥ កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍គាត់បានលើកឡើងថា ទោះបីជាកងពល កុយ ធួន នោះខ្លាំងក៏ដោយ ការអប់រំ

ផ្នែកនយោបាយរបស់ក្រុមនេះគឺថា មិនខ្លាំងក្លានោះទេ។ ចក្រី នេះគឺថាអាចមានទំនាក់ទំនងជាមួយវៀតណាម ដូច្នេះហើយយើងត្រូវតាមដានឲ្យស្អិតល្អួត”។ ដើម្បីយុត្តិធម៌យើងឃើញថា លេខយោងជើងទំព័រគឺថា បានយោងទៅសៀវភៅរបស់ ប៉ែន យៀវនិន។ បន្ទាប់មក ខៀវ សំផន បានលើកឡើងទៀតថា “ខ្ញុំយល់ឃើញថា ប៉ុល ពត និយាយបញ្ហានេះនៅចំពោះមុខគណៈអចិន្ត្រៃយ៍ ហើយមិនមែនគាត់ស្អប់ ចក្រី នោះទេ គាត់និយាយក្នុងនាមជាលេខាបក្សដែលជាអ្នកតាមដាន ចក្រី ជាយូរមកហើយ”។

[១៥:៤៤:៥៥]

អត្ថបទបន្ទាប់ទៀត គឺពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ចក្រី និងបុគ្គលផ្សេងទៀត ជាប់ទាក់ទង ឬសង្ស័យជាប់ទាក់ទងទៅនឹង ចក្រី។ ខ្មែរ ERN គឺ 00380454, បារាំងមានលេខ 00643883, អង់គ្លេសមានលេខ 00498277។ ដកស្រង់សម្ដី “ដោយសារតែការជ្រៀតជ្រែករបស់វៀតណាម ដែលខ្ញុំបានលើកឡើងដោយសង្ខេប នៅពេលនេះខ្ញុំសូមលើកឡើងការសង្ខេបរបស់ខ្ញុំ។ ភស្តុតាង ហ្វីលីព ស្សូត បានផ្ដល់ឲ្យ និយាយអំពីវៀតណាមបានបង្កើតខ្មែរ -- ចលនាខ្មែររំដោះ ជាមួយនឹងភស្តុតាងអ្នកស្រាវជ្រាវផ្សេងទៀតរកឃើញ បានបង្ហាញឲ្យឃើញច្បាស់ថា ការតាមដានរបស់ ប៉ុល ពត ក្រោមគោលការណ៍ ៣៧៨ ឈូក, យ៉ា និងកម្មាភិបាលផ្សេងទៀតដែលរួមជាមួយនឹងវៀតមិញនោះ គឺត្រឹមត្រូវមែន។ ដូច្នេះ ហ្វីលីព ស្សូត សរសេរមិនត្រឹមត្រូវនោះទេ នៅពេលដែលគាត់និយាយអំពី ស-២១ ដែលគាត់លើកឡើងអំពីបញ្ហានៃខ្សែក្បត់ ដែលថាស-២១ត្រូវចាប់ ហើយដែលបានសម្រេចទៅតាមនោះ។ គោលនយោបាយឯករាជ្យរបស់វៀតណាម តម្រូវឲ្យយើងអនុវត្តគោលនយោបាយរឹងប៉ឹងរបស់យើងនៅក្នុងប្រទេស”។

[១៥:៤៦:៣៧]

ផ្នែកមួយទៀតនៅក្នុងជំពូកសៀវភៅនេះ ខៀវ សំផន បានវិភាគចម្លើយសារភាពរបស់ កុយ ធួន ហៅ ធុច ហើយគាត់យល់ថា មានការអ្វីកើតឡើងចំពោះការចាប់ខ្លួន កុយ ធួន ហើយនិងគូកនរបស់គាត់។ ខ្មែរ ERN គឺ 00380457, អង់គ្លេសមានលេខ 00498279, បារាំងមានលេខ 0064 3885។ សូមដកស្រង់សម្ដី “តាមអ្វីដែលខ្ញុំយល់ ការទទួលខុសត្រូវនោះគឺថា មានចំណុចបីដែល ប៉ុល ពត ចាប់អារម្មណ៍។ ចម្លើយសារភាពនេះបាននាំឲ្យ ប៉ុល ពត ជឿកាន់តែខ្លាំងថា ការចាប់ខ្លួន យ៉ា នោះ មិនខុសនោះទេ។ យ៉ា គឺជាបុគ្គលដែលដើរតួនាទីសំខាន់នៅក្នុងបក្សថ្មីដែលគេបង្កើតឡើង។ ទី២ បញ្ហាដែល ប៉ុល ពត កត់សម្គាល់នោះ សំខាន់បំផុតនោះ គឺពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់ កុយ ធួន មានន័យថា ឌឿន បានផ្ដល់ព័ត៌មានសម្ងាត់ទៅដល់ យ៉ា បញ្ហាទាក់ទងទៅនឹងបញ្ហាគណៈអចិន្ត្រៃយ៍

ហើយនិងបញ្ហាលេខា និងអនុលេខានៅរតនគិរី។ ក្រៅពី ឌឿន គ្មាននរណា--

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងសហព្រះរាជអាជ្ញាផ្អាកបន្តិចសិន!

[១៥:៤៨:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៦:០៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកសហព្រះរាជអាជ្ញា នេះជាការប្រកាសជាទូទៅ ដូច្នេះមិនពាក់ព័ន្ធនឹងលោកនោះទេ។ លោកប្រធានស្នើសុំខ្ញុំឲ្យជម្រាបជូនភាគីនិងសាធារណជនថា យើងបានទទួលរបាយការណ៍ពេទ្យពាក់ព័ន្ធទៅនឹង នួន ជា។ របាយការណ៍នោះផ្តល់អនុសាសន៍ថា ឲ្យគាត់នោះសម្រាក២សប្តាហ៍ ក្រោយពេលអង្គជំនុំជម្រះស្នើសុំឲ្យមានការបញ្ជាក់លើបញ្ហាសុខភាព។ ដូច្នេះរបាយការណ៍បញ្ជាក់ថាឲ្យលោក នួន ជា នេះសម្រាកទាំងស្រុងតែម្តង មិនចាំបាច់ឲ្យតាមដានពីបន្ទប់ឃុំខ្លួនខាងក្រោមនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះនឹងសម្រេចពិចារណា ថាតើត្រូវធ្វើយ៉ាងម៉េចសម្រាប់សប្តាហ៍ក្រោយ។

[១៥:៥៧:១៦]

ចំណុចទី១ ឯកសារពាក់ព័ន្ធទៅនឹង ខៀវ សំផន មិនទាន់បានបញ្ចប់ចប់សព្វគ្រប់នោះទេ ទោះបីជានៅក្នុងរសៀលនេះក៏ដោយ។ នេះជាចំណុចទី១ ដែលថាបញ្ហាឯកសារលើតួនាទីរបស់ ខៀវ សំផន នឹងតទៅថ្ងៃអង្គារអាទិត្យក្រោយ។

មេធាវីការពារក្តី នួន ជា ខ្ញុំមានសំណួរមួយចំនួនចង់សួរទៅកាន់លោក។ ចំណុចទី១ គឺយើងខ្ញុំមិនសួរអំពីការដាក់លិខិតបោះបង់សិទ្ធិមានវត្តមានចំពោះសាក្សីទី១ សម្រាប់សប្តាហ៍ក្រោយនោះទេ។ ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនោះ ពាក់ព័ន្ធនឹងអ្នកទាំងអស់នោះ គឺថាយើងខ្ញុំសូមសួរបញ្ជាក់ពីលោក តើយល់យ៉ាងម៉េចដែរ? ខ្ញុំដឹងថាក្រុមមេធាវីការពារក្តីនោះមិនអាចឆ្លើយតបភ្លាមៗនៅពេលនេះនោះទេ។ ក៏ប៉ុន្តែយើងខ្ញុំចង់ឲ្យលោកនោះជូនដំណឹងមកយើងខ្ញុំនៅចុងសប្តាហ៍។ ទី១ គឺ TCW-100 បុគ្គលរូបនេះមិនទាន់បានស្តាប់បញ្ចប់រួចរាល់នោះទេ។ យើងខ្ញុំយល់ថា យើងត្រូវចំណាយពេល១ថ្ងៃទៅ

២ថ្ងៃទៀត ដើម្បីបញ្ចប់ស្តាប់សក្ខីកម្មសាក្សីរូបនេះ។ ដូច្នេះ តើ នួន ជា នោះរៀបត្រៀមខ្លួនបោះបង់សិទ្ធិមានវត្តមានចំពោះសាក្សីរូបនេះ ឬក៏យ៉ាងម៉េច?

សាក្សីបន្ទាប់ទៀត គឺ TCCP-116។ វាបង្ហាញយ៉ាងច្បាស់ដល់អង្គជំនុំជម្រះថា ពេលវេលាជាច្រើននោះគឺថា ភាគីមិនចង់ស្តាប់ដោយទាំងស្រុង ទាំងអស់គ្រប់នោះទេ។ ដូច្នេះហើយវាទំនងជាថា ខាងក្រុមមេធាវី នួន ជា នេះអាចសួរបញ្ជាក់នួន ជា ថាតើបោះបង់សិទ្ធិ ឬក៏យ៉ាងណា?

[១៥:៥៩:១០]

ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺថាគាត់បានធ្វើដំណើរចាកចេញពីទ្វីបអឺរ៉ុបមកហើយ ដូច្នេះហើយយើងខ្ញុំសូមសួរទៅខាងក្រុមមេធាវីនោះ ឲ្យបញ្ជាក់អំពីស្ថានភាពពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី តើ -- ខ្ញុំគិតថា លោកប្រហែលជាអាចជួយផ្តល់ព័ត៌មានទាំងអស់នេះឲ្យយើងខ្ញុំបាន។ ហើយយើងខ្ញុំគិតថា លោកនឹងផ្តល់ព័ត៌មានការជូនដំណឹងមកអង្គជំនុំជម្រះគ្រប់គ្រាន់ជាមិនខាន។

បញ្ហាបង្ហាញឯកសារអំពីតួនាទី ខៀវ សំផន នេះគឺថា ភាគីនឹងមានឱកាសផ្តល់យោបល់ និងធ្វើការលើកឡើងការជំទាស់របស់ខ្លួន ក្រោយពីតំណាងសហព្រះរាជអាជ្ញាធ្វើការបង្ហាញអំពីឯកសារទាំងអស់ចប់សព្វគ្រប់។ នេះជាដំណើរការនីតិវិធីរបស់យើង។ ខ្ញុំចង់សួរ និងគិតថាអ្វីដែលខ្ញុំលើកឡើងនេះគឺប្រហែលជាគ្រប់គ្រាន់ហើយលោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

[១៦:០០:៣៥]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ បញ្ហាការងារជាក់ស្តែងមួយ បញ្ហាមួយដែលខ្ញុំសូមឆ្លើយតបទៅនឹងការសួរបញ្ជាក់ពីអង្គជំនុំជម្រះ ដូចដែលលោក លោកស្រីចៅក្រមជ្រាបហើយថ្ងៃសុក្រស្អែក និងថ្ងៃចន្ទ មិនធ្វើសវនាការនោះទេ។ ដូច្នេះហើយប្រហែលជាយើងមានឱកាសជួបជាមួយនឹងកូនក្តីរបស់ខ្ញុំ។ សហសេវិករបស់ខ្ញុំគឺ សុន អរុណ កំពុងតែជួបនាពេលបច្ចុប្បន្នហើយ។ ដូច្នេះហើយ គឺខ្ញុំគ្រាន់តែជូនដំណឹងថាអ៊ីចឹង ថាលោក សុន អរុណ បានទៅជួបនឹងកូនក្តីនៅពេលនេះហើយ។

ហើយចំពោះលិខិតបោះបង់សិទ្ធិ ដែលថាអាចដាក់ទៅបានឬក៏យ៉ាងណានោះ ខ្ញុំសូមបញ្ជាក់ថាពាក់ព័ន្ធទៅនឹងលិខិត ពាក់ព័ន្ធទៅនឹងការបោះបង់សិទ្ធិស្តាប់លោក រ៉ូកូហ្វ គឺលោក នួន ជា បញ្ជាក់យ៉ាង

ច្បាស់ដោយណែនាំយើងថា -- គឺថាការលិខិតបោះបង់សិទ្ធិនោះ គឺជាការលើកលែងមួយករណីសាក្សី រ៉ុក្ខហួ ហ៊្វឹង។ ប៉ុន្តែពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺខ្ញុំសូមបញ្ជាក់ ប៉ុន្តែខ្ញុំមិនបានជួបជាមួយនឹងកូនក្តីរបស់ខ្ញុំទេ គឺខ្ញុំសូមបញ្ជាក់ថា ប្រហែលជាកូនក្តីរបស់ខ្ញុំនោះអាចមានបោះបង់សិទ្ធិមានវត្តមានស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសាក្សី១០០នោះ ប្រហែលជាគាត់មិនបោះបង់សិទ្ធិនោះទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណដែលលោកបានបញ្ជាក់។ អង្គជំនុំជម្រះយល់អំពីជំហររបស់លោក ហើយយើងខ្ញុំលើកបុគ្គលពីររូបអម្បាញ់មិញនេះ ដើម្បីប្រហែលជាអាចខាងលោកនោះបោះបង់សិទ្ធិ។ អង្គជំនុំជម្រះមិនមែនលើកជាសំណើរថាឲ្យលោក ឲ្យកូនក្តីរបស់លោកបោះបង់សិទ្ធិស្តាប់សក្ខីកម្មបុគ្គលពីរនាក់អម្បាញ់មិញ និងបុគ្គលក្រោយៗទៀតនោះទេ។

[១៦:០២:៣៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៣:២៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺថាដល់ពេលសមល្មមដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការដែលគ្រោងធ្វើនៅថ្ងៃអង្គារ ទី០៥ ខែមករា (ស៊ីក) ឆ្នាំ២០១៣ ដូចលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍បានជម្រាបជូនហើយ គឺយើងបន្តការដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ដោយតំណាងសហព្រះរាជអាជ្ញា។ ការអត្ថាធិប្បាយ ឬ/និងការជំទាស់របស់ភាគី និងការឆ្លើយតបរបស់ភាគីដែលពាក់ព័ន្ធ ហើយនិងមានលទ្ធភាពអាចបន្តការស្តាប់សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានស្នើសុំទៅ អ៊ំ! ដែលបានជម្រាបសួរទៅលោកមេធាវីការពារក្តីលោក នួន ជា អំពីលទ្ធភាពក្នុងការលះបង់សិទ្ធិអម្បាញ់មិញនេះ។ ហើយលទ្ធភាពដូច្នេះ អង្គជំនុំជម្រះនឹងបន្តធ្វើតាមអ្វីដែលបានជម្រាបជូននេះ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក

អៀង សារី និង ខៀវ សំផន ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃអង្គារ ទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី ឲ្យនាំគាត់មកដាក់ត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៦:០៥ នាទី)*